مدرسة اهل البيت
صلوات الله عليهم

# សាលា អាស្ហ់លុល-បៃត៍

## សៀវភៅសិក្សា ប្រវត្តិសាស្ត្រ (تَارِيْخ)

## ថ្នាក់ទី ៨ (អាយុ ១២-១៣ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ សមរភូមិវាយយកម៉ាក់កាស្ទ់ - ភាគ ១ ........................................ ៥
មេរៀនទី ២ សមរភូមិវាយយកម៉ាក់កាស្ទ់ - ភាគ ២ ........................................ ៩
មេរៀនទី ៣ សមរភូមិហ៊្វូណៃន៍ ........................................ ១៣
មេរៀនទី ៤ សមរភូមិត្អ៏អុីហ្វ ........................................ ១៧
មេរៀនទី ៥ សមរភូមិតាប៊ុក ........................................ ២១
មេរៀនទី ៦ ព្រឹត្តិការណ៍មូបាហ្វាឡាស្ទ់ - ភាគ ១ ........................................ ២៦
មេរៀនទី ៧ ព្រឹត្តិការណ៍មូបាហ្វាឡាស្ទ់ - ភាគ ២ ........................................ ៣១
មេរៀនទី ៨ ផែនការសម្លាប់ព្រះសាស្តាមូហ្ហាំម៉ាដ់ صلى الله عليه وآله وسلم ........................................ ៣៦
មេរៀនទី ៩ ពិធីហ្ហាជ្ជ់លាគ្នា ........................................ ៣៩
មេរៀនទី ១០ ព្រឹត្តិការណ៍ក្ហ៏ដៀរ ........................................ ៤៣
មេរៀនទី ១១ ពេលព្រះសាស្តាមូហ្ហាំម៉ាដ់ صلى الله عليه وآله وسلم ជិតសោយព្រះទិវង្គត ........................................ ៤៨
មេរៀនទី ១២ ព្រះទិវង្គតនិងកិច្ចបញ្ចុះព្រះរាជសពព្រះសាស្តាមូហ្ហាំម៉ាដ់ صلى الله عليه وآله وسلم .... ៥៣
មេរៀនទី ១៣ អុីមុាំអ្ហលី صلوات الله عليه والسلام - ភាគ ១ ........................................ ៥៧
មេរៀនទី ១៤ អុីមុាំអ្ហលី صلوات الله عليه والسلام - ភាគ ២ ........................................ ៦២
មេរៀនទី ១៥ អុីមុាំអ្ហលី صلوات الله عليه والسلام - ភាគ ៣ ........................................ ៦៧
មេរៀនទី ១៦ អុីមុាំអ្ហលី صلوات الله عليه والسلام - ភាគ ៤ ........................................ ៧២
មេរៀនទី ១៧ អុីមុាំហ្ហាសាន់ صلوات الله عليه والسلام - ភាគ ១ ........................................ ៧៧
មេរៀនទី ១៨ អុីមុាំហ្ហាសាន់ صلوات الله عليه والسلام - ភាគ ២ ........................................ ៨២
មេរៀនទី ១៩ អុីមុាំហ្ហូសែន៍ صلوات الله عليه والسلام - ភាគ ១ ........................................ ៨៧
មេរៀនទី ២០ អុីមុាំហ្ហូសែន៍ صلوات الله عليه والسلام - ភាគ ២ ........................................ ៩២

## មេរៀនទី ១

# សមរភូមិវាយយកម៉ាក់កាស់ - ភាគ ១

ឆ្នាំទី ៦ សករាជហ៊ិជ្រោះត៍ ពួកមេដឹកនាំគូរ៉យស្ស៍ស្រុកម៉ាក់កាស់និងព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ បានចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងហ៊ូដៃប៊ីយ៉ាស់ ។ នៅក្នុងកិច្ចព្រមព្រៀងនេះ មាននូវលក្ខខណ្ឌមួយចែងថាមិនឲ្យមានការប្រយុទ្ធគ្នាទេរវាងបក្សទាំងពីរក្នុងរយៈពេល ១០ ឆ្នាំ ។ មានសន្តិភាពទូទៅច្រើនឆ្នាំក្រោយកិច្ចព្រមព្រៀង ពួកមុស្លីមអាចទៅធ្វើពិធីហាជ្ជ៍បានដោយសេរីនៅឯម៉ាក់កាស់ ក្នុងវត្តមានពួកគោរពបូជារូបចម្លាក់សត្រូវអ៊ីស្លាម ។

ខែយ៉ូម៉ាដា អាល់-អៅវ៉ាល់ ឆ្នាំទី ៨ សករាជហ៊ិជ្រោះត៍ ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ បានចាត់បញ្ជូនវរេហ៍ពល ៣០០០ នាក់ទៅកាន់ព្រំដែនស៊ីរីដើម្បីធ្វើទណ្ឌកម្មពួករ៉ូម ដែលបានសម្លាប់បេសកជនមុស្លីមគ្មានការការពារយ៉ាងសាហាវ ។ ក៏ប៉ុន្តែបក្សមុស្លីមមិនបានប្រយុទ្ធលុះចប់សមរភូមិទេ បានដកថយបន្ទាប់ពីបានវាយលុកខ្លះ ។ ទោះបីមុស្លីមមួយចំនួនបានបាត់បង់ជីវិតក៏ដោយ តែចម្បាំងពុំបានទទួលជ័យជំនះដែលបានគ្រោងទុកមុនទេ ។ ពេលបានទទួលដំណឹង ពួកគូរ៉យស្ស៍គិតថាកម្លាំងយោធារបស់បក្សមុស្លីមបានអន់ថយ ហើយក៏ព្រហើនហ៊ានបង្កវិបត្តិនៅក្នុងស្ថានភាពសន្តិសុខ ។

សកម្មភាពដំបូងរបស់ពួកគូរ៉យស្ស៍គឺញុះញង់មិត្តពួកគេ ប្រជាជាតិ បានីបាការ (بنو بكر بن وائل) ឲ្យវាយលុកកុំឲ្យដឹងខ្លួនមុនប្រជាជាតិ បានី ឃូស្សាអាស់ (بنو خزاعة) ដែលជាសម្ព័ន្ធមិត្តនិងនៅក្រោមការការពាររបស់បក្សមុស្លីម ។ ប្រជាជាតិបានី ឃូស្សាអាស់ ត្រូវវាយលុកដោយពុំបានដឹងខ្លួនមុន មិនអាចតស៊ូបានច្រើន ត្រូវសម្លាប់កំពុងដេកនិងកំពុងស៊ូឡាត់ ។ បណ្តាអ្នកដែលនៅរស់ត្រូវចាប់ខ្លួនជាឈ្លើយសឹក ។

ពេលបានទទួលដំណឹង ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ បានសន្យាសងសឹកឲ្យប្រជាជាតិ បានី ឃូស្សាអាស់ ។ លុះបានដឹងថាបក្សមុស្លីមយកចិត្តទុកដាក់នឹងការរំលោភកិច្ចព្រមព្រៀងនេះ ពួកគូរ៉យស្ស៍ក៏ស្តាយក្រោយដែលបានធ្វើសកម្មភាព

តក់ក្រហល់ពេក ។ ដើម្បីបន្ធូរស្ថានភាព ពួកគេបានបញ្ជូន អាប៊ូ ស៊ុហ្វយ៉ាន ទៅម៉ាឌីណាស៊្ហជាមួយបណ្ដាំឲ្យបិទបាំងអំពើឧក្រិដ្ឋដោយប្រើគ្រប់មធ្យោបាយ ។

មកដល់ម៉ាឌីណាស៊្ហ អាប៊ូ ស៊ុហ្វយ៉ាន ទៅកាន់លំនៅរបស់កូនស្រីលោកឈ្មោះ អ៊ូម ហាប៊ីបាស៊្ហ (أُمُّ حبيبة رَمْلَةُ بِنْتُ أَبِي سُفْيَانَ) មហេសីរបស់ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ។ ពេលគាត់ចង់អង្គុយលើពូករបស់ព្រះសាស្ដាﷺ កូនស្រីគាត់បត់ពូកនោះភ្លាម ។ អាប៊ូ ស៊ុហ្វយ៉ាន សួរថា៖ "ពូកនេះមិនល្អសម្រាប់ខ្ញុំ ឬក៏ខ្ញុំមិនល្អសម្រាប់ពូកនេះ ?" កូនស្រីគាត់តបថា៖ "ខ្ញុំមិនចង់ឲ្យបុគ្គលឥតជំនឿណាឃ្មើសអង្គុយលើពូករបស់ព្រះសាស្ដាﷺទេ ។"

ឧប្បត្តិហេតុកើតឡើងនៅឯផ្ទះកូនស្រីគាត់បានធ្វើឲ្យ អាប៊ូ ស៊ុហ្វយ៉ាន ទើសទាល់ តែគាត់សម្រេចចិត្តទៅជួបព្រះសាស្ដាមូហាំម៉ាដ្ឋﷺ ។ ពេលជួបព្រះអង្គﷺ អាប៊ូ ស៊ុហ្វយ៉ាន និយាយដោយឥតអៀនខ្មាស់អំពីការរឹតបន្តឹងទំនាក់ទំនងសន្តិភាពរវាងបក្សមុស្លីមនិងបក្សគូរ៉យ៉ស្ហ៍ ហាក់ដូចជាការប្រព្រឹត្តរបស់ពួកគេទៅលើបក្សសម្ព័ន្ធនោះមិនសំខាន់សោះ ។ តែព្រះសាស្ដាមូហាំម៉ាដ្ឋﷺនៅស្ងៀម មិនចេញវាចា សម្ដែងឲ្យឃើញថាព្រះអង្គعزّوجلّមិនចាប់អារម្មណ៍សោះអំពីការស្នើនោះ ។

អាប៊ូ ស៊ុហ្វយ៉ាន ដឹងខ្លួនថាមិនអាចធ្វើឲ្យព្រះសាស្ដាមូហាំម៉ាដ្ឋﷺផ្លាស់ប្ដូរអារម្មណ៍បានទេ និងមិនអាចរារាំងបក្សមុស្លីមសងសឹកបានទេ ។ ដូច្នេះ គាត់បានត្រឡប់ទៅម៉ាក់កាស៊្ហវិញ ប្រាប់ដំណឹងពួកគូរ៉យ៉ស្ហ៍ ។

ព្រះសាស្ដាមូហាំម៉ាដ្ឋﷺបានសម្រេចចិត្តឆ្លៀតយកឱកាសនេះ ដើម្បីទាញយកម៉ាក់កាស៊្ហមកនៅក្រោមការគ្រប់គ្រងរបស់អ៊ីស្លាមវិញរហូតតរៀងទៅ ។ តែព្រះអង្គعزّوجلّមានបំណង ចាប់យកមូលដ្ឋានចុងក្រោយបង្អស់របស់ពួកឥតសាសនានេះដោយមានការបង្ហូរឈាមតិចបំផុត ។ ព្រះអង្គعزّوجلّមានគម្រោងការទៅកាន់ម៉ាក់កាស៊្ហយ៉ាងលឿននិងស្ងាត់ៗបំផុតជាមួយទ័ពធំ ។ ព្រះអង្គﷺសង្ឃឹមថាពេលប្រឈមនឹងកងទ័ពក៏សម្បើមដោយឥតដឹងខ្លួនមុន ពួកម៉ាក់កាស៊្ហនឹងបោះបង់ការប្រយុទ្ធ ។

អនុវត្តិតាមផែនការរបស់ព្រះអង្គﷺ ព្រះសាស្ដាមូហាំម៉ាដ្ឋﷺបានប្រមូលទ័ពមុស្លីមថ្ងៃទី ១០ ខែរ៉ម៉ាដ្ហន ឆ្នាំទី ៨ សករាជហ៊ីជ្រ៉ោះត៏ ហើយបានលើកទ័ពទៅកាន់ម៉ាក់កាស៊្ហជាមួយរេហ៍ពល ១០០០០ នាក់ ។ ពេលបានទៅដល់កន្លែងមួយហៅថា កាឌីដ ឆ្ងាយពីម៉ាឌីណាស៊្ហបន្តិច ព្រះសាស្ដាមូហាំម៉ាដ្ឋﷺនិងកនមុស្លីម

បានស្រាយត្រណម ។ រួចហើយបានបន្តដំណើរទៅកាន់ម៉ាក់កាស្ទ ។

អាប់បាស់ ប៊ិន អាប់ឌុល-មុត្តត៏លិប ឪពុកធំរបស់ព្រះសាស្ដាមូហាំម៉ាដ្ឋﷺ រស់នៅឯម៉ាក់កាស្ទ តែងតែប្រាប់ដំណឹងព្រះសាស្ដាﷺអំពីការពិភាក្សារបស់ពួកគូរ៉យស៍ ។ ថ្វីដ្បិតតែលោកជាមុស្លីម តែលោកមានទំនាក់ទំនងល្អជាមួយពួកមេដឹកនាំគូរ៉យ៉ស៍ ។ ខណៈដែលព្រះសាស្ដាﷺឆ្ពោះមកកាន់ម៉ាក់កាស្ទ អាប់បាស់មកកាន់ម៉ាឌីណាស្ទ ។ ទាំងពីរអ្នកបានជួបគ្នានៅឯកន្លែងមួយហៅថា យ៉ុះហ្វាស្ទ (الْجُحْفَة) ។ វត្តមានរបស់អាប់បាស់មានប្រយោជន៍ណាស់សម្រាប់ការវាយយកម៉ាក់កាស្ទ ។

ទ័ពមុស្លីមបានឈប់សម្រាកឆ្ងាយពីម៉ាក់កាស្ទបន្តិច ។ ពួកអ្នកស្រុកម៉ាក់កាស្ទដែលមិនដឹងអំពីវត្តមានរបស់ពួកមុស្លីមភ័យស្លន់ស្លោ ពេលឃើញភ្លើងជំរំមុស្លីមភ្លឺរាប់រយនៅលើទួលនៅជុំវិញម៉ាក់កាស្ទ ។

អាប៊ូ ស៊ុហ្វយ៉ាននិងមេដឹកនាំគូរ៉យ៉ស៍ខ្លះទៀត បានទៅកាន់កន្លែងភ្លើងនោះ ។ បុគ្គលដំបូងនេះត្រូវអាប់បាស់ការពារពីផ្លែដាវរបស់បក្សមុស្លីម ហើយបាននាំគាត់ទៅកាន់ជំរំព្រះសាស្ដាមូហាំម៉ាដ្ឋﷺ ។

ពេលព្រះសាស្ដាមូហាំម៉ាដ្ឋﷺឃើញគាត់ ព្រះអង្គﷻមានព្រះវចនៈថាៈ "លោកដល់ពេលទទួលស្គាល់ហើយឬនៅ ថាពុំមានព្រះផ្សេងពីអល់ឡោះហ៍ﷻទេនោះ ?" តែ អាប៊ូ ស៊ុហ្វយ៉ាន មិនចង់បោះបង់ចោលជំនឿលើរូបព្រះរបស់គាត់ទេ ។ ឃើញគាត់រារែក មិនដាច់ស្រេច អាប់បាស់បានតឿនគាត់ថាបើគាត់បង្អែបង្អង់យូរគាត់នឹងមិនរួចជីវិតទេ ។ ដឹងខ្លួនថាគាត់កំពុងនៅក្នុងគ្រោះថ្នាក់ អាប៊ូ ស៊ុហ្វយ៉ាន ក៏ព្រមទទួលអ៊ីស្លាមជាសាសនាគាត់ ថ្វីដ្បិតនៅក្នុងចិត្តគាត់ភ្លើងហិង្សាចំពោះព្រះសាស្ដាﷺកំពុងឆេះឆួលខ្លាំងបំផុត ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីកិច្ចព្រមព្រៀងហ៊្វូដៃប៊ីយ៉ាស់ជាជ័យជំនះសម្រាប់ពួកមុស្លីម ?

២. ហេតុអ្វីក្រុមមុស្លីមមិនអាចប្រយុទ្ធតទល់ពួករ៉ូមបានទេនៅឯស៊ីរីនោះ ?

៣. អ្វីបានធ្វើឲ្យអាប៊ូ ស៊ុហ្វយ៉ានភ្ញាក់ផ្អើលនៅម៉ាឌីណាស់ ?

៤. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺបានសម្រេចចិត្ត លើកទ័ពទៅកាន់ម៉ាក់កាស់ដោយស្ងាត់ៗ ?

៥. ហេតុអ្វីអាប៊ូ ស៊ុហ្វយ៉ានទៅជាមុស្លីមទីបំផុត ?

## មេរៀនទី ២

# សមរភូមិវាយយកម៉ាក់កាស់ - ភាគ ២

ថ្វីដ្បិតព្រះសាស្ដាមូហាំម៉ាដ់ﷺដឹងច្បាស់ថា អាប៊ូ ស៊ុហ្វយ៉ាន ចូលសាសនាអ៊ីស្លាមព្រោះតែចង់រួចជីវិត ព្រះអង្គﷺព្រមទទួលការប្ដេជ្ញារបស់បុរសនេះព្រោះវាមានប្រយោជន៍សម្រាប់វាយយកម៉ាក់កាស់ដោយមិនបង្ហូរឈាម ។

ដើម្បីនឹងឲ្យ អាប៊ូ ស៊ុហ្វយ៉ាន ឃើញថាព្រះអង្គﷺមិនយកទោសគាត់ទេ ព្រះសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថាៈ



អាប៊ូ ស៊ុហ្វយ៉ាន បានទទួលការអនុញ្ញាតឲ្យធានាអ្នកស្រុកម៉ាក់កាស់ថា អ្នកណាទៅជ្រកក្នុងម៉ាស់យ៊ិឌុល-ហ្ការ៉ម ជុំវិញព្រះមហាគ្រឹះកាក់បាស់ ឬដាក់អាវុធ ឬនៅក្នុងផ្ទះខ្លួន ឬទៅជ្រកឯផ្ទះរបស់ អាប៊ូ ស៊ុហ្វយ៉ាន ទ័ពអ៊ីស្លាមនឹងឲ្យអ្នកនោះរួចជីវិត ។

ព្រះសាស្ដាមូហាំម៉ាដ់ﷺចង់ឲ្យ អាប៊ូ ស៊ុហ្វយ៉ាន ឃើញកម្លាំងទ័ពមុស្លីម ដើម្បីនឹងឲ្យគាត់ទៅប្រាប់ពួកគូរ៉យស្ហ៍ថាមិនបាច់ប្រយុទ្ធតទល់បក្សមុស្លីមទេ នាំតែឥតប្រយោជន៍ ។ អ៊ាប់បាស់បានឃាត់ អាប៊ូ ស៊ុហ្វយ៉ាន នៅឯច្រកភ្នំតូចមួយដើម្បីនឹងឲ្យគាត់មើលទ័ពមុស្លីមដើរកាត់តាមនោះ ។

អានុភាពនិងភាពសម្បើមរបស់ទ័ពមុស្លីមធ្វើឲ្យ អាប៊ូ ស៊ុហ្វយ៉ាន ភ័យខ្លាច ការប៉ងប្រាថ្នាតស៊ូបានបាត់បង់អស់ពីក្នុងអារម្មណ៍គាត់ ។ ព្រះសាស្ដាមូហាំម៉ាដ់ﷺបានលែងគាត់ឲ្យទៅម៉ាក់កាស់វិញ ។ អាប៊ូ ស៊ុហ្វយ៉ានបាននិយាយប្រាប់អ្នកស្រុកម៉ាក់កាស់អ្វីដែលគាត់បានឃើញ ហើយបានប្រាប់ពួកគេឲ្យជ្រាបព្រះរាជសាររបស់ព្រះសាស្ដាﷺ ។ គាត់បានបន្ថែមថាមិនអាចវាយលុកទ័ពធំនិងប្រដាប់អាវុធគ្រប់

គ្រាន់បែបនេះបានជាដាច់ខាត ។ ពួកម៉ាក់កាស្ទ់អស់ទឹកចិត្តទាំងស្រុងពេលបានឮសម្តីអាប៊ូ ស៊ុហ្វយ៉ាន ។

ព្រះសាស្តាមូហ្ាំម៉ាដ្ទ់ﷺបានចូលទៅក្នុងនគរម៉ាក់កាស្ទ់ ដោយសេចក្តីថ្លៃថ្នូរលើខ្នងអូដ្ឋព្រះអង្គﷺឈ្មោះ អាល់-ក្វស្វ៉ាអ៌ (اَلْقَصْوَاء) ។ ពុំមានអ្នកណាមួយហ៊ានប្រយុទ្ធតទល់ព្រះអង្គﷺទេ ។ ព្រះអង្គﷺបានឈប់នៅខាងផ្នូរ អាប៊ូ ត៉ូលិប ឪពុកធំព្រះអង្គ ព្រះអង្គﷺបោះជំរំនៅកន្លែងនោះ ។

ក្រុមនីមួយៗនៃទ័ពមុស្លីមបានចូលទៅក្នុងស្រុកតាមច្រកទ្វារផ្សេងៗ ដោយពុំមានឧប្បត្តិហេតុ លើកលែងតែក្រុមរបស់ ខ៉ូលីដ្ទ ប៊ិន វ៉ាលីដ្ទ ។ អ្នកខ្លះបានរារាំងមិនឲ្យលោកចូលទេ ការប្រយុទ្ធគ្នាក៏បានផ្ទុះឡើង តែព្រះសាស្តាﷺបានបញ្ចប់ការប្រយុទ្ធនេះ ។ នគរម៉ាក់កាស្ទ់ទាំងមូលក៏បានចុះចាញ់បក្សមុស្លីមយ៉ាងឆាប់ៗ ។

ព្រះសាស្តាមូហ្ាំម៉ាដ្ទ់ﷺបានធ្វើឲ្យពួកម៉ាក់កាស្ទ់ចុះចូល ដោយប្រកាសថាព្រះអង្គﷺមិនសងសឹកពួកគេទេដែលបានធ្វើខុសកាលពីមុននោះ ពួកគេទាំងអស់មានសេរីភាព ។

បន្ទាប់មកព្រះអង្គﷺជិះអូដ្ឋ បន្តដំណើរទៅកាន់ព្រះមហាគ្រឹះកាក់ប៉ាស្ទ់ដើម្បីតាវ៉ាហ្វ់ ។ ក្នុងតាវ៉ាហ្វ់ជុំដំបូង ព្រះអង្គﷺបានទៅរករូបបដិមាបីធំជាងគេឈ្មោះ ហ៊ូបាល់ (هُبَل), អ៊ីសាហ្វ់ (إساف) និង ណាអ៊ីឡាស្ទ់ (نائلة) ដែលគេដាក់នៅពីលើទ្វារកាក់ប៉ាស្ទ់ ។ ព្រះអង្គﷺវាយទម្លាក់រូបព្រះទាំងនេះនឹងដំបងដែលព្រះអង្គﷺយកមកជាប់ខ្លួន ដោយសូត្រអាយ៉ាស្ទ់ព្រះគម្ពីរគួរអានថា៖

وَقُلْ جَآءَ ٱلْحَقُّ وَزَهَقَ ٱلْبَـٰطِلُ ۚ إِنَّ ٱلْبَـٰطِلَ كَانَ زَهُوقًا ﴿٨١﴾

*81. ចូរអ្នកថា៖ "ការពិតបានមកដល់ វិរុទ្ធភាពបានបាត់សូន្យបង់ ព្រោះវិរុទ្ធភាពរមែងតែវិនាសសូន្យបង់ ។"* (ស៊ូរ៉ោះត៍ បានី អ៊ីសរ៉អ៊ីល អាយ៉ាស្ទ់ 81 (17:81))

បន្ទាប់មក ព្រះសាស្តាមូហ្ាំម៉ាដ្ទ់ﷺបានចូលទៅក្នុងព្រះមហាគ្រឹះកាក់ប៉ាស្ទ់ដើម្បីបោសសម្អាតព្រះមហាគ្រឹះកាក់ប៉ាស្ទ់នេះ ឲ្យជ្រះស្អាតពីរូបព្រះនានាដែលនៅក្នុងនោះ ។ ព្រះអង្គﷺបានវាយកម្ទេចរូបបដិមាច្រើនដោយផ្ទាល់ដៃ ។ រូបបដិមាច្រើនត្រូវដាក់នៅលើកន្លែងខ្ពស់ ព្រះអង្គﷺមិនអាចលូកដល់ ដូច្នេះព្រះអង្គﷺឲ្យអ៊ីម៉ាំអ៊ាលីعليه السلامឡើងលើស្មាព្រះអង្គﷺ ទៅវាយទម្លាក់រូបចម្លាក់មកដី ។ ដូច្នេះស្លាកស្នាមចុងក្រោយបង្អស់នៃការធ្វើសក្ការៈរូបបដិមា ត្រូវបានលុបបំបាត់ពីព្រះ

មហាគ្រឹះកាក់បាស់និងពីម៉ាស់យ៉ិឌុល-ហ្ការ៉ម ។

ដល់ម៉ោងស្វ៉ឡាត្ទ ស្ហ៊ុហ្ហ៊រ (صَلَاة ٱلظُّهْر) ។ ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ឲ្យប៊ីឡាល់សូត្រអាសាន (أَذَان) ។ មុស្លីមទាំងអស់បានស្វ៉ឡាត្ទពីក្រោយព្រះសាស្ដា ﷺ ។ រួចហើយព្រះអង្គ ﷺ បានថ្លែងសុន្ទរកថា ដោយមានព្រះវចនៈសង្ខេបអំពីព្រះខ្លឹមសារនៃព្រះរាជសារអ៊ីស្លាម ។ ប្រជារាស្ត្រម៉ាក់កាស់ទាំងអស់បានប្ដេជ្ញាទទួលស្គាល់និងស្ម័គ្រស្មោះព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ។

អល់ឡោះហ្ទ៍ ﷻ បានគោរពពាក្យសន្យារបស់ព្រះអង្គ ﷻ ដែលព្រះអង្គ ﷻ បានសន្យាជាមួយព្រះសាស្ដា ﷺ ជាទីស្រឡាញ់របស់ព្រះអង្គ ﷻ នៅក្នុងព្រះគម្ពីរគួរអានស៊ូរ៉ោះត្ទ៍ អាល់-ក្ហ៍ស្វ៉ស្វ៍ អាយ៉ាស់ 85 (28:85) ថា៖

إِنَّ ٱلَّذِي فَرَضَ عَلَيْكَ ٱلْقُرْءَانَ لَرَآدُّكَ إِلَىٰ مَعَادٍ ... ﴿٨٥﴾

*85. ព្រះដែលបានអនុម័តគួរអានឲ្យអ្នក (ដាក់គួរអានឲ្យអ្នកជាព្រះរាជក្រឹត្យ) នឹងនាំអ្នកមកឯកន្លែងវិលត្រឡប់វិញ (គឺស្រុកកំណើត)... ។"*

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺ ព្រមទទួលការប្តេជ្ញាចូលអ៊ីស្លាមរបស់អាប៊ូ ស៊ុហ្វយ៉ាន ?

២. អ្នកណាជួយព្រះសាស្តាﷺវាយទម្លាក់រូបព្រះ ?

៣. ព្រះសាស្តាមូហាំម៉ាដ់ﷺបានធ្វើឲ្យអ្នកស្រុកម៉ាក់កាស៊ូចុះចូលដូចម្តេច ?

៤. អល់ឡោះហ្ទ័عزوجلបានសន្យាអ្វីជាមួយព្រះសាស្តាមូហាំម៉ាដ់ﷺ ?

៥. កាលណាអ៊ីម៉ាំទី ១២ ងើបឡើង ព្រះអង្គصلوات الله عليه والسلامនឹងសូត្រអាយ៉ាស់ 17:81 ។ ចូររកអាយ៉ាស់នេះនៅក្នុងគួរអាន ហើយចូរទន្ទេញអាយ៉ាស់នេះឲ្យចាំរត់មាត់ ។

**មេរៀនទី ៣**

# សមរភូមិហ៊្វូណៃន៍

غَزْوَة حُنَيْن

ដំណឹងស្រុកម៉ាក់កាស់ធ្លាក់បានធ្វើឲ្យមានការភ្ញាក់ផ្អើលខ្លាំង និងបានធ្វើឲ្យប្រជាជាតិជិតខាងជ្រួលច្របល់ ។ ប្រជាជាតិខ្លះដែលរស់នៅជុំវិញម៉ាក់កាស់បានរួមដៃគ្នាដើម្បីច្បាំងព្រះសាស្តាﷺអល់ឡោះហ្វ៎ ។

ព្រមនឹងពេលនោះ ព្រះសាស្តាﷺបានចាកចេញពីម៉ាក់កាស់បន្ទាប់ពីបានស្នាក់ទីនោះ ១៥ ថ្ងៃ ។ ព្រះអង្គﷺបានតែងតាំងអ្នកណៃនាំម្នាក់ដើម្បីបង្ហាត់បង្រៀននិងចង្អុលបង្ហាញមនុស្ស ។ ព្រះអង្គﷺបានប្រគល់ការដឹកនាំនិងការគ្រប់គ្រងស្រុកនិងភារកិច្ចដឹកនាំស៊្វឡាត់នៅឯម៉ាស់ឃ៊ីដ្ ឲ្យទៅមុស្លីមមានសទ្ធាស៊ប់ចិត្តអ្នកម៉ាឌ៉ីណាស់ម្នាក់ ។

ប្រជាជាតិដែលបានត្រៀមខ្លួនច្បាំងព្រះសាស្តាﷺនោះ បានទទួលដំណឹងថាព្រះអង្គﷺចេញពីម៉ាក់កាស់ ។ ដូច្នេះពួកគេបានសម្រេចចាំវាយឆ្មក់បក្សមុស្លីមនៅឯទួលហ៊្វូណៃន៍ ។ ដឹងគោលបំណងប្រជាជាតិទាំងនោះ ព្រះសាស្តាﷺបានលើកទ័ពដែលមានពលមុស្លីម ១២០០០ នាក់ ។

មេដឹកនាំទ័ពបច្ចាមិត្តបានចាត់បញ្ជូនចារបុរស ទៅក្នុងចំណោមពួកមុស្លីមដើម្បីប្រមាណមើលកម្លាំងទ័ពមុស្លីម ។ ពួកចារបុរសបានត្រឡប់មកវិញដោយស្រងាកចិត្តដោយសារកម្លាំងទ័ពមុស្លីម ។ ពេលបានឮដំណឹង ពួកសត្រូវក៏បាក់ទឹកចិត្ត ។ ពួកមេដឹកនាំបច្ចាមិត្តដឹងថាមិនអាចប្រយុទ្ធទល់នឹងទ័ពដ៏ធំរបស់បក្សមុស្លីមឈ្នះទេ ។ ហេតុដូច្នេះ ពួកគេគិតលួចវាយពេលទ័ពមុស្លីមឆ្លងកាត់តាមច្រកភ្នំទៅកាន់ហ៊្វូណៃន៍ ។ សមរភូមិនេះបានប្រព្រឹត្តទៅក្នុងឆ្នាំទី ៨ សករាជហ៊ីជ្រ៉ោះត៍ ។

ពេលមកដល់ច្រកភ្នំ ទ័ពមុស្លីមចាំបាច់ត្រូវដើរតាត់តាមច្រកចង្អៀតនេះដោយក្រុមតូច ។ ម្យ៉ាងទៀត ពួកមុស្លីមអាងលើគ្នាច្រើន បានជាធ្វេសប្រហេសខ្លួន ។

ពេលពួកមុស្លីមចូលទៅក្នុងច្រកភ្នំភ្លាម ពួកសត្រូវវាយលុកភ្លាមមកពីលើភ្នំដោយចោលដុំថ្មនិងបាញ់ព្រួញ ។ បន្ទាប់មក ក្រុមពិសេសចុះតាមជម្រាលភ្នំវាយ

ក្រុមមុស្លីមដោយដារ ។ ការវាយឆ្មក់បានធ្វើឲ្យពួកមុស្លីមបែកជួរនិងបាត់បង់សេចក្តីក្លាហាន ។ មុស្លីមច្រើននាក់បានរត់ចោលសមរភូមិ ថ្វីដ្បិតព្រះសាស្តាﷺបញ្ជាឲ្យបន្តការប្រយុទ្ធ ។

ពួកសត្រូវផ្តោតមុខព្រួញទៅរកព្រះសាស្តាﷺ សង្ឃឹមសម្លាប់ព្រះអង្គﷺ ដើម្បីបញ្ចប់សង្គ្រាមយ៉ាងឆាប់បំផុតពេលនេះ ក្នុងសមរភូមិនេះ ។ លុះយល់ដឹងគោលបំណងពួកសត្រូវ អ៊ីមុាំអាលីصلوات الله عليه والسلامនៅក្បែរព្រះសាស្តាﷺ ពួកខ្មាំងវាយមិនឈ្នះព្រះអង្គصلوات الله عليه والسلامទេព្រោះព្រះអង្គصلوات الله عليه والسلامស្ទាត់ជំនាញចម្បាំង ។

យុទ្ធជនល្បីល្បាញម្នាក់ឈ្មោះ អាប៊ូ យ៉ុនដាល់ (أبو جندل) មកប្រយុទ្ធឲ្យបក្សសត្រូវទល់នឹងអ៊ីមុាំអាលីصلوات الله عليه والسلام តែមិនយូរប៉ុន្មានក៏បានដេកស្លាប់ ។ ពេលនោះ អ៊ីមុាំអាលីصلوات الله عليه والسلامប្រយុទ្ធយ៉ាងសកម្មបំផុត ធ្វើឲ្យពួកសត្រូវខ្លបខ្លាច ។ ព្រះអង្គصلوات الله عليه والسلامបានសម្លាប់បច្ចាមិត្ត ៤០ នាក់មុនឈប់ ។ ពួកមុស្លីមមានសេចក្តីក្លាហានឡើងវិញត្រឡប់ទៅប្រយុទ្ធវិញ ពេលឃើញដូច្នេះ ។ ពួកសត្រូវលែងមានប្រៀបលើក្រុមមុស្លីម យុទ្ធជនមុស្លីមវាយសម្រុកទៅលើខ្មាំងគ្រប់កន្លែង ។ មុនចប់ចម្បាំង យុទ្ធជនបច្ចាមិត្ត ៣០ នាក់ទៀតបានស្លាប់ ។

ពួកឥតសាសនាខ្លះដែលរត់គេចពីសមរភូមិហ៊្វូណៃន៍នោះ បានប្រជុំគ្នាទៅឯអៅត្វាស់ (أَوْطَاس) ដើម្បីប្រមូលគ្នាទៅប្រយុទ្ធម្តងទៀត ។ ព្រះសាស្តាﷺបានបញ្ជូនទ័ពមួយកងធំទៅបង្ក្រាប ។ ទីបំផុត បក្សមុស្លីមឈ្នះចម្បាំង តែមេបញ្ជាការពួកគេបានស្លាប់ ។ ពួកគេចាប់បានឈ្លើយសឹកនិងរបស់យកពីសត្រូវបានច្រើន ។ ក្នុងចំណោមឈ្លើយសឹក មានកូនស្រីរបស់ម្តាយចិញ្ចឹមរបស់ព្រះសាស្តាមូហាំម៉ាដ់ﷺ ឈ្មោះ ហា្លីម៉ាស្ទ សាក់ឌីយ៉ាស្ទ (حليمة السعدية)[1] ។ ព្រះសាស្តាﷺបានទទួលគាត់ដោយសេចក្តីគោរព បានចាត់ចែងសព្វគ្រប់ដើម្បីនឹងឲ្យគាត់អាចវិលត្រឡប់ទៅរកប្រជាជាតិគាត់វិញបានដោយសុវត្ថិភាព ។

នៅក្នុងសមរភូមិហ៊្វូណៃន៍និងសមរភូមិអៅត្វាស់ មុស្លីមច្រើនបានបាត់បង់ជីវិតដោយសារការជ្រួលច្របល់នៅពេលចាប់ផ្តើមប្រយុទ្ធ ។ ថ្វីដ្បិតមានឧបសគ្គនៅពេលដំបូង ក្រុមមុស្លីមបានទទួលជ័យជំនះពីព្រោះក្រុមបច្ចាមិត្តបានបោះបង់សមរភូមិ ចោលឈ្លើសឹក ៦០០០ នាក់ អូដ្ឋ ២៤០០០ ក្បាល ចៀម ៤០០០០

[1] ហា្លីម៉ាស្ទ សាក់ឌីយ៉ាស្ទ (حليمة السعدية) មើលសៀវភៅសិក្សាប្រវត្តិសាស្ត្រ ថ្នាក់ទី ៥ មេរៀនទី ៨ ទំព័រ ៣៤ ។

ក្បាលនិង ៤០០០ វ៉ាគិះហ៍ប្រាក់ (១ វ៉ាគិះហ៍ស្មើនឹងប្រាក់ ២១៣ ក្រាម) ។

អល់ឡោះហ្ជ័ﷻថែងដល់សមរភូមិនេះនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាត់-តៅបាស់ អាយ៉ាស់ 25 (9:25) ថា៖

لَقَدۡ نَصَرَكُمُ ٱللَّهُ فِي مَوَاطِنَ كَثِيرَةٖ وَيَوۡمَ حُنَيۡنٍ إِذۡ أَعۡجَبَتۡكُمۡ كَثۡرَتُكُمۡ فَلَمۡ تُغۡنِ عَنكُمۡ شَيۡـٔٗا وَضَاقَتۡ عَلَيۡكُمُ ٱلۡأَرۡضُ بِمَا رَحُبَتۡ ثُمَّ وَلَّيۡتُم مُّدۡبِرِينَ ٢٥

*25. ពិតណាស់អល់ឡោះបានជួយសង្គ្រោះពួកអ្នកច្រើនកន្លែងរួចមកហើយ និងថ្ងៃហ៊្វូណៃន៍ កាលដែលពួកអ្នកមានមោទនភាពព្រោះមានគ្នាច្រើន តែវា (គឺគ្នាច្រើននោះ) ពុំមានប្រយោជន៍សម្រាប់ពួកអ្នកទេ ។ ផែនដីដែលធំទូលាយទៅជាចង្អៀតសម្រាប់ពួកអ្នក ក្រោយមកពួកអ្នកបានបែរក្រោយរត់ ។*

ព្រះសាស្តាﷺបានចេញបញ្ជា ឲ្យនាំរបស់ទាំងអស់ដែលយកបានពីសត្រូវនោះទៅកាន់កន្លែងមួយហៅថា អាល់-យ៉ាក់រ៉ណាស់ (الجعرانة) លុះព្រះអង្គﷺត្រឡប់មកពីត៏អ៊ីហ្វ (الطائف) វិញ ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីទ័ពមុស្លីមវិះនឹងបរាជ័យនៅឯហ៊្វូណៃន៍ ?

២. ពួកសត្រូវមានយុទ្ធសាស្ត្រអ្វី ?

៣. អ្នកណាធ្វើឲ្យទ័ពមុស្លីមមានជ័យជំនះ ?

៤. ហេតុអ្វីពួកសត្រូវផ្តោតមុខព្រួញទៅរកព្រះសាស្តាមូហាំម៉ាដ ﷺ ?

៥. អល់ឡោះហ្ ﷻ បានជួយក្រុមមុស្លីមដូចម្តេច ថ្ងៃប្រយុទ្ធនៅហ៊្វូណៃន៍នោះ ? ចូរមើល ស៊ូរ៉ោះត៍ អាត់-តៅបាស់ អាយ៉ាស់ 25 (9:25) ដើម្បីរកឃើញចម្លើយ ។

## មេរៀនទី ៤

# សមរភូមិត្ញ៉អ៊ីហ្វ

غَزْوَة الطَّائِف

ត្ញ៉អ៊ីហ្វជាតំបន់មានជីវជាតិនៃដែនដីអារ៉ាប៊ី ស្ថិតនៅប៉ែកខាងត្បូងឆៀងកើតនៃស្រុកម៉ាក់កាស់ ។ ព្រោះតែមានធាតុអាកាសល្អ សម្បូរចម្ការតាលប្រឹក្សនិងច្បារដំណាំ ប្រជាជាតិមួយក្រុមរស់នៅឯស្រុកត្ញ៉អ៊ីហ្វដោយមានជីវភាពប្រសើរ គឺប្រជាជាតិ បានី ស្ញគ៊ីហ្វ (بنو ثقيف) ។ ប្រជាជាតិ បានី ស្ញគ៊ីហ្វ នៅក្នុងចំណោមពួកដែលប្រយុទ្ធទល់អ៊ីស្លាមនៅក្នុងសមរភូមិហ៊្វណៃន៍ ។ បន្ទាប់ពីបានចាញ់សមរភូមិនេះ ពួកគេបានរត់ទៅជ្រកក្នុងបន្ទាយមាំមួយនៅក្នុងស្រុកខ្លួន ។

ដើម្បីបង្ក្រប់ជ័យជំនះ ព្រះសាស្តាﷺបានចាត់បញ្ជូនកងពលទៅតាមប្រជាជាតិ បានី ហាវ៉ាស៊ីន (بنو هوازن) នៅឯអៅត្ញស់ ចំណែកឯព្រះអង្គﷺនាំទ័ពដែលនៅសល់ទៅកាន់ត្ញ៉អ៊ីហ្វ ។

បន្ទាយស្ថិតនៅកន្លែងខ្ពស់ មានជញ្ជាំងមាំ មានឆ្មាំនៅក្នុងប៉មយាមមើលឃើញសព្វបរិវេណក្រៅបន្ទាយ ។ ទ័ពមុស្លីមមិនទាន់ព័ទ្ធបន្ទាយជុំផង យុទ្ធជនមុស្លីមត្រូវសម្លាប់ដោយភ្លៀងគ្រាប់ព្រួញ ។ សាល់ម៉ាន ហ្វារីស៊ី (سَلْمَانَ اَلْفَارِسِيِّ) បានឲ្យយោបល់ព្រះសាស្តាﷺឲ្យវាយលុកសត្រូវដោយចោលដុំថ្មនឹងដង្ហក់ធំ ។

យុទ្ធជនមុស្លីមបានដំឡើងដង្ហក់ ហើយបានចោលដុំថ្មទៅលើប៉មបន្ទាយនិងទៅក្នុងប៉មអស់រយៈពេល ២០ ថ្ងៃ ។ តែពួកសត្រូវនៅតែបាញ់ព្រួញតតបវិញ បណ្តាលឲ្យរបួសយុទ្ធជនមុស្លីម ។

ដើម្បីផ្ចាញ់សត្រូវ ត្រូវវាយលុកពីគ្រប់កន្លែងតែម្តង ។ គេបានសង់យានសឹកពីឈើពាសស្បែកក្រាស់ ។ យុទ្ធជនមានកម្លាំងខ្លាំងជាងគេរុញយាននេះទៅរកបន្ទាយ បុកទម្លុះជញ្ជាំង ។

តែសត្រូវបានចាក់ទឹកដែកមកលើយាននោះបណ្តាលឲ្យឆេះស្បែក ។ លើកនេះពួកមុស្លីមត្រូវសត្រូវបាញ់គ្រាប់ព្រួញស្រោចមកលើ យុទ្ធសាស្ត្រនេះត្រូវបោះបង់ចោល ។

ប្រជាជាតិ បានី ស្ញ្រគ្វីហ្ញ សម្បូរទ្រព្យ មានទាសៈទាសីច្រើន ។ ដើម្បីនឹងដឹងអំពីស្ថានការណ៍នៅក្នុងបន្ទាយនិងស្គាល់កម្លាំងទ័ពសត្រូវ ព្រះសាស្តាﷺបានប្រកាសថាទាសៈទាសីណាដែលចាកចេញពីបន្ទាយ មកនៅក្រោមការការពាររបស់ទ័ពមុស្លីមនឹងត្រូវដោះលែងឲ្យមានសេរីភាព ។ យុទ្ធសាស្ត្រនេះមានប្រសិទ្ធិភាពខ្លះ ទាសៈប្រមាណម្ភៃនាក់បានលួចរត់ចេញពីក្នុងបន្ទាយ មករកក្រុមមុស្លីម ។ ពួកគេបានឲ្យដឹងថាអ្នកនៅក្នុងបន្ទាយគិតតស៊ូទោះជាយ៉ាងណាក៏ដោយ ។ ទោះបីត្រូវឡោមព័ទ្ធមួយឆ្នាំក៏ដោយក៏ពួកគេមិនខ្វះស្បៀងដែរ ។

ព្រះសាស្តាﷺបានសម្រេចថា ការវាយយកបន្ទាយតម្រូវឲ្យមានអំណត់និងសកម្មភាពច្រើន ព្រះអង្គﷺមិនចង់ឲ្យសង្គ្រាមនេះមានរយៈពេលយូរទេ ដោយមានច្រើនមូលហេតុគឺ៖

១. ការឡោមព័ទ្ធបន្ទាយបានធ្វើឲ្យមុស្លីមស្លាប់ ១៣ នាក់ហើយ ។ ព្រះសាស្តាﷺមិនចង់ឲ្យមុស្លីមស្លាប់លើសពីនេះទេ ។

២. ទ័ពមុស្លីមចាប់ផ្ដើមអត់ទ្រាំលែងបានតទៅទៀត ដោយសារតែពុំបានទទួលលទ្ធផល ហើយពួកគេចង់បានចំណែកទ្រព្យដែលយកបានពីសមរភូមិហ្ញុនៃន៍និងសមរភូមិអៅត្វស់ ។

៣. ខែស្វៅវ៉ាល់ជិតដាច់ ខែស្ញុល ក្វក្ទ៍ដ្វាស្ញ៍[2] (គេហាមច្បាំងក្នុងខែនេះ) ជិតមកដល់ ។

៤. រដូវធ្វើពិធីហ្ញាច្ជ៍ក៏ជិតមកដល់ដែរ ព្រះសាស្តាﷺចង់យកឱកាសផ្សាយអ៊ីស្លាមក្នុងរដូវវិសេសវិសាលនេះ ។

ចារទុកក្នុងចិត្តប្រការទាំងអស់នេះ ព្រះសាស្តាﷺបានបោះបង់ការឡោមព័ទ្ធបន្ទាយត្វ៏អ៊ីហ្ញ ហើយបានបន្តដំណើរទៅកាន់អាល់-យ៉ាក្ជ៌រ៉ណាស្ញ៍ជាមួយកងទ័ពដើម្បីចែកទ្រព្យសង្គ្រាម ។

ពេលចែកទ្រព្យ ព្រះសាស្តាﷺបានឲ្យបណ្ដាអ្នកចូលសាសនាថ្មីចំណែកធំជាងគេ ។ ព្រះអង្គﷺឲ្យចំណែកផ្ទាល់ខ្លួនមួយចំនួនធំទៅពួកមេដឹកនាំគូរ៉យ៉ស្ញ៍ ។

[2] មើលសៀវភៅសិក្សាប្រវត្តិសាស្ត្រថ្នាក់ទី ៤ មេរៀនទី ២០ ឈ្មោះខែអ៊ីស្លាម ។

គេហៅបុគ្គលទាំងនេះថា មូអាល់ឡាហ្វាទុល-គូលូប (مألفة القلوب បណ្ដាអ្នកដែលគេយកចិត្តឲ្យចូលសាសនាអ៊ីស្លាម) ។ ទង្វើនេះរបស់ព្រះសាស្ដាﷺបានធ្វើឲ្យអ្នកចូលសាសនាថ្មីៗជំពាក់ចិត្តលើសាសនាអ៊ីស្លាមកាន់តែខ្លាំងឡើង តែធ្វើឲ្យមុស្លីមមុនៗទាស់ចិត្ត ជាពិសេសពួកអាន់ស្វារ ។

ព្រះសាស្ដាﷺដឹងថាពួកអាន់ស្វារអាក់អន់ចិត្ត ព្រះអង្គﷺក៏បានប្រាប់ពួកគេថា៖ "អាន់ស្វារអើយ ហេតុអ្វីអស់លោកតូចចិត្តព្រោះតែខ្ញុំﷺបានឲ្យទ្រព្យបន្តិចរបស់ខ្ញុំﷺទៅពួកគូរ៉យស្ជ៍ដើម្បីនឹងឲ្យពួកគេស្រឡាញ់អ៊ីស្លាម តែខ្ញុំﷺបានឲ្យអ៊ីស្លាមទៅអស់លោក ? អស់លោកមិនសប្បាយចិត្តទេដែលអ្នកដទៃបានអូដ្ឋនិងបានចៀម ចំណែកឯអស់លោកបានព្រះសាស្ដា ? សូមស្បថចំពោះអល់ឡោះហ្ជ៍ﷻ ! បើមនុស្សបែកទៅម្ខាង ពួកអាន់ស្វារបែកទៅម្ខាង ខ្ញុំﷺនឹងទៅតាមពួកអាន់ស្វារ ។" បន្ទាប់មកព្រះអង្គﷺបានសូមព្រះពរអល់ឡោះហ្ជ៍ﷻឲ្យពួកអាន់ស្វារនិងបណ្ដាកូនចៅរបស់ពួកគេ ។ ពាក្យពេជន៍របស់ព្រះសាស្ដាﷺបានធ្វើឲ្យពួកអាន់ស្វារយំព្រោះតែខ្មាសខ្លួនឯង ហើយថា៖ "ព្រះសាស្ដារបស់អល់ឡោះហ្ជ៍ﷻអើយ អស់ទូលបង្គំពេញចិត្តនឹងចំណែករបស់អស់ទូលបង្គំហើយ ។"

ក្នុងពេលដែលទាំងអស់គ្នានៅឯអាល់-យ៉ាក់ រ៉ាណាស់នៅឡើយ ប្រជាជាតិបានី ហ្វាវ៉ាស៊ីនដែលបានសូមចុះចាញ់បក្សមុស្លីមនោះបានសូមជួបព្រះសាស្ដាﷺហើយបានសូមឲ្យព្រះអង្គﷺដោះលែងសាច់ញាតិពួកគេឲ្យមានសេរីភាព ។ ព្រះអង្គﷺក៏បានដោះលែងឈ្លើយសឹកទាំងអស់ដែលជាចំណែករបស់ព្រះអង្គﷺ និងចំណែករបស់សមាជិកបានី ហ្វាស៊ីមដែរ ។ ពេលបានដឹងដំណឹងនេះ មុស្លីមឯទៀតក៏បានធ្វើដូច្នេះដែរ ។ ដូច្នេះ ឈ្លើយសឹក ៦០០០ នាក់ត្រូវបានដោះលែង ។

ថ្ងៃទី ១៨ ខែស្ហ៊ុល ក្វក់ដ្ហាស់ ឆ្នាំទី ៨ សករាជហ្ជ៊ិច្រ៉ោះត៍ ព្រះសាស្ដាﷺបានធ្វើពិធីអ៊ុមរ៉ោះត៍ រួចហើយបានចាកចេញទៅកាន់ម៉ាឌីណាស់បន្ទាប់ពីបានតែងតាំងអ្នកតំណាងនៅម៉ាក់កាស់ ។ ពេលត្រឡប់មកម៉ាឌីណាស់វិញ ព្រះអង្គﷺបានទៅស៊ីវ៉ាស់ផ្នូរមាតាព្រះអង្គﷺនៅឯអាប់វ៉ាអ៍ ។ ព្រះសាស្ដាﷺបានមកដល់ម៉ាឌីណាស់វិញថ្ងៃទី ១ ខែស្ហ៊ុល ហ្ជ៊ិច្ជ៍យ៉ាស់ ក្រោយពីបានអវត្តមាន ៣ ខែ ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ពួកអាន់សោ្ឋរបានត្អូញត្អែររឿងអ្វី ?

២. ព្រះសាស្តាﷺបានបោះបង់ការឡោមព័ទ្ធត៏អ៊ីហ្វពេលណា ?

៣. ហេតុអ្វីព្រះសាស្តាﷺបានដោះលែងអ្នកទោស ដែលជាកម្មសិទ្ធិរបស់ព្រះអង្គﷺនោះ ?

៤. ហេតុអ្វីព្រះអង្គﷺបានឲ្យចំណែកធំជាងគេទៅពួកគូរ៉យស្ញ ?

៥. ហេតុអ្វីព្រះអង្គﷺមិនស្នាក់នៅឯម៉ាក់កាស្ញ ?

**មេរៀនទី ៥**

# សមរភូមិតាប៊ុក

غَزْوَة تَبُوك

អំណាចអ៊ីស្លាមកាន់តែរាតធំឡើងទៅលើដែនដីអារ៉ាប៊ី ធ្វើឲ្យប្រមុខរដ្ឋជិតខាងដែលមិនមែនមុស្លីមនោះបារម្ភ ដូចជាព្រះចៅរ៉ូម គឺស្តេចប៊ីសង់ទីន ជាដើម ។ លុះបានឃើញរដ្ឋបាលម៉ាក់កាស្ងំរលំ ពួកគូរ៉ៃយ៉ស្ងំទៅជាមុស្លីម ព្រះបាទប៊ីសង់ទីនដឹងខ្លួនថាចក្រភពខ្លួនកំពុងតែនៅក្រោមការគំរាម ។ ដូច្នេះ ឆ្នាំទី ៩ សករាជហ៊ីជ្រ៉ោះគ៍ ព្រះបាទចក្រភពរ៉ូមបានសម្រេចចិត្តវាយលុកទៅលើពួកមុស្លីម ដោយមិនឲ្យដឹងខ្លួនមុន ។

ប្រទេសស៊ីរីជាអាណានិគមរបស់ចក្រភពរ៉ូម មាននគរកុងស្តង់ទីណូប្លឺ (Constantinople) ជារាជធានី ។ អ្នកស្រុកកាន់សាសនាគ្រិស្ត ទទួលបញ្ជាមកពីព្រះចៅអធិរាជផ្ទាល់តែម្តង ។ តាមផ្លូវអាល់-ហ៊ីជ្រ៍ (الْحِجْر) ទៅកាន់ស្រុកដ្ងាម៉ាស់ មានបន្ទាយមាំមួយឈ្មោះតាប៊ុក ។ ព្រះចៅរ៉ូមបានចាត់បញ្ជូនទ័ពសេះមួយមានរេហ៍ពល ៤០០០ នាក់ប្រដាប់ក្រោះនិងអាវុធទំនើបៗសម្រាប់ច្បាំងនឹងពួកមុស្លីម ។ ទ័ពរ៉ូម បានមកឈប់នៅឯបន្ទាយនេះចាំទទួលបញ្ជាផ្សេងៗទៀត ។

ពេលត្រឡប់មកកាន់ដែនដីអារ៉ាប៊ីវិញ ក្បួនទូរចរជំនួញបានប្រាប់ដំណឹងព្រះសាស្តាﷺថាពួករ៉ូមបានដាក់ទ័ពនៅឯព្រំដែនប្រទេសស៊ីរី ។ ព្រះសាស្តាﷺដឹងថាត្រូវតែទប់ស្កាត់គំរាមមកលើរដ្ឋអ៊ីស្លាម ។ ព្រះអង្គﷺបានផ្ញើសារទៅម៉ាក់កាស្ងំនិងជុំវិញម៉ាឌីណាស្ងំហៅមុស្លីមប្រយុទ្ធ នៅលើព្រះមាគ៌ាអល់ឡោះហ៍ عز وجل ។ ព្រះអង្គﷺបានសូមឲ្យបណ្តាអ្នកដែលមានទ្រព្យធនជួយផ្គត់ផ្គង់សង្គ្រាមដោយបង់ស្វាកាត់ ។

មុស្លីម ៣០០០០ នាក់បានឆ្លើយតបសេចក្តីអំពាវនាវរបស់ព្រះសាស្តាﷺប្រជុំគ្នាក្បែរម៉ាឌីណាស្ងំ ត្រៀមខ្លួនប្រយុទ្ធជាស្រេច ។ មានទ័ពសេះ ១០០០០ នាក់ផ្សេងទៀតជារេហ៍ពលថ្មើជើង ។ កាលនោះធាតុអាកាសក្តៅណាស់នៅម៉ាឌីណាស្ងំ ។ មានមេដឹកនាំប្រជាជាតិមួយក្រុមជាបុគ្គលមានពុតត្បុត ឈ្មោះ

អុ៊ាប់ឌុលឡោះហ្ ប៊ិន អ៊ូបៃ (عبد الله بن أبي) បានបំបាក់ទឹកចិត្តពួកមុស្លីមដោយរំលឹក
អំពីសេចក្តីខ្លាំងក្លារបស់ទ័ពសត្រូវ និងអំពីការលំបាកក្នុងការធ្វើដំណើរផ្លូវឆ្ងាយទៅ
កាន់តាប៊ុកក្រោមថ្ងៃក្តៅស្ទើរឆេះ ។ បុគ្គលមានពុតត្បុតរូបនេះសង្ឃឹមថាសម្តីខ្លួន
នឹងធ្វើឲ្យសមាជិកប្រជាជាតិខុស្ស៊ំរ៉ូច់របស់ខ្លួនមួយចំនួននឹងផ្លាស់ប្តូរចិត្ត ។

កាលនោះអាយ៉ាស់គួរអានមួយត្រូវបានដាក់មកថាៈ

فَرِحَ ٱلْمُخَلَّفُونَ بِمَقْعَدِهِمْ خِلَٰفَ رَسُولِ ٱللَّهِ وَكَرِهُوٓا۟ أَن يُجَٰهِدُوا۟ بِأَمْوَٰلِهِمْ وَأَنفُسِهِمْ فِى سَبِيلِ ٱللَّهِ وَقَالُوا۟ لَا تَنفِرُوا۟ فِى ٱلْحَرِّ ۗ قُلْ نَارُ جَهَنَّمَ أَشَدُّ حَرًّا ۚ لَّوْ كَانُوا۟ يَفْقَهُونَ ﴿٨١﴾

*81. អ្នកទាំងឡាយដែលគេទុកឲ្យនៅខាងក្រោយសប្បាយចិត្ត ព្រោះបានអង្គុយមួយកន្លែងនៅខាងក្រោយសាស្តាអល់ឡោះហ្ (គឺនៅឯផ្ទះមិនចេញទៅច្បាំងទេ) ។ ពួកគេស្អប់ខ្ពើមការតស៊ូលើមាគ៌ាអល់ឡោះហ្ ដោយលះបង់ទ្រព្យនិងលះបង់ខ្លួន ពួកគេបានថ្លែង[ប្រាប់គ្នីគ្នានិងបណ្តាអ្នកមានសទ្ធា]ថាៈ "ចូរអស់លោកកុំចេញទៅ[ប្រយុទ្ធ]កណ្តាលថ្ងៃក្តៅបែបនេះ ។" ចូរអ្នកថ្លែងថាៈ "ភ្លើងនរកក្តៅជាងនោះទៅទៀត ។" ប្រសិនបើពួកគេយល់ ។* (ស៊ូរ៉ោះត៍ អាត់-តៅបាស់ អាយ៉ាស់ 81 (9:81))

ថ្ងៃទ័ពចេញដំណើរបានមកដល់ ព្រះសាស្តាصلى الله عليه وآله وسلمបានប្រកាសលើកកម្លាំងចិត្តយុទ្ធជន ។ បន្ទាប់មកកងទ័ពបានចាកចេញពីម៉ាឌីណាស់ទៅកាន់តាប៊ុក ។

អាមីរុល-មុមីនីន ព្រះអគ្គប្រមុខរបស់បណ្តាអ្នកមានសទ្ធាជ្រះថ្លា គឺអ៊ីម៉ាំអាលីصلوات الله عليه والسلام តែងតែនៅពីមុខគេជានិច្ចក្នុងសមរភូមិអ៊ីស្លាមទាំងអស់ ។ តែក្នុងសមរភូមិតាប៊ុក ព្រះសាស្តាصلى الله عليه وآله وسلمបានដាក់ព្រះបញ្ជាមិនឲ្យព្រះអង្គصلوات الله عليه والسلامចូលរួមក្នុងសមរភូមិនេះទេ ឲ្យព្រះអង្គصلوات الله عليه والسلامទទួលភារកិច្ចគ្រប់គ្រងម៉ាឌីណាស់ ។ ព្រះសាស្តាصلى الله عليه وآله وسلمដឹងថាតាប៊ុកនៅឆ្ងាយត្រូវដើរផ្លូវយូរ ថានឹងមានចលាចលបង្កដោយពួកប្រឆាំងអ៊ីស្លាមនៅម៉ាឌីណាស់ពេលព្រះអង្គصلوات الله عليه والسلامមិននៅ ។

ថ្វីដ្បិតព្រះអង្គصلى الله عليه وآله وسلمបានតែងតាំង មូហ៊ាំម៉ាដ់ ប៊ិន ម៉ាស់ឡាម៉ាស់ (مُحَمَّد بْنِ مَسْلَمَة) ជាអ្នកតំណាងព្រះអង្គصلى الله عليه وآله وسلمមែន ព្រះអង្គصلى الله عليه وآله وسلمបានឲ្យអ៊ីម៉ាំអាលីصلوات الله عليه والسلامនៅម៉ាឌីណាស់ដែរដើម្បីបង្ក្រាបពួកបង្កចលាចល ។

បនប៉ាយហ្វយដែលប្រុងនឹងបង្កចលាចល ពេលព្រះសាស្តាصلى الله عليه وآله وسلمមិននៅនោះខកចិត្តដោយសារវត្តមានអ៊ីម៉ាំអាលីصلوات الله عليه والسلام ព្រោះព្រះអង្គصلوات الله عليه والسلامប្រុងប្រយ័តជានិច្ច ។

ដើម្បីធ្វើឲ្យអ៊ីម៉ាំអាលី صلوات الله عليه والسلام ចាកចេញពីម៉ាឌីណាស់ ពួកនេះបានសាបព្រោះពាក្យចចាមអារ៉ាមថាព្រះសាស្តា ﷺ មិនពេញចិត្តព្រះអង្គ صلوات الله عليه والسلام ទេ ដូច្នេះឯងបានជាព្រះអង្គ ﷺ ទុកឲ្យអ៊ីម៉ាំអាលី صلوات الله عليه والسلام នៅម៉ាឌីណាស់ ។

ដើម្បីបំភ្លឺរឿងនេះ អ៊ីម៉ាំអាលី صلوات الله عليه والسلام បានទៅតាមព្រះសាស្តា ﷺ បានជួបព្រះអង្គ ﷺ នៅឯកន្លែងមួយហៅថា យូរហ្វ៍ (جُرْف ឬ យ៉ោរ៉ហ្វ៍) ។ លុះព្រះសាស្តា ﷺ បានឮសម្តីដែលបនកំហូចបានសាបព្រោះនៅម៉ាឌីណាស់នោះ ព្រះអង្គ ﷺ បានថ្លែងពាក្យពេជន៍ដែលល្បីជាប់តរៀងមកបញ្ជាក់អំពីខ៊ិលីហ្វាស់របស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ថា៖ "អាលី صلوات الله عليه والسلام អើយ ចូរត្រឡប់ទៅម៉ាឌីណាស់វិញពីព្រោះ ក្រៅពីខ្លួនអ្នក صلوات الله عليه والسلام និងខ្លួនខ្ញុំ ﷺ ផ្ទាល់ ពុំមានអ្នកណាមួយអាចថែរក្សាសេចក្តីថ្លៃថ្នូរនិងស្ថានការណ៍របស់ម៉ាឌីណាស់បានទេ ។ អ្នក صلوات الله عليه والسلام មិនពេញចិត្តទេដែលខ្ញុំ ﷺ ថាទំនាក់ទំនងរវាងអ្នក صلوات الله عليه والسلام និងខ្ញុំ ﷺ ប្រៀបបាននឹងទំនាក់ទំនងរវាងហារូន عليه السلام និងមូសា عليه السلام ខុសគ្នាតែពុំមានព្រះសាស្តាទេអត់ពីខ្ញុំ ﷺ ទៅនោះ[3] ? ដូចហារូន عليه السلام ជាព្រះឧត្តរាធិការី (អ្នកស្នង) ទីមួយរបស់មូសា عليه السلام អ្នក صلوات الله عليه والسلام ក៏នឹងទៅជាព្រះឧត្តរាធិការីរបស់ខ្ញុំ ﷺ ដែរ ហើយនឹងទៅជាខ៊ិលីហ្វក្រោយពីខ្ញុំ ﷺ ។"

ការដើរផ្លូវរបស់ទ័ពមុស្លីមសម្បូរដោយឧបសគ្គនានា ធាតុអាកាសក្តៅដូចនៅក្នុងឡ ។ គ្រាមួយ កងទ័ពអស់ទឹកផឹក តែមានភ្លៀងមួយមេធំដែលធ្វើឲ្យកងទ័ពមានទំនុកចិត្តនិងបន្តដំណើរទៅមុខ ។ ទីបំផុត ទ័ពមុស្លីមក៏បានទៅដល់តាប៊ុក តែទ័ពរ៉ូមបានដកថយអស់ជាមុន ពេលបានដំណឹងថាបក្សមុស្លីមមានកម្លាំងទ័ពសម្បើម ។ ព្រះសាស្តា ﷺ ស្នាក់នៅតាប៊ុក ២០ ថ្ងៃ មិនឃើញបច្ចាមិត្តត្រឡប់មកវិញទេ ព្រះអង្គ ﷺ សម្រេចចិត្តត្រឡប់មកម៉ាឌីណាស់វិញ ។

ដំណើរទៅតាប៊ុកពុំឥតប្រយោជន៍ទេ ព្រោះព្រះសាស្តា ﷺ បានធ្វើឲ្យមេដឹកនាំក្បែរៗនោះមួយចំនួនធំព្រមទទួលអ៊ីស្លាមជាសាសនាខ្លួន ចំណែកឯមេដឹកនាំឯទៀតព្រមបង់ពន្ធឲ្យរដ្ឋអ៊ីស្លាមឯរដ្ឋអ៊ីស្លាមនឹងការពារប្រជារាស្ត្រទាំងនោះ ។ ម្យ៉ាង

---

[3] ដកស្រង់ពី *យ៉ាមិអ៍ អាត់-តៀរមីស៊ី (جامع الترمذي)* https://sunnah.com/urn/736090

حَدَّثَنَا مَحْمُودُ بْنُ غَيْلاَنَ، قَالَ حَدَّثَنَا أَبُو أَحْمَدَ ، قَالَ حَدَّثَنَا شَرِيكٌ، عَنْ عَبْدِ اللَّهِ بْنِ مُحَمَّدِ بْنِ عَقِيلٍ، عَنْ جَابِرِ بْنِ عَبْدِ اللَّهِ، أَنَّ النَّبِيَّ صلى الله عليه وسلم قَالَ لِعَلِيٍّ " **أَنْتَ مِنِّي بِمَنْزِلَةِ هَارُونَ مِنْ مُوسَى إِلاَّ أَنَّهُ لاَ نَبِيَّ بَعْدِي** " . قَالَ أَبُو عِيسَى هَذَا حَدِيثٌ حَسَنٌ غَرِيبٌ مِنْ هَذَا الْوَجْهِ . وَفِي الْبَابِ عَنْ سَعْدٍ وَزَيْدِ بْنِ أَرْقَمَ وَأَبِي هُرَيْرَةَ وَأُمِّ سَلَمَةَ .

ទៀត ពួករូមបានផ្លាស់ប្ដូរគំនិតលែងគិតវាយលុកទៅលើដែនដីមុស្លីមទៀតក្រោយពីបានឃើញឥទ្ធិពលទ័ពមុស្លីម ។

តាមផ្លូវត្រឡប់មកកាន់មាតុភូមិវិញ ព្រះសាស្ដាﷺបានឆ្លងកាត់តាមច្រកភ្នំអ៊ុកូបាស់តាមផ្លូវមួយចង្អៀតពិបាកដើរ មានជម្រាលចោតសងខាង ។ ហ៊្វូស្ទៃហ្វាស់ ប៊ិន យ៉ាម៉ានី (حُذَيْفَةَ بْنِ الْيَمَانِ) និង អុាំម៉ារ ប៊ិន យ៉ាសៀរ (عمَّار بن يَاسِر) ជួយព្រះសាស្ដាﷺដើរឆ្លងផ្លូវដោយសុវត្ថិភាព ។ កាលនោះកំពុងយប់ ស្រាប់តែមានផ្លេកបន្ទោរ ។ នៅក្រោមពន្លឺផ្លេកបន្ទោរនោះ ព្រះសាស្ដាﷺនិងហ៊្វូស្ទៃហ្វាស់បានឃើញមនុស្សមួយក្រុមដែលរង់ចាំច្រានព្រះសាស្ដាﷺទៅឯជម្រាលភ្នំ ។ ពេលដឹងថាគេបានឃើញខ្លួន បនក្បត់ក្រុមនេះបានរត់គេចខ្លួន ។ ថ្វីដ្បិតពួកវាបិទមុខ ព្រះសាស្ដាﷺបានប្រាប់ហ៊្វូស្ទៃហ្វាស់ឲ្យដឹងអត្តសញ្ញាណរបស់ពួកវារាល់គ្នា ហើយព្រះអង្គﷺសូមកុំឲ្យលោកប្រាប់ឲ្យគេដឹងជាដាច់ខាត ។

ព្រះសាស្ដាﷺមិនចង់សងសឹកបុគ្គលទាំងនេះទេ ក្រែងគេចោទព្រះអង្គﷺថា៖ "ពេលនេះមូហាំម៉ាដ់បានអំណាច គេសម្លាប់មិត្តខ្លួនឯងដែលបានការពារគេពីមុននោះ ។" ចាប់ពីពេលនោះតរៀងមក គេស្គាល់ហ៊្វូស្ទៃហ្វាស់ថាជា "អ្នកដឹងអាថិកំបាំងរបស់ព្រះសាស្ដាﷺ" ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីព្រះសាស្តាﷺបានសម្រេចចិត្តលើកទ័ពទៅវាយតាប៊ុក ?

២. ហេតុអ្វីព្រះសាស្តាﷺមិនឲ្យអ៊ីម៉ាំអាលីصلوات الله عليه والسلامទៅជាមួយព្រះអង្គﷺផង ?

៣. ហេតុអ្វីការធ្វើដំណើរនេះមិនឥតប្រយោជន៍ ?

៤. អ្នកណាចង់សម្លាប់ព្រះសាស្តាﷺតាមផ្លូវត្រឡប់មកវិញ ?

៥. តើគេអាចប្រៀបផ្ទឹមព្រះសាស្តាហារូនعليه السلام និងអ៊ីម៉ាំអាលីصلوات الله عليه والسلامបានដូចម្តេច ?

# មេរៀនទី ៦

## ព្រឹត្តិការណ៍មូបាហាឡាស់ - ភាគ ១

الْمُبَاهَلَة

ដើមសម័យអ៊ីស្លាម ណាច្រ៉ន់ (نجران) ជាទីប្រជុំជនមួយដែលសម្បូរអ្នកលះបង់ចោលការធ្វើសក្ការៈរូបចម្លាក់ជាព្រះមកកាន់សាសនាគ្រិស្តវិញ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានផ្ញើសារអញ្ជើញរដ្ឋ និងប្រជាជាតិនានាមកចូលអ៊ីស្លាម ។ សារមួយច្បាប់បានផ្ញើទៅពួកកាន់សាសនាគ្រិស្តនៃតំបន់ណាច្រ៉ន់ ។ ព្រះរាជសារមានសេចក្តីថា៖

"ដោយនូវព្រះនាមព្រះរបស់អ៊ីបរ៉ហ៊ីម របស់អ៊ីសហ្វាក់និងរបស់យ៉ាក់គូប ។

សំបុត្រសរសេរដោយមូហាំម៉ាដ់ﷺ ព្រះសាស្តានិងព្រះសាសនៈទូតរបស់អល់ឡោះហ៍ﷻ ផ្ញើជូនសង្ឃរាជ (أُسْقُف) នៃតំបន់ណាច្រ៉ន់ ។

សូមក្រាបប្រណិប័តន៍ព្រះរបស់អ៊ីបរ៉ហ៊ីម របស់អ៊ីសហ្វាក់និងរបស់យ៉ាក់គូប ។ ខ្ញុំﷺសូមឲ្យអស់លោកធ្វើសក្ការៈអល់ឡោះហ៍ﷻ កុំធ្វើសក្ការៈបណ្តាបាវព្រះអង្គﷻ ។ ខ្ញុំﷺសូមឲ្យអស់លោកដកខ្លួនចេញពីការគោរពបណ្តាបាវរបស់អល់ឡោះហ៍ﷻ មកចុះចូលខ្លួនចំពោះអល់ឡោះហ៍ﷻវិញ ។ បើអស់លោកបដិសេធការស្នើសូមរបស់ខ្ញុំﷺ អស់លោកត្រូវបង់ឃ្យីស្យ៉ាស់ (جِزْيَة ពន្ធ) ឲ្យរដ្ឋអ៊ីស្លាម (រដ្ឋអ៊ីស្លាមនឹងការពារអស់លោកនិងទ្រព្យរបស់អស់លោក) ។ ពុំនោះទេអស់លោកនៅក្នុងគ្រោះថ្នាក់ ។"

ដែលព្រះសាស្តាមូហាំម៉ាដ់ﷺ បានប្រើព្រះនាមព្រះសាស្តាមុនៗعليهم السلامនោះព្រោះព្រះអង្គﷺចង់ឲ្យពួកគ្រិស្តសាសនិកនៃតំបន់ណាច្រ៉ន់ឃើញថា ជំនឿលើព្រះតែមួយគត់ដែលព្រះអង្គﷺផ្សាយនេះ ជាជំនឿតែមួយដែលព្រះសាស្តាមុនៗបានផ្សាយដែរ គឺព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام ព្រះសាស្តាអ៊ីសហ្វាក់عليه السلامនិងព្រះសាស្តាយ៉ាក់គូបعليه السلامដែលព្រះអង្គﷺជឿនោះ ។ គេបានឲ្យដឹងដែរថាព្រះសាស្តាមូហាំម៉ាដ់ﷺបានលើកឡើង នូវអាយ៉ាស់គួរអានខាងក្រោមនេះក្នុងព្រះរាជសារ

ព្រះអង្គﷺ គឺ៖

قُلْ يَـٰٓأَهْلَ ٱلْكِتَـٰبِ تَعَالَوْا۟ إِلَىٰ كَلِمَةٍ سَوَآءٍۭ بَيْنَنَا وَبَيْنَكُمْ أَلَّا نَعْبُدَ إِلَّا ٱللَّهَ وَلَا نُشْرِكَ بِهِۦ شَيْـًٔا وَلَا يَتَّخِذَ
بَعْضُنَا بَعْضًا أَرْبَابًا مِّن دُونِ ٱللَّهِ ۚ فَإِن تَوَلَّوْا۟ فَقُولُوا۟ ٱشْهَدُوا۟ بِأَنَّا مُسْلِمُونَ ﴿٦٤﴾

*64. ចូរអ្នកថ្លែងថា៖ "ជនគម្ពីរអើយ ចូរអស់លោកមករកវាចារួម (គឺតែមួយ) រវាងយើងនិងអស់លោក នោះគឺ៖ យើងនឹងមិនគោរពសក្ការៈអ្វីឡើយក្រៅពីអល់ឡោះហ៍ យើងនឹងមិនផ្គួបផ្គុំ[ហ៊ុនហាយ ដៃគូឬ]អ្វីផ្សេងជាមួយព្រះអង្គជាដាច់ខាត អស់ទាំងយើងនឹងមិនយកម្ចាស់ផ្សេងពីអល់ឡោះហ៍ឡើយ ។" បើពួកគេបែរក្រោយ ចូរពួកអ្នកថ្លែងថា៖ "ចូរអស់លោកជាសាក្សីថាយើងជាអ្នកចុះចូល (គឺជាមុស្លិម អ្នកមានស្វាមីភ័ក្តិ ប្រតិបត្តិតាមព្រះបញ្ញត្តិរបស់អល់ឡោះហ៍) ។"* (ស៊ូរ៉ោះត៍ អាលី អ៊ិមរ៉ន អាយ៉ាស់ 64 (3:64))

ពេល អាប៊ូ ហ៉ារីស្ស៍ សង្ឃរាជរបស់គ្រិស្តសាសនិកនៃតំបន់ណាច្ច៉រ៉ន់ បានទទួលសំបុត្រនេះ គាត់បានអានយ៉ាងយកចិត្តទុកដាក់ ហើយបានចាត់តាំងគណៈកម្មាធិការចម្រុះដោយបុរសអ្នកជំនាញខាងសាសនានិងអ្នកប្រាជ្ញ ដើម្បីពិភាក្សារកដំណោះស្រាយសំណួរនេះ ។

ក្នុងចំណោមពួកគេ បុរសម្នាក់ ដែលមានបទពិសោធន៍និងមានប្រាជ្ញា បានស្នើសូមឲ្យអ្នកតំណាងប្រជារាស្ត្រណាច្ច៉រ៉ន់មួយក្រុមទៅកាន់ម៉ាឌីណាស់ ដើម្បីសិក្សានិងពិនិត្យមើលថាតើព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ﷺជាព្រះសាស្ដាពិតមែនឬទេ ។

គេបានជ្រើសរើសមនុស្ស ៦០ នាក់ដែលមានប្រាជ្ញានិងមានការចេះដឹងដាច់គេនៃតំបន់ណាច្ច៉រ៉ន់ ។ ក្រុមនេះដឹកនាំដោយសង្ឃរាជបីនាក់ រាប់ទាំង អាប៊ូ ហ៉ារីស្ស៍ដែរ ។ ប្រតិភូបានទៅដល់ម៉ាឌីណាស់ បានចូលទៅក្នុងម៉ាស់យ៉ិដ្ឋដោយស្លៀកពាក់សូត្រ ពាក់ចិញ្ចៀនមាសនិងពាក់ខ្សែកឈើឆ្កាង ។ ឃើញពួកគេស្លៀកពាក់បែបនេះ ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ﷺរកាំចិត្ត ហើយក៏មិនអើពើពួកគេទេ ។ ពួកគេដឹងខ្លួនថាមានបញ្ហាតែមិនដឹងថាត្រូវធ្វើអ្វី ។

ធ្វើតាមអ៊ីមុាំអ៊ាលីصلوات الله عليه والسلامប្រាប់ គណៈប្រតិភូណាច្ច៉រ៉ន់បានផ្លាស់សំលៀកបំពាក់មកស្លៀកពាក់សាមញ្ញវិញ ដកគ្រឿងលំអចេញ ។ ពួកគេបានទៅជួបព្រះសាស្ដាﷺជាថ្មី ព្រះសាស្ដាﷺទទួលពួកគេយ៉ាងរាក់ទាក់ ។ មុនចាប់ផ្តើមសន្ទនា ពួកគេសូមអនុញ្ញាតសូត្រមន្ត ព្រះសាស្ដាﷺក៏បានអនុញ្ញាត ។ គេបាននាំពួកគេទៅឯ

ជ្រុងម៉ាស់ឃ្ញីដូមួយដើម្បីសូត្រមន្តដោយសេរី ។ រួចហើយកិច្ចសន្ទនាក៏បានចាប់ផ្តើម ។

**ព្រះសាស្តាមូហាំម៉ាដ់ﷺ** - "ខ្ញុំﷺសូមឲ្យអស់លោកជឿតៅហ៊ីដ្ធ ធ្វើសក្ការៈព្រះឯកអង្គﷻនិងចុះចូលខ្លួនចំពោះព្រះឆន្ទៈរបស់ព្រះឯកអង្គﷻ ។ (រួចហើយព្រះអង្គﷺសូត្រអាយ៉ាស្ទ 64 ក្នុងស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន)"

**សង្ឃរាជ** - "បើអ៊ីស្លាមនិយាយអំពីការជឿព្រះឯកអង្គ នៃភពផែនដែនចក្រវាល យើងជឿព្រះឯកអង្គនោះនិងបានធ្វើតាមព្រះបញ្ញារបស់ព្រះឯកអង្គនោះស្រេចហើយ ។"

**ព្រះសាស្តាមូហាំម៉ាដ់ﷺ** - "អ៊ីស្លាមមានសញ្ញាសម្គាល់ខ្លះ ទង្វើមួយចំនួនរបស់អស់លោកសម្តែងឲ្យឃើញថា អស់លោកមិនបានទទួលយកអ៊ីស្លាមពិតប្រាកដទេ ។ អស់លោកអាចថាធ្វើសក្ការៈព្រះឯកអង្គបានដូចម្តេចបើអស់លោកធ្វើសក្ការៈរូបឈើឆ្កាង បរិភោគសាច់ជ្រូក ជឿថាព្រះមានកូននោះ ?"

**សង្ឃរាជ** - "អ៊ីសាعليه السلامពិតជាព្រះរាជបុត្ររបស់ព្រះមែន ពីព្រោះព្រះមាតារបស់ព្រះអង្គعليه السلامបានឲ្យកំណើតព្រះអង្គعليه السلام ដោយពុំបានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកមួយសោះក្នុងលោកនេះ ។ បិតារបស់ព្រះអង្គعليه السلامពិតជាព្រះនៃភពផែនដែនចក្រវាលមែន ។ យើងជឿដែរថាយេស៊ូ (គឺអ៊ីសាعليه السلام) ជាព្រះព្រោះព្រះអង្គបានធ្វើឲ្យអ្នកស្លាប់រស់វិញ ព្រោះព្រះអង្គបានធ្វើឲ្យមនុស្សឈឺជាវិញ ព្រោះព្រះអង្គបានធ្វើឲ្យសត្វស្លាបដែលធ្វើអំពីដីនោះហើរបាន ។ ទាំងអស់នេះសឲ្យឃើញថាព្រះអង្គជាព្រះ ។"

**ព្រះសាស្តាមូហាំម៉ាដ់ﷺ** - "ទេ ព្រះអង្គជាបាវម្នាក់និងជាសត្វលោកមួយរបស់ព្រះ ។ ព្រះអង្គត្រូវដាក់មកក្នុងពោះព្រះមាតាព្រះអង្គ ព្រះនាងម៉ារយ៉ាំسلام الله عليها ។ អំណាចនិងកម្លាំងពលំទាំងអស់របស់ព្រះអង្គត្រូវព្រះទ្រង់ព្រះរាជទានឲ្យ ។"

ព្រមនឹងពេលនេះ ទេវតាយ៉ីបរ៉អ៊ីលعليه السلامបាននាំអាយ៉ាស់ខាងក្រោមនេះមកឲ្យព្រះអង្គﷺ គឺ៖

إِنَّ مَثَلَ عِيسَىٰ عِندَ ٱللَّهِ كَمَثَلِ ءَادَمَۖ خَلَقَهُۥ مِن تُرَابٍ ثُمَّ قَالَ لَهُۥ كُن فَيَكُونُ ﴿٥٩﴾

*59. សម្រាប់អល់ឡោះហ៍ [ការបង្កើត]អ៊ីសា[ដោយឥតមានឪពុកនោះ]ប្រៀបបាននឹង[ការបង្កើត]អាដាំ[ដែរដោយគ្មានឪពុកគ្មានម្តាយ] ។ ព្រះអង្គបានបង្កើតគេ (គឺអាដាំ) មកពីធូលី បន្ទាប់ពីនោះព្រះអង្គមានព្រះតម្រាស់ចំពោះគេថា៖ "ចូរកើតឡើង ។" គេក៏បានកើតឡើង ។* (ស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន អាយ៉ាស់ 59 (3:59))

"បានសេចក្តីថា ដែលគេអាចហៅអ៊ីសាعليه السلامបានថាជាកូនរបស់ព្រះនោះ ព្រោះតែព្រះអង្គعليه السلامកើតមកដោយពុំមានឪពុក ។ ចំណែកឯអាដាំعليه السلامវិញដែលបានកើតមកដោយពុំមានឪពុកនិងពុំមានម្តាយនោះ ស័ក្តិសមត្រូវហៅព្រះអង្គعليه السلام ថាជាកូនព្រះជាងអ៊ីសាعليه السلامទៅទៀត ។"

ពួកសង្ឃរាជមិនដឹងឆ្លើយតបថាអ្វីទេ តែពួកគេមានះនិយាយប្រឆាំង ។ បន្ទាប់មក អាយ៉ាស់ព្រះគម្ពីរគួរអានខាងក្រោមនេះត្រូវដាក់ចុះមកថា៖

فَمَنْ حَآجَّكَ فِيهِ مِنۢ بَعْدِ مَا جَآءَكَ مِنَ ٱلْعِلْمِ فَقُلْ تَعَالَوْا۟ نَدْعُ أَبْنَآءَنَا وَأَبْنَآءَكُمْ وَنِسَآءَنَا وَنِسَآءَكُمْ وَأَنفُسَنَا وَأَنفُسَكُمْ ثُمَّ نَبْتَهِلْ فَنَجْعَل لَّعْنَتَ ٱللَّهِ عَلَى ٱلْكَٰذِبِينَ ﴿٦١﴾

*61. ដូច្នេះអ្នកណាមួយឈ្លោះប្រកែកជាមួយអ្នកអំពីរឿងនេះ ក្រោយពីព្រះអភិញ្ញាបានមកដល់អ្នកហើយនោះ ចូរអ្នកថា៖ "អស់លោកចូរមកចុះ យើងនឹងហៅកូនប្រុសៗរបស់យើងនិងកូនប្រុសៗរបស់អស់លោក បណ្តាស្ត្រីរបស់យើងនិងបណ្តាស្ត្រីរបស់អស់លោក ខ្លួនយើងផ្ទាល់និងខ្លួនអស់លោកផ្ទាល់ រួចហើយយើងបួងសួងយ៉ាងស្មោះអស់ពីចិត្ត សូមឲ្យព្រះបណ្តាសារបស់អល់ឡោះហ៍ពើបពះលើមុសាវាទី (គឺអ្នកនិយាយកុហក) ។"* (ស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន អាយ៉ាស់ 61 (3:61))

ព្រះសាស្តាមូហាំម៉ាដ់ﷺបានសូត្រអាយ៉ាស់នេះ ឲ្យពួកគ្រិស្តសាសនិកស្តាប់ ហើយបបួលពួកគេធ្វើ "មូបាហាឡាស់" គឺដាក់បណ្តាសាគ្នាទៅវិញទៅមក ។ ពួកគ្រិស្តសាសនិកសូមពេលពិភាក្សាគ្នា ហើយបានប្រាប់ថាពួកគេយល់ព្រមធ្វើតាមការបបួលមុនត្រឡប់ទៅកាន់ជំរំខ្លួនវិញ ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីបានជាព្រះសាស្តាមូហាំម៉ាដ់ﷺសរសេរសំបុត្រ ផ្ញើទៅពួកកាន់សាសនាគ្រិស្ត ?

២. តើពួកកាន់សាសនាគ្រិស្តមានប្រតិកម្មអ្វី ?

៣. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺមិនអើពើពួកកាន់សាសនាគ្រិស្ត កាលព្រះអង្គﷺបានឃើញពួកគេលើកដំបូង ?

៤. ព្រះសាស្តាមូហាំម៉ាដ់ﷺមានសំអាងអ្វី ដើម្បីអធិប្បាយបំភ្លឺថាអ៊ីសាعليه السلامមិនមែនជាកូនព្រះទេនោះ ?

៥. មូបាហាឡាស់ មានន័យថាអ្វី ?

## មេរៀនទី ៧

# ព្រឹត្តិការណ៍មូបាហាឡាស់ - ភាគ ២

الْمُبَاهَلَة

ពេលពួកគ្រិស្តសាសនិកណាច់រ៉ន់ត្រឡប់មកកាន់ជំរំខ្លួនវិញ ដោយបានយល់ព្រមប្រកួតមូបាហាឡាស់ មេដឹកនាំបានប្រាប់ពួកគេថា៖ "ថ្ងៃស្អែក បើមូហាំម៉ាដ់ﷺចេញពីផ្ទះជាមួយសមាជិកគ្រួសារគេﷺ ចូរអស់លោកកុំយល់ព្រមធ្វើមូបាហាឡាស់ជាដាច់ខាត ។ តែបើគេﷺមកជាមួយបក្សពួក ចូរអស់លោកកុំខ្លាច ហើយចូរយល់ព្រមធ្វើមូបាហាឡាស់ចុះ ។"

មេដឹកនាំពួកគ្រិស្តសាសនិកដឹងថា មូបាហាឡាស់ជាការប្រកួតស្លាប់រស់សម្រាប់បក្សទាំងពីរ ដោយជាប់ទាក់ទិននឹងគ្រួសាររៀងៗខ្លួនផង ។ បើព្រះសាស្តាមូហាំម៉ាដ់ﷺសង្ស័យអំពីសេចក្តីពិតរបស់ព្រះរាជសារអ៊ីស្លាម ទោះបីបន្តិចបន្តួចក៏ដោយនោះ ព្រះអង្គﷺប្រាកដជាមិនបបួលពួកគ្រិស្តសាសនិកប្រកួតមូបាហាឡាស់ជាដាច់ខាត ។ ប្រសិនបើព្រះអង្គﷺខ្លាច ទោះបីបន្តិចបន្តួចក៏ដោយថាបណ្តាសានឹងធ្លាក់មកលើព្រះអង្គﷺនិងគ្រួសារព្រះអង្គﷺនោះ ព្រះសាស្តាមូហាំម៉ាដ់ﷺច្បាស់ជាមិនគិតនឹងនាំគ្រួសារព្រះអង្គﷺ ចេញទៅប្រឈមនឹងពួកគ្រិស្តសាសនិកឡើយ ។

បក្សទាំងពីរបានយល់ព្រមប្រកួតគ្នាថ្ងៃបន្ទាប់នៅឯវាល ខាងក្រៅស្រុកម៉ាឌីណាស់ ។ ថ្ងៃទី ២៤ ខែស៊្ហុល ហ៊ីច្ចយ៉្ហាស់ ឆ្នាំទី ៩ សករាជហ៊ីច្ចរ៉ោះត៍ ព្រះសាស្តាមូហាំម៉ាដ់ﷺចេញទៅប្រកួតមូបាហាឡាស់ ។ ព្រះអង្គﷺពអ៊ីមុាំហ៊្វសៃន៍ صلوات الله عليه والسلام ដោយដៃម្ខាង ព្រះអង្គﷺដឹកដៃអ៊ីមុាំហាសាន់ صلوات الله عليه والسلام ដោយដៃម្ខាងទៀត ។ សៃយីដាស់ហ្វាទីម៉ាស់ سلام الله عليها ដើរតាមក្រោយព្រះអង្គﷺ អ៊ីមុាំអាលី صلوات الله عليه والسلام ដើរតាមក្រោយព្រះនាងហ្វាទីម៉ាស់ سلام الله عليها ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានប្រាប់ព្រះអង្គទាំងអស់គ្នា عليهم السلام ថា៖ "ពេលខ្ញុំﷺសូត្រ[ដោយលើកដៃសូមឲ្យអល់ឡោះហ៍ عز وجل ដាក់បណ្តាសាមកលើពួកនិយាយកុហក] ចូរអ្នកទាំងអស់គ្នា عليهم السلام ថា "អាមីន" ។"

អនុវត្តិតាមអាយ៉ាស់មូបាហាឡាស់ ព្រះសាស្តាមូហាំម៉ាដ់ﷺបាននាំមក

បណ្ដា "កូនប្រុស" របស់ព្រះអង្គ صلى الله عليه وآله وسلم គឺអ៊ីម៉ាំហាសាន់ صلوات الله عليه والسلام និងអ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام បណ្ដា "ស្ត្រី" របស់ព្រះអង្គ صلى الله عليه وآله وسلم គឺព្រះនាងហ្វាទីម៉ាស់ سلام الله عليها និង "ខ្លួន" របស់ព្រះអង្គ صلى الله عليه وآله وسلم ផ្ទាល់ គឺអ៊ីម៉ាំអាលី صلوات الله عليه والسلام[4] ។

ពេលបានឃើញវង់មុខដ៏ស្អាតនិងត្រចះត្រចង់ ពួកសង្ឃរាជចាប់ចិត្តក្រៃលែង ។ ពួកគេញ័រខ្លួនរន្ធត់ដោយបានឃើញអំណាចជះចេញមកពីអាស់លុល-បៃត៍ عليهم السلام ។ មេដឹកពួកគេបានសួរបក្សពួកខ្លួនម្នាក់ថា៖ "ពួកគេទាំងនេះជាអ្នកណា ដែលមកជាមួយមូហាំម៉ាដ់ صلى الله عليه وآله وسلم នោះ ?" បុរសនោះបានប្រាប់ឈ្មោះរាល់គ្នានិងទំនាក់ទំនងជាមួយព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ។

មិនអាចអត់ទ្រាំបានយូរតទៅទៀត សង្ឃរាជម្នាក់បានថា៖ "សូមស្បថចំពោះព្រះ ។ នៅពីមុខខ្ញុំ ខ្ញុំឃើញវង់មុខអស្ចារ្យ បើពួកគេសូមឲ្យព្រះធ្វើឲ្យភ្នំដើរបាន ព្រះច្បាស់ជានឹងធ្វើឲ្យភ្នំដើរបានសម្រាប់ពួកគេ ។ ប្រជារាស្ត្រណាច្ច៉រ៉ន់អឺយ បើអស់លោកប្រកួតជាមួយមូហាំម៉ាដ់ صلى الله عليه وآله وسلم ដោយបួងសួងសូមឲ្យបុគ្គលនិយាយកុហកត្រូវបណ្ដាសានោះ ចូរឲ្យខ្ញុំដាស់តឿនអស់លោកថាអស់លោកទាំងអស់គ្នានឹងវិនាស នឹងពុំមានគ្រិស្តសាសនិកណាម្នាក់សេសសល់នៅលើផែនដីឡើយ ។ ខ្ញុំយល់ឃើញថាយកល្អយើងសូមចុះចាញ់ពួកគេនិងស្ដាប់បង្គាប់ពួកគេ ។"

ពេលបានឮសម្ដីនេះ ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "សូមស្បថចំពោះអល់ឡោះហ៍ عز وجل បើពួកគ្រិស្តសាសនិកតំបន់ណាច្ច៉រ៉នហ៊ានប្រកួតនឹងយើង عليهم السلام ពួកគេប្រាកដជាក្លាយទៅសត្វស្វានិងសត្វជ្រូក ។ ភ្លើងនឹងឆេះមកលើពួកគេ ។"

ត្រឡប់មកពីប្រកួតមូបាហាឡាស់វិញ ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ឲ្យពួកសង្ឃរាជជ្រើសរើសយកពីរជម្រើសគឺ៖ ឲ្យពួកគេព្រមចូលសាសនាអ៊ីស្លាម ឬឲ្យពួកគេចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀង ។

ពួកគ្រិស្តសាសនិកមិនព្រមទទួលយកសាសនាអ៊ីស្លាមទេ ដូច្នេះពួកគេបាន

[4] នៅក្នុងអាយ៉ាស់ ពាក្យ "កូនប្រុស" "ស្ត្រី" និង "ខ្លួន" ជាពហុវចនៈ តែព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم មិនបាននាំមកមហេសីណាម្នាក់របស់ព្រះអង្គ صلى الله عليه وآله وسلم ឬសាវកណាម្នាក់របស់ព្រះអង្គ صلى الله عليه وآله وسلم ទេ ដើម្បីបញ្ជាក់ឲ្យឃើញថាមានតែបុគ្គលទាំងនេះ عليهم السلام ទេដែលជាអាស់លុល-បៃត៍ عليهم السلام របស់ព្រះអង្គ صلى الله عليه وآله وسلم ដែលអល់ឡោះហ៍ عز وجل ជម្រះបន្សុទ្ធឲ្យជ្រះស្អាតចាកសេចក្ដីអបរិសុទ្ធនោះ ។

ចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងដោយមានលក្ខខណ្ឌដូចតទៅគឺ៖

១. រៀងរាល់ឆ្នាំ ពួកគ្រិស្តសាសនិកតំបន់ណាជ្រ៉ន់ប្រគល់ឲ្យរដ្ឋបាលអ៊ីស្លាម សំលៀកបំពាក់ចំនួន ២០០០ ។ សំលៀកបំពាក់នីមួយៗមានតម្លៃ ៥០ ដៀរហ្ហាំ ។

២. ពួកគេនឹងជួយជ្រោមជ្រែងដោយឲ្យសេះ ៣០ ក្បាល អូដ្ឋ ៣០ ក្បាល គ្រោះចម្បាំងចំនួន ៣០ គ្រឿងនិងលំពែងចំនួន ៣០ ដែរពេលណាព្រះសាស្តាﷺ ត្រូវការពេលច្បាំង ។

ព្រះសាស្តាមូហ្ហាំម៉ាដ្ឋ៍ﷺ បានប្រាប់ឲ្យអ៊ីមុាំអាលីصلوات الله عليه والسلامសរសេរកិច្ចព្រមព្រៀង ជាលាយលក្ខណ៍អក្សរ បានឲ្យសាវក ៤ នាក់ចុះហត្ថលេខាក្នុងឋានៈជាសាក្សី ។

ក្រៅពីលក្ខខណ្ឌខាងលើនេះ កិច្ចព្រមព្រៀងមានពាក្យពេជន៍ដូចតទៅដែរគឺ៖ "... ប្រជារាស្ត្រតំបន់ណាជ្រ៉ន់នៅក្រោមការថែរក្សារបស់អល់ឡោះហ្ស៍عز وجل និងព្រះសាស្តាﷺ ។ ជីវិតពួកគេ សាសនាពួកគេ ដីធ្លីរបស់ពួកគេនិងទ្រព្យរបស់ពួកគេនឹងមិនត្រូវប៉ះពាល់ទេ អល់ឡោះហ្ស៍عز وجلនិងព្រះសាស្តាﷺជាអ្នកទទួលខុសត្រូវការពារពួកគេ ។ កិច្ចព្រមព្រៀងនេះជាប់ពាក់ព័ន្ធលើប្រជាពលរាស្ត្រតំបន់ណាជ្រ៉ន់ទាំងអស់ ទោះបីអ្នកនោះមានវត្តមានឬអវត្តមានក្តី ទោះបីអ្នកនោះជាសមាជិកនៃប្រជាជាតិណាមួយក្តីឬនៅក្រោមអាណាព្យាបាលប្រជាជាតិណាមួយក្តី ទោះបីអ្នកនោះជាទាសៈទាសីក្តីឬជាបាវបម្រើគេក្តី ។ សិទ្ធិផ្ទាល់ខ្លួននិងឯកសិទ្ធិរបស់ពួកគេនឹងមិនត្រូវផ្លាស់ប្តូរទេ ។ ..."

លក្ខខណ្ឌសំខាន់បំផុតមួយនៅក្នុងកិច្ចព្រមព្រៀងនោះគឺ កុំឲ្យប្រជាពលរាស្ត្រតំបន់ណាជ្រ៉ន់ធ្វើព្រឹទ្ធិកម្ម (ឲ្យខ្ចីដោយយកការប្រាក់) ដោយវិធីណាមួយក៏ដោយ ។ ពុំនោះទេ ព្រះសាស្តាﷺនឹងរំលាយកិច្ចព្រមព្រៀង ។

បន្ទាប់ពីគណៈប្រតិភូសាសនាគ្រិស្តបានវិលត្រឡប់ទៅលំនៅវិញ បុគ្គលមានឋានៈខ្លះនៃតំបន់ណាជ្រ៉ន់ដែលកាន់សាសនាគ្រិស្តនោះ បានមកកាន់ម៉ាឌីណាស្ម័គ្រព្រមចូលសាសនាអ៊ីស្លាមដោយពេញចិត្ត ហើយបានទៅជាមុស្លីម ។

ព្រឹត្តិការណ៍មូបាហ្លាឡាស្ហ៍ ជាប៉ែកមួយដែលសំខាន់បំផុតក្នុងប្រវត្តិសាស្ត្រអ៊ីស្លាមព្រោះវាបង្ហាញឲ្យឃើញថា អាស្ហ៍លុល-បៃត៍عليهم السلامជាសាច់ញាតិជិតស្និទ្ធរបស់ព្រះសាស្តាមូហ្ហាំម៉ាដ្ឋ៍ﷺ និងសឲ្យឃើញថាអាស្ហ៍លុល-បៃត៍عليهم السلامជាបុគ្គលវិសេសវិសាលនិងជាជំនិតរបស់ព្រះអង្គﷺនិងជាជំនិតរបស់អល់ឡោះហ្ស៍عز وجل ។ គេបានដាក់

ឈ្មោះឲ្យអ៊ីម៉ាំអាលីصلوات الله عليه والسلامថា "ណាហ្វ៉ស៍របស់រ៉សូលុលឡោះហ្ស៍صلى الله عليه وآله وسلم" (ណាហ្វ៉ស៍មានន័យថា "វិញ្ញាណ" ឬ "ខ្លួន" ឬ "សាច់") ក្រោយពីព្រឹត្តិការណ៍នេះព្រោះព្រះសាស្តាصلى الله عليه وآله وسلمបាននាំព្រះអង្គصلوات الله عليه والسلامទៅជាន់ដីមូបាហាឡាស់ ក្នុងឋានៈជាតំណាងវិញ្ញាណព្រះអង្គصلى الله عليه وآله وسلم (ឬខ្លួនព្រះអង្គصلى الله عليه وآله وسلم) ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីពួកកាន់សាសនាគ្រិស្តដកខ្លួនចេញពីការប្រកួតមូបាហា្ឡាស់ ?

២. ពួកគ្រិស្តសាសនិកបានទទួលលទ្ធផលអ្វីពេលមកកាន់ម៉ាឌីណាស់នោះ ?

៣. មានលក្ខខណ្ឌសំខាន់មួយប្រការនៅក្នុងកិច្ចព្រមព្រៀង ទាក់ទងនឹងការប្រាក់ ។ លក្ខខណ្ឌនោះមានខ្លឹមសារដូចម្ដេច ?

៤. គេបានលើកឋានៈអ៊ីម៉ាំអាលី صلوات الله عليه والسلام ក្រោយព្រឹត្តិការណ៍នេះ ។ ព្រះអង្គ صلوات الله عليه والسلام មានឋានៈអ្វី ?

៥. យើងអាចដកស្រង់បាននូវមេរៀនអ្វីពីព្រឹត្តិការណ៍មូបាហា្ឡាស់ ?

**មេរៀនទី ៨**

# ផែនការសម្លាប់ព្រះសាស្ដាមូហាំម៉ាដ់ﷺ

ឆ្នាំទី ៩ សករាជហ៊ីច្ជរ៉ោះត៍ ក្នុងរដូវធ្វើពិធីហាច្ជ់ ព្រះសាស្ដាមូហាំម៉ាដ់ﷺបានឲ្យអ៊ីម៉ាំអាលីصلوات الله عليه والسلامធ្វើលិខិតប្រកាសជាផ្លូវការប្រាប់ប្រជារាស្ត្រ ។ ព្រឹត្តិការណ៍នេះបានកើតឡើងនៅឯមីណា លិខិតប្រកាសមានសេចក្ដីថាអល់ឡោះហ៏ﷻនិងព្រះសាស្ដាﷺស្អប់ខ្ពើមការធ្វើសក្ការៈរូបបដិមា មិនអត់ឱនឲ្យធ្វើបែបនេះទៀតទេ ។ គេបានប្រាប់បណ្ដាអ្នកធ្វើសក្ការៈរូបបដិមាថាគេទុកពេលឲ្យ ៤ ខែសម្រាប់គិតថាចូលសាសនាអ៊ីស្លាមឬត្រៀមខ្លួនធ្វើសង្គ្រាម ។

លិខិតនេះបានជះឥទ្ធិពលខ្លាំងនិងរហ័ស ។ ប្រជាជាតិទាំងនោះដែលមានះបន្តធ្វើតាមទម្លាប់អាក្រក់និងកាន់ជំនឿឆ្វេងក៏បានផ្លាស់ប្ដូរគំនិត ។ ប្រជាជាតិច្រើនបានបញ្ជូនអ្នកតំណាងមកសូមចរចាជាមួយព្រះសាស្ដាមូហាំម៉ាដ់ﷺ នៅទីចាត់ការរបស់ព្រះអង្គﷺនៅម៉ាឌីណាស្ហ ។

ពេលកំណត់ ៤ ខែមិនទាន់បានកន្លងផុតផង ដែនដីអារ៉ាប៊ីទាំងមូលបានមកនៅក្រោមទង់អ៊ីស្លាម ពុំមាននៅសេសសល់រូបបដិមាឬអ្នកធ្វើសក្ការៈរូបបដិមាឡើយ ។ ប្រជារាស្ត្រយេមេន ប្រជារាស្ត្របាហ្ររ៉យ៉ន៍ (اَلْبَحْرَيْنَ) និងប្រជារាស្ត្រយ៉ាម៉ាម៉ាស្ហ (اَلْيَمَامَة) បានចូលអ៊ីស្លាមដែរ ។

ថ្វីដ្បិតពុំមានអ្នកណាមួយប្រឆាំងព្រះអាជ្ញាធរព្រះសាស្ដាﷺ ដោយចេញមុខពួកលាក់ពុតត្បុតច្រើនរង់ចាំឱកាសហុចឲ្យ ដើម្បីបៀតបៀនព្រះអង្គﷺនិងអ៊ីស្លាម ។

ពួកមេដឹកនាំប្រជាជាតិ បានី អាមៀរ (بنو عامر) ជាបុគ្គលដែលល្បីខាងមានះនិងខាងបង្កអន្តរាយ ។ មេដឹកនាំប្រជាជាតិនេះពីរនាក់ឈ្មោះអាមៀរ (عامر بن الطفيل) និងអារបាដ់ (أربد بن قيس) បានសម្រេចដឹកនាំប្រតិភូទៅកាន់ម៉ាឌីណាស្ហ ។ ធ្វើពុតថាចង់ចូលអ៊ីស្លាម តែការពិតពួកគេមានបំណងសម្លាប់ព្រះសាស្ដាមូហាំម៉ាដ់ﷺ ។ ផែនការពួកគេគឺ វាយប្រហារព្រះសាស្ដាមូហាំម៉ាដ់ﷺខណៈដែលពួកគេម្នាក់ចរចាជាមួយព្រះអង្គﷺ ។

សមាជិកប្រតិភូឯទៀត ដែលមិនដឹងផែនការអាក្រក់នេះ បានថ្លែងថាខ្លួនជឿអ៊ីស្លាមនិងព្រះសាស្ដាﷺ ។ តែអុាមៀរមិនបានថ្លែងអ្វីសោះអំពីអ៊ីស្លាម គាត់នៅតែសូមនិយាយជាមួយព្រះសាស្ដាមូហុាំម៉ាដ់ﷺដោយផ្ទាល់ខ្លួន ។ ព្រះសាស្ដាមូហុាំម៉ាដ់ﷺបានតបវិញថាមិនអាចជួបគាត់តែម្នាក់ឯងបានទេ ដរាបណាគាត់មិនទាន់បានទៅជាមុស្លីមទេនោះ ។

ពេលអុាមៀរមើលទៅអារបាដ់ដើម្បីសូមជំនួយ គាត់បានឃើញអារបាដ់ស្ងៀមស្ងាត់យ៉ាងចម្លែក ហាក់ដូចជាភ្លេចផែនការអស់ ។ ការពិតគឺពេលអារបាដ់ហូតដាវនោះ គាត់មានអារម្មណ៍ភ័យរន្ធត់ដែលប្រឈមនឹងវត្តមានព្រះសាស្ដាមូហុាំម៉ាដ់ﷺនិងលក្ខណៈបុគ្គលរបស់ព្រះសាស្ដាមូហុាំម៉ាដ់ﷺ ។ គាត់រឹងខ្លួនកម្រើកមិនរួចនៅមួយកន្លែងតែម្ដង ឥតប្រយោជន៍សម្រាប់អុាមៀរ ។

ទីបំផុត មិនសង្ឃឹមបានជំនួយពីអារបាដ់ អុាមៀរស្ទុះក្រោកឈរប្រកាសគំនុំដាក់ព្រះសាស្ដាមូហុាំម៉ាដ់ﷺ គំរាមវាយលុកម៉ាឌីណាស់ដោយកងទ័ពខ្លួន ។ ព្រះសាស្ដាមូហុាំម៉ាដ់ﷺអាចកម្ចាត់បុគ្គលនេះបានបើព្រះអង្គﷺចង់ តែព្រះអង្គﷺបែរជាបួងសួងអល់ឡោះហ៍ﷻវិញសូមឲ្យការពារព្រះអង្គﷺ និងបណ្ដាមុស្លីមពីទង្វើអាក្រក់របស់អុាមៀរ ។ ការបួងសួងនេះបានសម្រេចយ៉ាងឆាប់ៗ អុាមៀរកើតជម្ងឺគួរឲ្យខ្លាចតាមផ្លូវត្រឡប់ទៅលំនៅវិញ ចំណែកឯអារបាដ់ត្រូវផ្លេកបន្ទោរបាញ់ឆេះខ្លួនលុះស្លាប់តាមផ្លូវទៅផ្ទះគាត់ ។

ដូច្នេះ អល់ឡោះហ៍ﷻបានការពារព្រះសាស្ដាមូហុាំម៉ាដ់ﷺពីសត្រូវព្រះអង្គﷺ ហើយបានឲ្យព្រះអង្គﷺទទួលបានលទ្ធផលល្អពីការខិតខំ ក្រោយពីបានផ្សព្វផ្សាយអ៊ីស្លាមអស់ច្រើនឆ្នាំយ៉ាងលំបាក ។ ក្នុងអំឡុងពេលតែ ២០ ឆ្នាំ សាសនាដែលដែនដីអារ៉ាប៊ីទាំងមូលបានប្រទូសប្រឆាំងនោះ ពេលនេះបានក្លាយទៅជាសាសនាផ្លូវការ ។ នេះគឺពេលដែលព្រះសាស្ដាមូហុាំម៉ាដ់ﷺសប្បាយចិត្តជាអតិបរមា ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. គេបានប្រកាសជាលើកចុងក្រោយព្រមានអ្នកស្រុកម៉ាក់កាស៊ូថាអ្វី ?

២. សេចក្ដីប្រកាសនេះមានលទ្ធផលអ្វី ?

៣. ហេតុអ្វីអ៊្ហុយមៀរមិនបានទទួលជំនួយពីមិត្តគាត់ ?

៤. ឃាតករទាំងពីរបានកើតអ្វីតាមផ្លូវត្រឡប់ទៅលំនៅវិញ ?

៥. យើងទទួលបាននូវមេរៀនអ្វីពីព្រឹត្តិការណ៍នេះ ?

## មេរៀនទី ៩

# ពិធីហាជ្ជ៍លាគ្នា

حِجَّةُ الْوَدَاعِ

តាំងពីសម័យព្រះសាស្តាអ៊ីបរ៉ហ៊ីម(ع) បានសាងសង់ព្រះមហាគ្រឹះកាក់បាស់មក ព្រះមហាគ្រឹះកាក់បាស់ជាកន្លែងធ្វើសក្ការៈរហូតតរៀងមក ។ តៗមក ការធ្វើសក្ការៈនេះបានក្លាយទៅមិនសុទ្ធដូចមុន ទាល់តែខូចទៅជាទង្វើចម្លែកនិងមិនគួរឲ្យចង់បាន ។ មនុស្សរាំស្រាតផ្លាំងជុំវិញព្រះមហាគ្រឹះកាក់បាស់ ហើយបានដាក់រូបព្រះនៅក្នុងកាក់បាស់នោះ ។ ក្រោយពីពួកមុស្លីមវាយយកបានម៉ាក់កាស់ ហើយបានវាយកម្ទេចចោលរូបព្រះអស់ហើយក្តី ប្រជារាស្ត្រក៏នៅតែមិនចេះធ្វើពិធីហាជ្ជ៍ត្រឹមត្រូវទេ ។

ដូច្នេះឯង បានជាអល់ឡោះហ្ញ៍(عز وجل)ដាក់ព្រះរាជបញ្ជាឲ្យព្រះសាស្តាមូហាំម៉ាដ្ឋ(ص)ចូលរួមក្នុងពិធីហាជ្ជ៍ដោយខ្លួនផ្ទាល់ក្នុងឆ្នាំទី ១០ សករាជហ៊ិជ្ជរ៉ោះត៍ ដើម្បីនឹងឲ្យប្រជារាស្ត្រលែងនៅក្នុងការសង្ស័យអំពីរបៀបបំពេញពិធីហាជ្ជ៍ទៀត ។ វាជាឱកាសល្អសម្រាប់ព្រះអង្គ(ص)ដែរដើម្បីធ្វើបង្ហាញប្រការចាំបាច់ (វ៉ាឃ៊ីប) និងដើម្បីលះបង់ចោលទង្វើចាស់ដែលមិនត្រូវចង់បាននោះ ។ ព្រះអង្គ(ص)នឹងមានឱកាសប្រាប់ប្រជារាស្ត្រឲ្យស្គាល់ព្រំដែនមីណានិងម៉ារវ៉ាស់ដែរ និងឲ្យពួកគេស្គាល់ពេលដែលត្រូវចាកចេញពីកន្លែងទាំងនេះ ។

ចារគោលដៅទាំងអស់នេះទុកនៅក្នុងអារម្មណ៍ ព្រះសាស្តាមូហាំម៉ាដ្ឋ(ص)ត្រៀមខ្លួនធ្វើដំណើរ ។ ខែទី ១១ នៃប្រក្រតិទិនអ៊ិស្លាម (ស៊ុល កូក៏ដាស់ (ذُو الْقَعْدَة)) ព្រះអង្គ(ص)បានប្រកាសថាព្រះអង្គ(ص)ទៅបំពេញពិធីហាជ្ជ៍ក្នុងឆ្នាំនោះ ។ ដំណឹងនេះបានធ្វើឲ្យមុស្លីមច្រើនមានសេចក្តីរីករាយ ។ មនុស្សច្រើនពាន់នាក់បានប្រជុំគ្នានៅខាងក្រៅនគរម៉ាឌីណាស់រង់ចាំព្រះសាស្តាមូហាំម៉ាដ្ឋ(ص)ចេញដំណើរ ។

ព្រះសាស្តាមូហាំម៉ាដ្ឋ(ص)បានចេញដំណើរទៅកាន់ម៉ាក់កាស់ថ្ងៃទី ២៨ ខែស៊ុល កូក៏ដាស់ ឆ្នាំទី ១០ សករាជហ៊ិជ្ជរ៉ោះត៍ ។ ព្រះអង្គ(ص)យកសត្វសម្រាប់បូជា

ចំនួន ៦០ ក្បាលទៅជាមួយដែរ ។ ដល់ម៉ាស់យ៉ីដ្ន ស្ហាយ៉្ហារ៉ោះត៍ (مَسْجِد اَلشَّجَرَة) ព្រះអង្គﷺគ្រងអ៊ិះហ្រ៉ាម គឺស្លៀកពាក់ដោយសំពត់ពីរបន្ទះសាមញ្ញ ។ ពេលគ្រងអ៊ិះហ្រ៉ាម ព្រះអង្គﷺសូត្រដោយចាប់ផ្តើមថា "ឡាប់បៃក៍ (لَبَّيْكَ)" ដែលជាចម្លើយឆ្លើយតបការហៅរបស់ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام ។ ព្រះអង្គﷺបានធ្វើបែបនេះជាបន្តលុះបានដល់ម៉ាក់កាស់ទើបឈប់សូត្រ ។ នៅឯម៉ាក់កាស់ ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានទៅកាន់ព្រះបូជនីយដ្ឋាន ម៉ាស់យ៉ីឌុល-ហារ៉ម តែម្តងដោយចូលតាមទ្វារបានី ស្ហៃបាស់ ។ នៅទីនេះ ព្រះអង្គﷺបានថ្វាយសេចក្តីគោរពនិងកោតសរសើរដ៏ខ្ពង់ខ្ពស់ចំពោះអល់ឡោះហ៊្ជعزوجلនិងសូមព្រះពរឲ្យព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام ។

ពេលតាវ៉ាហ្វ ព្រះអង្គﷺចាប់ផ្តើមដោយក្រោកឈរទល់មុខថ្មខ្មៅ រួចហើយព្រះអង្គﷺដើរខ្វែលព្រះមហាគ្រឹះកាក់បាស់ ៧ ជុំ ។ បន្ទាប់មក ព្រះអង្គﷺឈរពីក្រោយ ម៉ាកម អ៊ីបរ៉ហ៊ីមعليه السلام ហើយស្ហឡាត់តាវ៉ាហ្វ ២ រ៉ក់អាត់ ។ ក្រោយពីនោះ ព្រះអង្គﷺចាប់ផ្តើមសាអ៊ី (السعي) ពោលគឺ ដើរទៅមករវាងទួលស្ហហ្វានិងម៉ារវ៉ាស់ ៧ ដង ។ ព្រះអង្គﷺបានចាប់ផ្តើមពីទួលស្ហហ្វា ចប់នៅឯទួលម៉ារវ៉ាស់ ។

រួចហើយ ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺបានបែរទៅរកបណ្តាអ្នកបំពេញពិធីហាជ់ មានព្រះវចនៈថា៖ "បណ្តាអ្នកដែលពុំបានយកសត្វបូជាមកទេ ចូរស្រាយអ៊ិះហ្រ៉ាម ហើយធ្វើ តាក់ស្ហៀរ (التقصير) គឺកាត់សក់ឬកាត់ក្រចក ។ ចូរឲ្យជនទាំងនេះចាត់ទុកថាខ្លួនបានធ្វើអ៊ុមរ៉ោះត៍រួចស្រេចហើយដោយបានធ្វើគ្រប់ប្រការខាងលើនេះ រួចហើយចូរឲ្យពួកគេគ្រងអ៊ិះហ្រ៉ាមសម្រាប់បំពេញពិធីហាជ់ ។ តែអ្នកឯទៀត ដូចជាខ្លួនខ្ញុំﷺជាដើមដែលបានយកសត្វមកបូជានោះ ត្រូវទុកអ៊ិះហ្រ៉ាមរហូតដល់បានសំឡែះសត្វរួចនៅមីណា ។"

ព្រមនឹងពេលនោះ អ៊ីម៉ាំអាលីصلوات الله عليه والسلامបានមកឯម៉ាក់កាស់តាមព្រះសាស្តាមូហ៊ាំម៉ាដ់ﷺ ។ ព្រះអង្គصلوات الله عليه والسلامត្រឡប់មកពីយេមេនវិញ ។ ព្រះអង្គصلوات الله عليه والسلامបានចូលមកក្នុងនគរម៉ាក់កាស់ជាមួយយុទ្ធជន ដោយនាំមកនូវសម្លៀកបំពាក់ដែលប្រជារាស្ត្រតំបន់ណាជ់រ៉ាន់ប្រគល់ឲ្យជាសួយសារអាករ ។ ព្រះអង្គصلوات الله عليه والسلامយកសត្វបូជាមកជាមួយដែរ ដូច្នេះព្រះអង្គصلوات الله عليه والسلامទុកអ៊ិះហ្រ៉ាម ។

ធ្វើអ៊ុមរ៉ោះត៍រួច ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺរង់ចាំពេលធ្វើពិធីហាជ់ ។ ព្រះអង្គﷺមិនស្នាក់នៅផ្ទះគេទេនៅឯម៉ាក់កាស់នោះ តែព្រះអង្គﷺបោះជំរំនៅក្រៅស្រុកម៉ាក់កាស់ ។ ថ្ងៃទី ៨ ខែស៊្ហុល ហ៊ីជ្ជយ៉ាស់ ព្រះសាស្តាﷺបានទៅកាន់អារ៉ហ្វាត់កាត់

តាមមីណា ហើយបានឈប់សម្រាកនៅមីណារហូតដល់ថ្ងៃរះនៃថ្ងៃទី ៩ ខែស៊្មុល ហ៊្ចុចយ៉ាស់ ។ បន្ទាប់មកព្រះអង្គﷺជិះអូដ្ឋទៅអារ៉ហ្វាត់ ។ ពេលនៅលើខ្នងអូដ្ឋនៅឡើយ ព្រះអង្គﷺបានឈប់នៅឯកន្លែងមួយដែលគេហៅថា នុមរ៉ោះត៍ (نمرة) ហើយបានថ្លែងសុន្ទរកថាដ៏ល្បីល្បាញពេញប្រវត្តិសាស្រ្ត ឲ្យមនុស្សរាប់ពាន់នាក់ដែលប្រជុំគ្នានៅទីនោះស្តាប់ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានថ្លែងប្រាប់ប្រជារាស្រ្ត ដោយបរិយាយសង្ខេបអំពីសិក្ខាបទរបស់ព្រះអង្គﷺ ។ ព្រះអង្គﷺបានរំលឹកឡើងវិញនូវគោលតូចធំទាំងអស់របស់សាសនាអ៊ីស្លាម ដើម្បីនឹងកុំឲ្យមានសល់ការសង្ស័យនៅក្នុងអារម្មណ៍ប្រជារាស្រ្ត ។ លុះចប់ ព្រះអង្គﷺបានស្វ៊ាឡាត់ពេលស្ហូហ៊្ហូរនិងអាស្វារជាមួយមនុស្ស ១០០ ០០០ នាក់ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបាននៅឯអារ៉ហ្វាត់ថ្ងៃទី ៩ ខែស៊្មុល ហ៊្ចុចយ៉ាស់ រហូតដល់ថ្ងៃលិច មុនយប់ងងឹតព្រះអង្គﷺបានចាកចេញទៅកាន់មុស្ដាលីហ្វាស់ (مُزْدَلِفَة) បានសម្រាកនៅទីនេះមួយប៉ែកនៃយប់ ។ បន្ទាប់មកព្រះអង្គﷺបានទៅឯអាល់-ម៉ាស្អ៊ារ (المشعر الحرام) សម្រាកនៅទីនោះ រវាងមុនថ្ងៃរះនិងពេលថ្ងៃរះ ។

ថ្ងៃទី ១០ ខែស៊្មុល ហ៊្ចុចយ៉ាស់ ព្រះសាស្តាមូហាំម៉ាដ់ﷺបានទៅកាន់មីណា ដើម្បីចោលគោល (رمي الجمرات) សំឡេះសត្វបូជានិងធ្វើតាក់ស្ស៊ៀរ ។ រួចហើយ ព្រះអង្គﷺត្រឡប់ទៅម៉ាក់កាស់វិញ ធ្វើតាវ៉ាហ្វចុងក្រោយ ហើយបង្ហាញប្រជារាស្រ្តធ្វើពិធីបិទពិធីហាច់ ។

គេហៅពិធីហាច់នេះថា ហ៊្ចុចយ៉ាទុល-វ៉ាដាអ៍ ព្រោះវាជាពិធីហាច់ចុងក្រោយបង្អស់ដែលព្រះសាស្តាﷺបានធ្វើ ។ នៅក្នុងពិធីហាច់នេះព្រះអង្គﷺបានអធិប្បាយរៀបរាប់គ្រប់លក្ខណៈរបស់ពិធីហាច់ ដើម្បីនឹងកុំឲ្យមានការភាន់ច្រឡំអំណឺះតទៅ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានត្រៀសត្រាយផ្លូវ សម្រាប់ពេលព្រះអង្គﷺចែកឋានព្រោះព្រះអង្គﷺដឹងថាមិនបានរស់នៅយូរទេក្នុងលោកនេះ បន្តិចទៀតអល់ឡោះហ៍ﷻនឹងហៅព្រះអង្គﷺត្រឡប់វិញ ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីអល់ឡោះហ្ ﷻ បានដាក់ព្រះរាជបញ្ជា ឲ្យព្រះសាស្តាមូហាំម៉ាដ់ ﷺ ធ្វើពិធីហាស្ជ៍ក្នុងឆ្នាំនេះ ?

២. ព្រះអង្គ ﷺ គ្រងអ៊ិះហ្រ៉ាមនៅកន្លែងណា ?

៣. អ៊ីមុាំអាលី صلوات الله عليه والسلام នៅឯណា ?

៤. ព្រះសាស្តាមូហាំម៉ាដ់ ﷺ បានថ្លែងព្រះរាជសារដ៏សំខាន់មួយ ប្រាប់ពួកមុស្លីមនៅឯម៉ាក់កាស្ ព្រះរាជសារនោះមានខ្លឹមសារអ្វី ?

៥. ហេតុអ្វីពិធីហាជ្ជ៍នេះសំខាន់នៅក្នុងប្រវត្តិសាស្ត្រ ?

## មេរៀនទី ១០

# ព្រឹត្តិការណ៍ក៏ដៀរ

واقِعَة اَلْغَدِير

ពេលពិធីហាច់ចប់ ព្រះសាស្តាមូហាំម៉ាដ្ទ ﷺបានចាកចេញពីម៉ាក់កាស់ទៅកាន់ម៉ាឌីណាស់វិញថ្ងៃទី ១៤ ខែស្ស៊ុល ហ៊ីច្ចយ៉ាស់ ។ ពេលព្រះអង្គ ﷺទៅដល់រ៉ាប៊ីក (رابغ) កន្លែងមួយឆ្ងាយពីឃ្ញុះហ៍ហ្វាស់ (الْجُحْفَة) ៣ ម៉ៃល៍ (ប្រមាណ ៥ គីឡូម៉ែត្រ) ទេវតាយ៉ីបរ៉អ៊ីល ﷺបាននាំអាយ៉ាស់នេះមកឲ្យព្រះអង្គ ﷺជ្រាប គឺ៖

﴿يَـٰٓأَيُّهَا ٱلرَّسُولُ بَلِّغۡ مَآ أُنزِلَ إِلَيۡكَ مِن رَّبِّكَۖ وَإِن لَّمۡ تَفۡعَلۡ فَمَا بَلَّغۡتَ رِسَالَتَهُۥۚ وَٱللَّهُ يَعۡصِمُكَ مِنَ ٱلنَّاسِۗ إِنَّ ٱللَّهَ لَا يَهۡدِي ٱلۡقَوۡمَ ٱلۡكَٰفِرِينَ ٦٧﴾

*67. សាស្តាអើយ ចូរអ្នកផ្សព្វផ្សាយអ្វីដែលគេបានបើកឲ្យអ្នកដឹងមកពីព្រះម្ចាស់អ្នក ។ បើអ្នកមិនធ្វើ[ការផ្សព្វផ្សាយនោះ]ទេ [ព្រោះខ្លាចមនុស្សកំណាច វាដូចជា]អ្នកពុំបានផ្សព្វផ្សាយ [ប្រាប់មនុស្សជាតិ] នូវព្រះរាជសាររបស់ព្រះអង្គទេ ។ អល់ឡោះហ៍នឹងការពារអ្នកទល់បណ្តាមនុស្ស ។ ពិតណាស់អល់ឡោះហ៍មិនដឹកនាំ[ដោយបង្ហំ]ជនបដិសេធសទ្ធាទេ ។* (ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស់ អាយ៉ាស់ 67 (5:67))

ដើម្បីធ្វើតាមព្រះរាជបញ្ជាដ៏សំខាន់នេះ ព្រះសាស្តាមូហាំម៉ាដ្ទ ﷺបានឈប់ធ្វើដំណើរភ្លាម ។ ព្រះអង្គ ﷺបានឲ្យគេវាតកន្លែងធ្វើវេទិកាដោយកែបអូដ្ឋ ។ ព្រះអង្គ ﷺបានឲ្យប៊ីឡាល់ ដែលមានសម្លេងខ្លាំងនោះ ប្រកាសហៅត្រឡប់មនុស្សដែលបានទៅមុខហួសនោះ និងឲ្យអ្នកនៅខាងក្រោយចាប់អារម្មណ៍ ។

មនុស្សទាំងអស់បានប្រជុំគ្នានៅឯកន្លែងមួយដែលហៅថា ក៏ដៀរ ឃុម (ត្រពាំងឃុម غَدِير خُم) ។ កាលនោះថ្ងៃត្រង់ ថ្ងៃកំពុងក្តៅខ្លាំង ។ ព្រះសាស្តាមូហាំម៉ាដ្ទ ﷺបាននាំស្វ៍ឡាត់ជុំគ្នារួចហើយបានឡើងលើវេទិកា ដើម្បីនឹងឲ្យគេមើលឃើញព្រះអង្គ ﷺ ។ បន្ទាប់មកព្រះអង្គ ﷺបានសម្តែងធម៌ មានសេចក្តីសង្ខេបដូចតទៅ គឺ៖

"សូមថ្វាយសេចក្តីគោរព សេចក្តីសរសើរទាំងអម្បាលម៉ានចំពោះអល់ឡោះហ៍ ﷻ

ព្រះអ្នកបង្កើត ព្រះម្ចាស់ភពផែនដែនចក្រវាល ។ រាល់គ្នាមានករណីយកិច្ចអរព្រះគុណព្រះអង្គﷻទាំងក្នុងពេលស្រណុក ទាំងក្នុងពេលលំបាក ។ ខ្ញុំﷺសូមអះអាងថាខ្ញុំﷺជាបាវនិងជាសត្វលោកម្នាក់របស់ព្រះអង្គﷻ ខ្ញុំﷺសូមអះអាងថាព្រះអង្គﷻជាព្រះម្ចាស់ﷻនិងព្រះអភិបាលﷻរបស់ខ្ញុំﷺ ។ ខ្ញុំﷺប្រាប់មនុស្សឲ្យដឹងអ្វីៗទាំងអស់ដែលព្រះអង្គﷻបានប្រាប់ឲ្យខ្ញុំﷺដឹងដើម្បីដឹកនាំពួកគេ ។

អល់ឡោះហ្វ៍ﷻបានដាក់ព្រះរាជបញ្ជាឲ្យខ្ញុំﷺប្រាប់អស់លោកថា បន្តិចទៀត គេនឹងនាំខ្លួនខ្ញុំﷺចាកឆ្ងាយពីអស់លោក ។

ប្រជារាស្ត្រអើយ ខ្ញុំﷺសូមទុកកេរមរតកពីរឲ្យអស់លោកគឺ៖ ព្រះគម្ពីរអល់ឡោះហ្វ៍ﷻនិងអាស្ហ៊ុលុល-បៃត៏عليهم السلام បណ្ដាកូនចៅខ្ញុំﷺ ។ ទាំងពីរនេះនឹងមិនបែកគ្នាជាដាច់ខាត លុះត្រាទាំងអស់គ្នានេះនឹងបានមកជួបខ្ញុំﷺវិញឯឋានសួគ៌នាក្បាលទឹក អាល់-កៅស្ហារ ។ ដរាបណាអស់លោកនៅជាប់ជាមួយកេរមរតកទាំងពីររបស់ខ្ញុំﷺនេះ ដរាបនោះអស់លោកនឹងមិនល្អៀងចេញពីផ្លូវល្អជាដាច់ខាត អត់ពីខ្ញុំﷺទៅ ។ ចូរអស់លោកកុំឃើតយ៉ារឆ្ងាយពីក្រោយពួកគេពេក ចូរអស់លោកកុំដើរពីមុខពួកគេ ពីព្រោះក្នុងករណីយទាំងពីរនេះ អស់លោកនឹងលំអៀងចេញពីមាគ៌ាត្រូវ ។ ប្រជារាស្ត្រអើយ អល់ឡោះហ្វ៍ﷻជាម៉ៅឡាﷻ (ព្រះម្ចាស់) របស់ខ្ញុំﷺ ខ្ញុំﷺជាម៉ៅឡា (ម្ចាស់) របស់បណ្ដាអ្នកមានសទ្ធាជ្រះថ្លា ។"

ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺបានសួរបណ្ដាអ្នកស្ដាប់ថា៖ "ប្រជារាស្ត្រអើយ ខ្ញុំﷺមិនមែនម្ចាស់ (ម៉ៅឡា) របស់អស់លោកទេ លើសខ្លួនអស់លោកទៅទៀត ?" ទាំងអស់គ្នាបានតបជាសម្លេងតែមួយថា៖ "មែនហើយ ព្រះសាស្ដារបស់អល់ឡោះហ្វ៍ﷻអើយ ។" ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺបានឱនទៅចាប់ដៃអ៊ីម៉ាំអ្ាលីصلوات الله عليه والسلامលើកឡើងបង្ហាញមហាជនដែលនៅគ្រប់អន្លើនៃវេទីកានោះ ប្រកាសថា៖ "ម៉ាន គុនទូម៉ៅឡាហ៊ូ ហ្វា ហ្ហាស្ហា អ៊ាលីយុន ម៉ៅឡាហ៊ូ (مَنْ كُنْتُ مَوْلَاهُ فَهٰذَا عَلِيٌّ مَوْلَاهُ - ខ្ញុំﷺជាម្ចាស់របស់អ្នកណា អ៊ាលីصلوات الله عليه والسلامក៏ជាម្ចាស់របស់អ្នកនោះដែរ) ។

ពេលថា ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺបានលើកដៃឡើងលើ បួងសួងថា៖ "អល់ឡោះហ្វ៍ﷻអើយ សូមព្រះអង្គﷺទ្រង់សព្វព្រះហឫទ័យអ្នកណាដែលស្រឡាញ់អ៊ាលីصلوات الله عليه والسلام សូមព្រះអង្គﷺស្អប់អ្នកណាដែលមិនគាំទ្រគេصلوات الله عليه والسلام សូមព្រះអង្គﷻចោលអ្នកណាដែលចោលគេصلوات الله عليه والسلام ។"

បន្ទាប់ពីបានថាបីដង ព្រះអង្គﷺចុះពីលើវេទិកា ។ ពេលនោះទេវតា

យ៉ិបរ៉អ៊ីលعليه السلامបាននាំអាយ៉ាស់នេះមកឲ្យព្រះអង្គصلى الله عليه وآله وسلم គឺ៖

ٱلۡيَوۡمَ أَكۡمَلۡتُ لَكُمۡ دِينَكُمۡ وَأَتۡمَمۡتُ عَلَيۡكُمۡ نِعۡمَتِي وَرَضِيتُ لَكُمُ ٱلۡإِسۡلَٰمَ دِينٗاۚ ٣

*3. ថ្ងៃនេះអញបានធ្វើឲ្យសាសនាពួកអ្នកសុក្រឹតឥតខ្ចោះសម្រាប់ពួកអ្នក បានបង្គ្រប់ឧបការធមិអញលើពួកអ្នក ហើយអញបានជ្រើសយកអ៊ីស្លាមជាសាសនាសម្រាប់ពួកអ្នក ។*(ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដ្ហាស់ អាយ៉ាស់ 3 (5:3))

ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានអរព្រះគុណអល់ឡោះហ៍عز وجل ដែលអាណិតស្រឡាញ់ព្រះអង្គصلى الله عليه وآله وسلم ហើយបានឲ្យអ៊ីម៉ាំអាលីصلوات الله عليه والسلامអង្គុយក្នុងជំរំមួយដើម្បីនឹងឲ្យប្រជារាស្ត្រចាប់ដៃព្រះអង្គصلوات الله عليه والسلامនិងអបអរសាទរសរសើរព្រះអង្គصلوات الله عليه والسلام ។

ក្នុងចំណោមមនុស្សដែលបានអបអរសាទរសរសើរអ៊ីម៉ាំអាលីصلوات الله عليه والسلام មុនគេនោះ មាន អាប៊ូ បាការ និង អ៊ុំម៉ារ ។ អ្វីដែលចម្លែកនោះគឺ ទាំងពីរនាក់នេះជាបុគ្គលដំបូងបង្អស់ដែរដែលបានបដិសេធ មិនទទួលស្គាល់សិទ្ធិព្រះអង្គصلوات الله عليه والسلام បន្ទាប់ពីព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានចូលទិវង្គត ។

បន្ទាប់ពីបានបង្គ្រប់កិច្ចទទួលស្គាល់អ៊ីម៉ាំអាលីصلوات الله عليه والسلام ជាអ្នកស្នងព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمរួច ប្រជារាស្ត្រក៏បានត្រឡប់ទៅលំនៅវិញ ។

នៅឯឃ្ញុះហ្វាស់ បណ្តាអ្នកដែលបានមកពីប្រទេសស៊ីរីនិងប្រទេសអេស៊ីបត៍ បានបែកចេញពីក្បួនទូរចរធំ ព្រមទាំងពួកអ្នកយេមេននិងអ្នកហាដ៉្វរ៉ម៉ៅត៍ (حَضْرَمَوْتُ) ដែរ ។ តែមុស្លីមចំនួន ១០ ០០០ នាក់បានហែរអមព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمទៅកាន់ម៉ាឌីណាស់ ហើយទៅដល់មុនដើមឆ្នាំទី ១០ សករាជហ៊ីជ្រ៉ោះត៍បន្តិច ។

ការអធិប្បាយរៀបរាប់លំអិតអំពីថ្ងៃនេះ មានចែងនៅក្នុងតម្រាប្រវត្តិសាស្ត្រអ៊ីស្លាមភាគច្រើន សរសរដោយអ្នកប្រវត្តិសាស្ត្រស៊ុអុស្ន៉ះនិងអ្នកប្រវត្តិសាស្ត្រមិនមែនស៊ុអុស្ន៉ះ ។ ថ្វីដ្បិតពុំមានការសង្ស័យនិងការងឿងឆ្ងល់អំពីការតែងតាំងអ៊ីម៉ាំអាលីصلوات الله عليه والسلامជាអ្នកដឹកនាំមុស្លីមទាំងអស់បន្ទាប់ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم ក្នុងថ្ងៃដ៏សំខាន់បំផុតនេះ មុស្លីមចំនួនច្រើនមិនដឹង មិនស្គាល់ បទបញ្ជានេះទេក្រោយពីព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានសោយព្រះទិវង្គត ។ ក្នុងពេលដែលអ៊ីម៉ាំអាលីصلوات الله عليه والسلامកំពុងតែរវល់ចាត់ចែងការបញ្ចុះព្រះរាជសពរបស់ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم ពួកគេបានជ្រើសរើសយកមេដឹកនាំផ្ទាល់ខ្លួនរបស់ពួកគេ ដែលពុំមានសិទ្ធិនិងពុំមានគុណសម្បត្តិទេក្នុងការដឹកនាំពួកគេនោះ ។

ថ្ងៃ ក៏ខ្ទៀរ ជាព្រឹត្តិការណ៍សំខាន់បំផុតមួយក្នុងប្រវត្តិសាស្ត្រយើង ។ ស្ទ៊ីអ៊ុស្ទ៉ូ ពេញមួយពិភពលោកធ្វើពិធីបុណ្យ អ៊ីដ្ទ អាល់-ក៏ខ្ទៀរ (عِيدَ الْغَدِيرِ) ថ្ងៃទី ១៨ ខែស៊្ទុល ហ៊្ញុច្ចយ៉្ញាស្ទ៉ូ ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីព្រះសាស្ដាមូហាំម៉ាដ់ﷺបានឲ្យបឺឡាល់ប្រកាស ?

២. នៅឯក៊ុំជៀរ គេបានប្រកាសព្រះរាជសាដ៏សំខាន់មួយថាអ្វីខ្លះ ?

៣. ហេតុអ្វីគេមិនដឹងព្រះរាជសារនេះ ?

៤. ព្រះសាស្ដាមូហាំម៉ាដ់ﷺសោយទិវង្គត ក្រោយពីព្រឹត្តិការណ៍នេះអស់រយៈពេលប៉ុណ្ណា ?

៥. ហេតុអ្វី អ៊ីដុ អាល់-ក៊ុំជៀរ សំខាន់សម្រាប់ស៊្វីអុះស៊ូ ?

## មេរៀនទី ១១

# ពេលព្រះសាស្តាមូហាំម៉ាដ់ﷺជិតសោយព្រះទិវង្គត

ព្រះសាស្តាមូហាំម៉ាដ់ﷺត្រឡប់មកពីធ្វើពិធីហាជ្ជ៍ចុងក្រោយវិញ ចុងខែស៊្មុលហ៊ីជ្ជយ៉ាស់ ឆ្នាំទី ១០ សករាជហ៊ីជ្រ៉ោះត៍ ។ បន្ទាប់ពីខែមូហារ៉មបានកន្លងផុត ព្រះអង្គﷺធ្លាក់ខ្លួនឈឺដើមខែស្វហ្វារ ឆ្នាំទី ១១ សករាជហ៊ីជ្រ៉ោះត៍ ។

កាលនោះគេទើបនឹងបានទទួលដំណឹងថា ពួករ៉ូមប៉ែកខាងជើងឆៀងខាងលិចនៃដែនដីអារ៉ាប៊ីប្រុងវាយលុកម៉ាឌីណាស់រដ្ឋធានីអ៊ីស្លាម ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានធ្វើប្រតិកម្មតបតស្ថានការណ៍ប្រកបដោយគ្រោះថ្នាក់នេះ ដោយបញ្ជាឲ្យប្រមូលទ័ពមុស្លីមធំមួយក្រោមបញ្ជាការរបស់ អ៊ូសាម៉ាស់ ប៊ិន ស្សៃដ៍(أسامة بن زيد) ។ ព្រះអង្គﷺដាក់បញ្ជាជាពិសេសឲ្យពួកមូហាជីរីនទាំងអស់ ដែលបានភៀសខ្លួនជាមួយព្រះអង្គﷺមកម៉ាឌីណាស់នោះចូលរួមក្នុងសមរភូមិ លើកលែងតែអ៊ីម៉ាំអាលីصلوات الله عليه والسلام ។ ដើម្បីលើកកម្លាំងចិត្តពួកមុស្លីម ព្រះសាស្តាមូហាំម៉ាដ់ﷺបានចងទង់ឲ្យអ៊ូសាម៉ាស់ដោយដៃព្រះអង្គﷺផ្ទាល់ ប្រាប់លោកថា៖ "ចូរអស់លោកប្រយុទ្ធក្នុងព្រះនាមអល់ឡោះហ្ម៍عز وجلនិងលើព្រះមាគ៌ាព្រះអង្គعز وجل ។ ចូរច្បាំងសត្រូវពេលព្រលឹម ចូរដើរផ្លូវរវាងអស់លោកនិងពួកសត្រូវឲ្យលឿន ដើម្បីនឹងទៅដល់មុនពួកគេដឹងថាអស់លោកបានចេញដំណើរ ។"

អ៊ូសាម៉ាស់ បានបោះជំរំនៅឯយ៉ូរហ្វ៍ ៣ ម៉ៃល៍ (ប្រមាណ ៥ គីឡូម៉ែត្រ) នៅក្រៅម៉ាឌីណាស់ ដើម្បីនឹងឲ្យយុទ្ធជនមុស្លីមអាចប្រជុំគ្នាបាននៅទីនោះមុនចេញដំណើរទៅច្បាំង ។ អ៊ូសាម៉ាស់ជាយុវជនអាយុ ២០ ឆ្នាំ កូនរបស់ស្សៃដ៍ ជាទាសៈដោះលែងឲ្យមានសេរីភាព ។ ពួកម៉ាឌីណាស់តវ៉ាថាមិនចង់តាមមេបញ្ជាការក្មេងពេកទេ ។ ពេលព្រះសាស្តាមូហាំម៉ាដ់ﷺបានដឹងថាពួកមុស្លីមរារែក ព្រះអង្គﷺបានព្រមានពួកគេថាអ្នកណាមិនចូលរួមក្នុងទ័ពអ៊ូសាម៉ាស់ តាមព្រះបញ្ជាព្រះអង្គﷺទេ អ្នកនោះនឹងត្រូវបណ្តាសាអល់ឡោះហ្ម៍عز وجل ។ ទោះជាដូច្នេះក៏ដោយ បណ្តាសាវករបស់ព្រះសាស្តាﷺមិនចេញទៅប្រយុទ្ធទេ ដោយយកលេសថាព្រួយបារម្ភអំពីជម្ងឺព្រះសាស្តាﷺដើម្បីនៅម៉ាឌីណាស់ ។ លុះពេលវេលាបានកន្លងទៅ ជម្ងឺ

ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ មានអាការធ្ងន់ធ្ងរ ។ ទីបំផុត សមរភូមិរបស់អ៊ូសាម៉ាស្ហ៍ក៏មិនមានរូបរាងឡើងឡើយ ។

ការលើកទ័ពទៅច្បាំងប្រទេសស៊ីរីក្រោមបញ្ជាការរបស់អ៊ូសាម៉ាស្ហ៍ បង្ហាញឲ្យដឹងថាព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ បានគិតទុកក្នុងចិត្តពីរប្រការ ។ ប្រការទីមួយ ព្រះអង្គ ﷺ ចង់បង្ហាញមនុស្សឲ្យដឹងថា អាយុមិនសំខាន់ទេក្នុងការចែកភារកិច្ចនិងអំណាច លក្ខខណ្ឌសម្រាប់ដឹកនាំនៅលើលក្ខណៈបុគ្គលនិងសមត្ថភាព ។

អាប៊ូ បាការ និង អ៊ូម៉ារ មិនយកចិត្តទុកដាក់នឹងមេរៀនដ៏មានតម្លៃនេះទេ ច្រើនខែក្រោយមក ពេលពួកគាត់បានបដិសេធ មិនទទួលស្គាល់សិទ្ធិរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ដោយឆ្លើយដោះសាថា ព្រះអង្គ صلوات الله عليه والسلام ក្មេងពេកសម្រាប់ដឹកនាំប្រជារាស្ត្រ ។

ប្រការទីពីរដែលគួរឲ្យចាប់អារម្មណ៍ គឺការរំអុកច្រំដែលរបស់ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ថាឲ្យអ៊ីម៉ាំអាលី صلوات الله عليه والسلام នៅម៉ាឌីណាស្ហ៍ ថាមុស្លីមល្បីៗឯទៀតត្រូវចេញទៅជាមួយអ៊ូសាម៉ាស្ហ៍ ។ ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ បានធ្វើដូច្នេះព្រោះតែព្រះអង្គ ﷺ ចង់ឲ្យពួកដែលសម្បូរពុតត្បុតច្រើនជាងគេនោះនៅឆ្ងាយពីម៉ាឌីណាស្ហ៍ ដើម្បីនឹងឲ្យអ៊ីម៉ាំអាលី صلوات الله عليه والسلام ឡើងកាន់តំណែងខ៊ូលិហ្វដោយគ្មានការជ្រៀតជ្រែក ។

ក៏ប៉ុន្តែ ពួកសម្បូរពុតត្បុតស្គាល់ផែនការព្រះសាស្ដា ﷺ ហើយបានរើសយកអាការអន់ខ្សោយរបស់ព្រះអង្គ ﷺ នោះមកជាលេស ដើម្បីល្មើសព្រះបញ្ជាព្រះអង្គ ﷺ ។ ពួកសម្បូរពុតត្បុតទាំងនេះចង់នៅឯម៉ាឌីណាស្ហ៍ពេលព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ សោយទិវង្គត ដើម្បីនឹងអាចចុះដៃធ្វើផែនការលួចប្លន់តំណែងខ៊ូលីហ្វាស្ហ៍បានពីអ៊ីម៉ាំអាលី صلوات الله عليه والسلام ។

ប្រវត្តិសាស្ត្របានបង្ហាញឲ្យឃើញថា អាប៊ូ បាការ, អ៊ូម៉ារ និងបុគ្គលច្រើននាក់ទៀតបានធ្វើតាមផែនការដែលពួកគេបានគ្រោងទុកនោះ បានសម្រេចដូចបំណង ។ ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ឈឺខ្លាំងកាលព្រះអង្គ ﷺ ស្នាក់នៅឯដំណាក់ព្រះនាង ម៉ៃមូណាស្ហ៍ ព្រះមហេសីព្រះអង្គ ﷺ ។ គេបានសម្រេចគ្នាថាឲ្យព្រះអង្គ ﷺ ស្នាក់នៅឯផ្ទះរបស់មហេសីព្រះអង្គ ﷺ ឈ្មោះអ៊ៃស្ហាស្ហ៍ ដើម្បីគេនឹងអាចមកមើលព្រះអង្គ ﷺ បាន ។ ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ដឹងច្បាស់ថាមនុស្សទាំងនោះកំពុងតែធ្វើផែនការបំបាត់សិទ្ធិអ៊ីម៉ាំអាលី صلوات الله عليه والسلام ។ ពេលជម្ងឺមានអាការធ្ងន់ ព្រះអង្គ ﷺ ដឹងថាមិនមានព្រះជន្មនៅបានយូរទៀតទេ ។ ដូច្នេះ ព្រះអង្គ ﷺ បានឲ្យបណ្ដា

សាវកដែលនៅជុំវិញព្រះអង្គﷺនោះរកក្រដាសនិងប៉ាកកា ដើម្បីព្រះអង្គﷺនឹងប្រាប់ឲ្យសរសេរមរតកសាសន៍ (គឺបណ្តាំ) សម្រាប់ដឹកនាំប្រជារាស្ត្រ ។

អ៊ុំម៉ារ ដែលដឹងថាផែនការខ្លួននឹងបរាជ័យបើព្រះសាស្តាមូហាំម៉ាដ់ﷺបន្សល់ទុកនូវឯកសារជាលាយលក្ខណ៍អក្សរនោះ ក៏បានប្រកែកតវ៉ាថាព្រះសាស្តាﷺបាត់បង់ស្មារតីដោយសារឈឺខ្លាំង ថាព្រះអង្គﷺមិនដឹងខ្លួនថាកំពុងនិយាយអ្វីទេ ។ គាត់បានអះអាងថាព្រះគម្ពីរគួរអានគ្រប់គ្រាន់ណាស់ហើយ មិនចាំបាច់ធ្វើមរតកសាសន៍ទេ (គឺមិនបាច់សរសេរបណ្តាំទុកទេ) ។ បណ្តាសាវកឯទៀតមិនយល់ស្របទេ បណ្តាលឲ្យមានការឈ្លោះប្រកែកគ្នា បង្កសម្លេងឡូឡាខ្លាំង ។ សម្លេងឡូឡាកាន់តែខ្លាំងឡើង ធ្វើឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺរំខាន ហើយក៏ឲ្យពួកគេទាំងអស់គ្នាចេញក្រៅ ។ សំខាន់គឺយើងត្រូវដឹងថាទង្វើតែមួយនេះប្រព្រឹត្តដោយបុគ្គលចង្រៃអ៊ុំម៉ារត្រូវបណ្តាសារូបនេះជាមូលហេតុដែលធ្វើឲ្យមុស្លីមបែកបាក់គ្នា ឥតទីបញ្ចប់ គាត់ជាដើមហេតុធ្វើឲ្យមនុស្សរាប់ពាន់នាក់ស្លាប់ បណ្តាលមកពីការប៉ះទង្គិចគ្នារវាងស្ហ៊ីអ៊ាស្ហ៊ុំនិងសុន្នី (អាស្ហ៊ុលុល-ស៊ុនណាស្ហ៊ុំ) អស់រយៈពេលច្រើនសតវត្សរ៍មកហើយ ។

ពេលព្រះសាស្តាមូហាំម៉ាដ់ﷺជិតអស់ព្រះជន្ម គ្រួសារជាទីស្រឡាញ់របស់ព្រះអង្គﷺនៅជុំវិញព្រះអង្គﷺជានិច្ច ។ សៃយីដ្ហាស្ហ៊ុំហ្វាទីម៉ាស្ហ៊ុំ(سلام الله عليها)មិនអាចអត់ទ្រាំការបាត់បង់ព្រះបិតាﷺជាទីស្រឡាញ់បានទេ ព្រះនាង(سلام الله عليها)យំសស្រាក់ឥតឈប់ ។ ព្រះសាស្តាﷺលោមព្រះនាង(سلام الله عليها)ឲ្យឈប់យំ ព្រះអង្គﷺបានខ្សឹបដាក់ត្រចៀកព្រះនាង(سلام الله عليها) ព្រះនាង(سلام الله عليها)ក៏ឈប់យំបែរជាញញឹមវិញ ។ ក្រោយមក ពេលអ៊ុំស្ហាស្ហ៊ុំសួរព្រះនាង(سلام الله عليها)ថាព្រះសាស្តាﷺបានខ្សឹបថាអ្វីនោះ សៃយីដ្ហាស្ហ៊ុំហ្វាទីម៉ាស្ហ៊ុំ(سلام الله عليها)បានឆ្លើយថាព្រះបិតាﷺព្រះនាង(سلام الله عليها)បានប្រាប់ព្រះនាង(سلام الله عليها)ថា ចូរកុំបារម្ភព្រោះព្រះនាង(سلام الله عليها)ជាបុគ្គលដំបូងបង្អស់ បន្ទាប់ព្រះអង្គﷺ ដែលនឹងចាកចោលលោកនេះទៅជួបជុំព្រះអង្គﷺ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានលាបណ្តាសាវកព្រះអង្គﷺ ព្រះអង្គﷺនៅតែរំលឹកពួកគេឲ្យតាមព្រះគម្ពីរគួរអាន កុំបោះបង់ចោលអាស្ហ៊ុ-លុលបៃត៍(عليهم السلام)ដែលនឹងដឹកនាំពួកគេនៅលើមាគ៌ាត្រូវនៃសីលធម៌និងសច្ចធម៌ ។ បន្ទាប់មកព្រះអង្គﷺហៅចៅទាំងអស់របស់ព្រះអង្គﷺមកឱបរឹតថើប ។ ជោកទឹកភ្នែក ព្រះអង្គﷺថើបអ៊ីម៉ាំហ្សាសាន់លើមាត់ ថើបអ៊ីម៉ាំហ៊្សូសែន៍(صلوات الله عليه والسلام)លើដើមក ។

ពេលគេសួរព្រះអង្គﷺថានេះមានអត្ថន័យអ្វី ព្រះអង្គﷺមានព្រះវចនៈថា ចៅម្នាក់របស់ព្រះអង្គﷺនឹងត្រូវគេសម្លាប់ដោយដាក់ថ្នាំបំពុល ឯចៅម្នាក់ទៀតនឹងត្រូវគេកាត់ក្បាល ។

ពេលអាការជម្ងឺព្រះសាស្តាមូហាំម៉ាដ់ﷺធុនធ្ងរខ្លាំង មនុស្សពេញនគរម៉ាឌីណាស្ងំសោកសៅនិងព្រួយបារម្ភខ្លាំងណាស់ ខ្លាចបាត់បង់ព្រះសាស្តាﷺអល់ឡោះហ្ទ៍عزّ وجلّជាទីស្រឡាញ់ ដែលបានបង្ហាត់បង្រៀនពួកគេឲ្យចេះដឹងសព្វគ្រប់អំពីមាគ៌ាពិតដែលនាំទៅកាន់ការចាកផុតពីគ្រោះ ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីបណ្ដាសាវកល្បីៗមិនតាមអ៊ូសាម៉ាស់ ?

២. ពួកគេឆ្លើយដោះសាខ្លួនថាអ្វី ដើម្បីល្មើសព្រះបញ្ជាព្រះសាស្ដាមូហាំម៉ាដ់ ﷺ ?

៣. ដែលព្រះសាស្ដាមូហាំម៉ាដ់ﷺបានជ្រើសរើសអ៊ូសាម៉ាស់នោះ ព្រោះព្រះអង្គﷺមានព្រះបំណងពីរប្រការ ព្រះអង្គﷺមានព្រះបំណងអ្វី ?

៤. ហេតុអ្វីព្រះសាស្ដាមូហាំម៉ាដ់ﷺបានឲ្យគេរកក្រដាសនិងប៉ាកកា ?

៥. ព្រះសាស្ដាមូហាំម៉ាដ់ﷺសោយទិវង្គតនៅឯផ្ទះអ្នកណា ?

## មេរៀនទី ១២

# ព្រះទិវង្គតនិងកិច្ចបញ្ចុះព្រះរាជសពព្រះសាស្តាមូហាំម៉ាដ់ﷺ

ពេលជិតដាច់ដង្ហើម ព្រះសាស្តាមូហាំម៉ាដ់ﷺបើកភ្នែក ឲ្យគេហៅប្អូនព្រះអង្គ ﷺ ។ អ៊ែស្ហាស់ហៅអាប៊ូ បាការ ឪពុកខ្លួន តែពេលឃើញគាត់ព្រះសាស្តាﷺដាក់ក្បាលលើខ្នើយវិញហើយឲ្យគេហៅប្អូនព្រះអង្គﷺម្តងទៀត ។ ហាហ្វ៉ស្វោះត្ង៍ (حفصة بنت عمر) មហេសីម្នាក់ទៀតរបស់ព្រះសាស្តាﷺ ហៅអ៊ុម៉ារ ឪពុកខ្លួន ។ តែព្រះសាស្តាﷺធ្វើដូចមុនទៀត ។ អ៊ែស្ហាស់ក៏បានឲ្យគេទៅហៅអ៊ីម៉ាំអាលីصلوات الله عليه والسلام ដោយប្រាប់ថាព្រះសាស្តាﷺមិនជួបអ្នកណាផ្សេងទេ ។ ពេលអ៊ីម៉ាំអាលីصلوات الله عليه والسلامមកដល់ ព្រះសាស្តាﷺបានលើកអាវធំគ្របលើព្រះអង្គទាំងពីរعليهما السلام ។ ព្រះសាស្តាﷺ បានដាក់ក្បាលលើទ្រូងអ៊ីម៉ាំអាលីصلوات الله عليه والسلامហើយបាននិយាយគ្នាយូរ ។

នាអវសានកាលនៃព្រះជន្មព្រះអង្គﷺ មានគេគោះទ្វារ ។ សៃយីដ្ហាស់ហ្វាទីម៉ាស់سلام الله عليهاសូមឲ្យអ្នកចង់ជួបនោះត្រឡប់មកវិញពេលក្រោយ ព្រោះព្រះបិតាﷺព្រះនាងسلام الله عليهاកំពុងឈឺខ្លាំង ។ តែគេនៅតែគោះទ្វារច្រំដែល ។ ព្រះនាងسلام الله عليها ហ្វាទីម៉ាស់سلام الله عليهاសូមឲ្យត្រឡប់មកពេលក្រោយម្តងទៀត ។ លើកទីបី ព្រះនាងហ្វាទីម៉ាសسلام الله عليهاស្រក់ទឹកភ្នែក តែព្រះបិតាﷺព្រះនាងسلام الله عليهاប្រាប់ព្រះនាងسلام الله عليهاថា៖ "ហ្វាទីម៉ាស់سلام الله عليهاអើយ ឲ្យគេចូលមក គេមិនមែនអ្នកណាក្រៅពីទេវតាយកព្រលឹងعليه السلامទេ ។ ព្រោះតែគេعليه السلامគោរពកូនسلام الله عليهاបានជាគេعليه السلامគោះទ្វារសូមអនុញ្ញាតចូលនោះ ពុំនោះទេគេعليه السلامប្រាកដជានឹងមិនរង់ចាំទេដើម្បីយកព្រលឹង ។"

ក្រោយពីនោះភ្លាម សញ្ញានៃសេចក្តីស្លាប់បានប្រាកដឡើងលើមុខព្រះអង្គ ﷺ ។ ពាក្យពេជន៍ចុងក្រោយរបស់ព្រះអង្គﷺគឺ៖ "ទេ ។ ជាមួយកនរបស់ព្រះ ។" សឲ្យឃើញថាក្នុងដង្ហើមចុងក្រោយ ទេវតាយ៉ិបរ៉អ៊ីលعليه السلامទុកឲ្យព្រះសាស្តាﷺ រើសយកពីរជម្រើសគឺ៖ ជាសះស្បើយពីជម្ងឺវិញហើយរស់នៅក្នុងលោកនេះ ឬអនុញ្ញាតឲ្យយមទូតعليه السلام (គឺទេវតាយកព្រលឹងعليه السلام) ដកយកព្រះវិញ្ញាណព្រះអង្គ ﷺដើម្បីនឹងឲ្យព្រះអង្គﷺទៅកាន់បរលោកជាមួយយមទូតعليه السلام (គឺកនរបស់ព្រះ) នេះ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានឲ្យចម្លើយ ហើយបានសោយព្រះទិវង្គតក្នុងថ្ងៃ

ចន្រ ទី ២៨ ខែស្វហ្វារ ឆ្នាំទី ១១ សករាជហុិជ្រ៉េះត៍ ។ ព្រះអង្គﷺមានព្រះជន្មាយុ ៦៣ ព្រះវស្សា ។

ពេលសម្លេងព្រះមរណៈទុក្ខ នៅក្នុងព្រះដំណាក់ព្រះសាស្តាមូហាំម៉ាដ់ﷺ បានបន្លឺឡើង ប្រជារាស្ត្រនៅខាងក្រៅបានដឹងភ្លាមថាព្រះសាស្តាមូហាំម៉ាដ់ﷺ បានដាច់ដង្ហើម ។ ក្រោយពីនោះភ្លាម ដំណឹងព្រះទិវង្គតរបស់ព្រះសាស្តាមូហាំម៉ាដ់ ﷺបានលេចឮពេញនគរម៉ាឌីណាស្ទុំ បណ្តាលឲ្យប្រជានុរាស្ត្រទាំងអស់សោកសៅ ។ អ៊ីម៉ាំអាលីصلوات الله عليه والسلامបានផ្ងូតទឹកឲ្យព្រះបូជនីយសពព្រះសាស្តាﷺហើយបានគ្រងសំពត់កាហ្វាន់ឲ្យព្រះបូជនីយសព ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានដាក់ព្រះបង្គាប់ថា ឲ្យបុគ្គលជិតស្និទ្ធបំផុតរបស់ព្រះអង្គﷺជាអ្នកផ្ងូតទឹកឲ្យព្រះរាជសពរបស់ព្រះអង្គﷺ ។ បុគ្គលជិតស្និទ្ធនោះពុំមែនអ្នកណាក្រៅពីអ៊ីម៉ាំអាលីصلوات الله عليه والسلامទេ ។

បុគ្គលមុនគេបង្អស់ ដែលធ្វើពិធីស្វឡាត់ម៉ាយិតឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺគឺ អ៊ីម៉ាំអាលីصلوات الله عليه والسلام ។

បន្ទាប់មក បណ្តាសាវករបស់ព្រះសាស្តាមូហាំម៉ាដ់ﷺបានមកស្វឡាត់ម៉ាយិតជាក្រុមៗ ។ គេបានប្រព្រឹត្តបែបនេះរហូតដល់ថ្ងៃបន្ទាប់ (ថ្ងៃអង្គារពេលថ្ងៃត្រង់) ។ គេបានសម្រេចថានឹងបញ្ចុះព្រះរាជសពព្រះសាស្តាមូហាំម៉ាដ់ﷺនៅក្នុងលំនៅដ្ឋានដែលព្រះអង្គﷺបានអស់ព្រះជន្មនោះតែម្តង ។

នេះគឺព្រឹត្តិការណ៍ខ្លោចផ្សាមួយ ។ វីរបុរសថ្លៃថ្លាបំផុតដែលបានផ្លាស់ប្តូរអនាគតរបស់មនុស្សជាតិដោយការព្យាយាមនិងការលះបង់នោះ បានចែកឋានទៅហើយ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានផ្តល់នូវសុខុមាលភាពមួយប៉ែកធំដល់មនុស្សជាតិទូទៅ ។ ព្រះអង្គﷺបានផ្សព្វផ្សាយព្រះរាជសាររបស់អល់ឡោះហ៍عز وجل ដោយប្រតិបត្តិសាសនាខ្លួនឯងនិងដោយឲ្យអ្នកដទៃតាមព្រះអង្គﷺ ។

ព្រះអង្គﷺបានចាត់ចែងឲ្យមានសិទ្ធិមនុស្ស កាលដែលមនុស្សត្រូវគេរំលោភសិទ្ធិគ្រប់ទីកន្លែង ។ ព្រះអង្គﷺបានសាបព្រោះយុត្តិធមិកាលដែលអំពើសង្កត់

សង្កិនជាធម្មនិយម (គឺជាទង្វើធម្មតា) ។ ព្រះអង្គﷺបានចាត់ចែងឲ្យមានសមភាពសម័យដែលការរើសអើងជាទង្វើទូទៅ ។ ព្រះអង្គﷺបានប្រគល់សេរីភាពឲ្យទៅបណ្តាអ្នកដែលត្រូវគេបំបាត់សេរីភាពដោយអយុត្តិធម៌ ។ ព្រះអង្គﷺបានបំពេញមហាបេសកកម្មដែលអល់ឡោះហ្ទ៏ﷻបានដាក់មកលើព្រះអង្គﷺនោះ ដោយភក្តីភាព ។

ព្រះសាស្តាមូហាំម៉ាដ់ﷺធ្លាប់តែប្រាប់មនុស្សជានិច្ចថា៖ "ខ្ញុំﷺត្រូវចាត់បញ្ជូនមកដើម្បីដុសខាត់ចរិយាមារយាទ (គឺសីលធម៌) អស់លោកឲ្យសុក្រឹតឥតខ្ចោះ[5] ។" ពាក់ព័ន្ធនឹងចរិយាមារយាទ (សីលធម៌) របស់ព្រះសាស្តាមូហាំម៉ាដ់ﷺ ផ្ទាល់ ព្រះគម្ពីរគួរអានបញ្ជាក់ថា៖

وَإِنَّ لَكَ لَأَجۡرًا غَيۡرَ مَمۡنُونٖ ﴿٣﴾ وَإِنَّكَ لَعَلَىٰ خُلُقٍ عَظِيمٖ ﴿٤﴾

*3. ពិតណាស់ អ្នកនឹងបានទទួលនូវរង្វាន់[ដ៏បវរ]ឥតដាច់ ។ 4. ពិតណាស់ អ្នកមានសីលធម៌បវរ ។* (ស៊ូរ៉ោះត៍ អាល់-ក័ឡាំ អាយ៉ាស់ 3-4 (68:3-4))

សូមអល់ឡោះហ្ទ៏ﷻប្រសិទ្ធិពរជ័យ សិរីសួស្តីដល់ព្រះសាស្តាមូហាំម៉ាដ់ អាល់-មុស្ទហ្វ៉ាﷺនិងព្រះរាជបុត្ររាជនត្តាعليهم السلامរបស់ព្រះអង្គﷺ ។

---

[5] . " وَحَدَّثَنِي عَنْ مَالِكٍ، أَنَّهُ قَدْ بَلَغَهُ أَنَّ رَسُولَ اللَّهِ صلى الله عليه وسلم قَالَ " بُعِثْتُ لأُتَمِّمَ حُسْنَ الأَخْلاَقِ " (យ៉ាស្ម៉ាបានប្រាប់ខ្ញុំតមកពីម៉ាលិកថាលោកបានឮព្រះសាស្តាﷺរបស់អល់ឡោះហ្ទ៏ﷻមានព្រះវចនៈថា៖ "ខ្ញុំﷺត្រូវចាត់បញ្ជូនមកដើម្បីធ្វើឲ្យចរិយាមារយាទសុក្រិតឥតខ្ចោះ ។" (ដកស្រង់ពី *មូវ៉ាត្តក្ក ម៉ាលិក (موطأ مالك)* ។"), Muwatta Malik (موطأ مالك), Arabic reference: Book 47, Hadith 1643, USC-MSA web (English) reference: Book 47, Hadith 8

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ព្រះសាស្តាមូហាំម៉ាដ់ﷺទ្រង់ប្រសូតថ្ងៃអ្វី ?

២. ព្រះសាស្តាមូហាំម៉ាដ់ﷺសោយព្រះទិវង្គតថ្ងៃអ្វី ?

៣. ព្រះអង្គﷺប្រសូតនៅឯណា ?

៤. ព្រះរាជសពព្រះអង្គﷺត្រូវបញ្ចុះនៅឯណា ?

៥. ព្រះអង្គﷺមានបុត្រាបុត្រីប៉ុន្មាននាក់ ?

## មេរៀនទី ១៣

# អ៊ីមាំអាលី صلوات الله عليه والسلام - ភាគ ១

| | |
|---|---|
| ឈ្មោះ | : អាលី |
| ឋានៈ | : អាល់-មូរតាដ្ធំ (បុគ្គលដែលអល់ឡោះហ្ន៍ عز وجل ស្រឡាញ់) |
| ឈ្មោះក្រៅ | : អាប៊ុល-ហាសាន់ |
| បិតា | : អាប៊ូ ត៍លិប ប៊ិន អាប់ឌុល-មុត្តត៍លិប |
| មាតា | : សៃយីដ្ធាស់ ហ្វាទីម៉ាស់ ប៊ិនទី អាសាដ្ធ់ |
| កំណើត | : ថ្ងៃទី ១៣ ខែរ៉យ៉ាប់ ២៣ ឆ្នាំមុនសករាជហ៊ីជ្រ៉េះត៍ នៅម៉ាក់កាស់ |
| អ៊ីម៉ាម៉ាស់ | : ពីឆ្នាំទី ១១ សករាជហ៊ីជ្រ៉េះត៍ ដល់ឆ្នាំទី ៤០ សករាជហ៊ីជ្រ៉េះត៍ |
| ទុក្ករកម្ម | : ថ្ងៃទី ២១ ខែរ៉ម៉ាដន ឆ្នាំទី ៤០ សករាជហ៊ីជ្រ៉េះត៍ |
| ទីបញ្ចុះសព | : ណាយ៉ាហ្វា ប្រទេសអ៊ីរ៉ាក់ |

អ៊ីមាំដំបូងបង្អស់ដែលកើតនៅក្នុងព្រះបូជណីយគ្រឹះកាក់បាស់ នៅម៉ាក់កាស់ ឆ្នាំ 600 គ្រិស្តសករាជ ។ កន្លែងប្រសូតរបស់ព្រះអង្គ صلوات الله عليه والسلام សឲ្យឃើញនូវឋានៈព្រះអង្គ صلوات الله عليه والسلام សម្រាប់អល់ឡោះហ្ន៍ عز وجل ពុំដែលមានអ្នកណាប្រសូតនៅក្នុងព្រះបូជណីយគ្រឹះកាក់បាស់ឡើយកាលពីមុនមក ។

មុនព្រះអង្គ صلوات الله عليه والسلام ប្រសូតបន្តិច ព្រះមាតាព្រះអង្គ صلوات الله عليه والسلام សៃយីដ្ធាស់ ហ្វាទីម៉ាស់ ប៊ិនទី អាសាដ្ធ់ មកកាន់ព្រះបូជណីយគ្រឹះកាក់បាស់ ។ ពេលនៅទីនេះ ព្រះនាងឈឺពោះខ្លាំង ហើយក៏អង្គុយបួងសួង ។ ពេលព្រះនាងងើយមុខឡើងវិញ ក៏បានឃើញជញ្ជាំងព្រះមហាគ្រឹះបែកដោយអព្ភូតហេតុអស្ចារ្យ ។ អាប់បាស់ ប៊ិន អាប់ឌុលមុត្តត៍លិបនិងមិត្តលោកខ្លះបានមើលព្រះនាង យ៉ាងស្រឡាំងកាំង ដើរចូលទៅក្នុងព្រះសំណង់នេះៗក៏បានបិទវិញតាមក្រោយព្រះនាង ។ ពេលទ្វារព្រះមហាគ្រឹះបិទ គេពុំអាចចូលទៅក្នុងនោះបានទេ ។ មិនយូរប៉ុន្មានដំណឹងព្រឹត្តិការណ៍អស្ចារ្យនេះបានលេចឮពេញម៉ាក់កាស់ ។

ព្រះនាងហ្វាទីម៉ាស់ ប៊ិនទី អាសាដ្ធ់បាននៅក្នុងព្រះមហាគ្រឹះកាក់បាស់បីថ្ងៃ

ថ្ងៃទីបួនព្រះនាងចេញមកវិញដោយបីទារកទើបនឹងកើតក្នុងដៃ ។ ទារកបិទភ្នែកជិតចាប់តាំងពីកើតមកទារកនេះមិនបើកភ្នែកទេ ។ ពេលចេញពីក្នុងព្រះមហាគ្រឹះកាក់បាស្ហ៍ ព្រះនាងឃើញព្រះសាស្តាមូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلمរង់ចាំទទួលទារកដោយបារម្ភ ។ ព្រះអង្គصلى الله عليه وآله وسلمដឹងថាទារកនេះនឹងធំឡើងដើម្បីពង្រឹងសាសនាអ៊ីស្លាម នឹងជាដៃស្តាំរបស់ព្រះអង្គصلى الله عليه وآله وسلمក្នុងមហាបេសកកម្មដែលព្រះអង្គصلى الله عليه وآله وسلمត្រូវបំពេញនោះ ។ ពេលមកនៅក្នុងដៃព្រះសាស្តាមូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلم ទើបព្រះសន្តអ៊ីមុាំصلوات الله عليه والسلامបើកភ្នែកជាលើកដំបូងមើលព្រះបូជណីយភ័ក្ត្រព្រះសាស្តាមូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلم ។

សម័យនោះ ព្រះសាស្តាមូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلمទើបនឹងបានបាត់បង់កូនប្រុសបង្កើត ។ ដូច្នេះ ព្រះអង្គصلى الله عليه وآله وسلمអាណិតស្រឡាញ់បងប្អូនជីតាមួយថ្មីនេះណាស់ បានចិញ្ចឹមទារកនេះដោយសេចក្តីស្រឡាញ់ ។

នៅក្នុងសាត្រា ណាស្ហ៍ឃ្វុល-បាឡាកោះគ៍ (نهج البلاغة) ព្រះសន្តអ៊ីមុាំصلوات الله عليه والسلامមានវចនៈថា៖ "ព្រះសាស្តាصلى الله عليه وآله وسلمបានចិញ្ចឹមខ្ញុំصلوات الله عليه والسلامដោយដៃព្រះអង្គصلى الله عليه وآله وسلمផ្ទាល់ ។ ព្រះអង្គصلى الله عليه وآله وسلمទំពារបាយបញ្ចុកខ្ញុំصلوات الله عليه والسلام ។ ព្រះអង្គصلى الله عليه وآله وسلمទៅណាខ្ញុំصلوات الله عليه والسلامទៅតាមព្រះអង្គصلى الله عليه وآله وسلم ដូចកូនអូដ្ឋដើរតាមមេវា ។ រៀងរាល់ថ្ងៃខ្ញុំصلوات الله عليه والسلامស្គាល់ចរិយាមារយាទ (សីលធម៌) ថ្មីមួយរបស់ព្រះអង្គصلى الله عليه وآله وسلم ខ្ញុំصلوات الله عليه والسلامទទួលយកចរិយាមារយាទនោះនិងអនុវត្តិតាមចរិយាមារយាទនោះដូចបទបញ្ជា ។"

ព្រះអង្គصلوات الله عليه والسلامបានធាត់ធំក្នុងការថែរក្សារបស់ព្រះសាស្តាមូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلم ព្រះសន្តអ៊ីមុាំصلوات الله عليه والسلامមានចរិយាមារយាទ (សីលធម៌) មានចំណេះ មានស្មារតីលះបង់ មានអំណត់ មានសេចក្តីក្លាហាន មានចិត្តទូលាយនិងមានវោហារកោសល្យដូចព្រះសាស្តាصلى الله عليه وآله وسلمដែរ ។ តាំងពីនៅក្មេងវ័យម្ល៉េះ ព្រះអង្គصلوات الله عليه والسلامក្រាបប្រណិប័តន៍អល់ឡោះហ្វ៍عز وجلជាមួយព្រះសាស្តាមូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلم ពេលអល់ឡោះហ្វ៍عز وجلឲ្យព្រះសាស្តាصلى الله عليه وآله وسلمប្រកាសព្រះរាជសារ ព្រះអង្គصلوات الله عليه والسلامជាបុរសដំបូងបង្អស់ដែលទៅជាមុស្លីម ។

ក្រោយពីព្រះសាស្តាមូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلم បានប្រកាសព្រះរាជសាររបស់អល់ឡោះហ្វ៍عز وجل ព្រះសន្តអ៊ីមុាំصلوات الله عليه والسلامត្រៀមខ្លួនជាស្រេចដើម្បីបម្រើព្រះសាស្តាصلى الله عليه وآله وسلمនិង

ការពារព្រះអង្គ صلى الله عليه وآله وسلم ពីសត្រូវ ។ ព្រះអង្គ صلوات الله عليه والسلام ធ្លាប់តែកត់ត្រាព្រះរាជបន្ទូលរបស់អល់ឡោះហ្វ៍ عز وجل ក្នុងព្រះគម្ពីរគួរអាន (អាយ៉ាស់) និងពិភាក្សាជាមួយព្រះសាស្ដា صلى الله عليه وآله وسلم អំពីអាយ៉ាស់នោះ រាល់ពេលដែលអល់ឡោះហ្វ៍ عز وجل បើកឲ្យដឹងព្រះរាជបន្ទូលព្រះអង្គ عز وجل ។ ព្រះអង្គ صلوات الله عليه والسلام មានភក្ដីភាពឥតឧបមារហូតដល់ថ្ងៃព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم សោយព្រះទិវង្គតឆ្នាំទី ១១ សករាជហ៊ីជ្រ៉េាះត៍ ។ ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈអំពីព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ថា៖

"អាុលី صلوات الله عليه والسلام អឺយ អ្នក صلوات الله عليه والسلام ជាបងប្អូនខ្ញុំ صلى الله عليه وآله وسلم ក្នុងលោកនិងក្នុងលោកមុខ ។"

"ខ្ញុំ صلى الله عليه وآله وسلم ជានគរនៃអភិញ្ញា អាុលី صلوات الله عليه والسلام ជាទ្វារនៃនគរនេះ ។"

"ពុំមានអ្នកណាស្គាល់អល់ឡោះហ្វ៍ عز وجل ទេ ក្រៅពីខ្ញុំ صلى الله عليه وآله وسلم និងអាុលី صلوات الله عليه والسلام ។ ពុំមានអ្នកណាស្គាល់អាុលី صلوات الله عليه والسلام ទេ ក្រៅអល់ឡោះហ្វ៍ عز وجل និងខ្ញុំ صلى الله عليه وآله وسلم ។ ពុំមានអ្នកណាស្គាល់ខ្ញុំ صلى الله عليه وآله وسلم ទេ ក្រៅពីអល់ឡោះហ្វ៍ عز وجل និងអាុលី صلوات الله عليه والسلام ។"

"បើអស់លោកចង់ឃើញចំណេះរបស់អាដាំ عليه السلام ចង់ឃើញសេចក្ដីគោរពសាសនារបស់នុះហ៍ عليه السلام ចង់ឃើញសក្ការៈរបស់អ៊ីបរ៉ហ៊ីម عليه السلام ចង់ឃើញការខ្លាចក្រែងរបស់មូសា عليه السلام ចង់ឃើញការបម្រើនិងសក្ការៈរបស់អ៊ីសា عليه السلام ចូរអស់លោកមើលមុខត្រចះត្រចង់របស់អាុលី صلوات الله عليه والسلام ។"

ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام មានឋានន្តរ (គឺឈ្មោះចំតើតបង្ហាញនូវឋានៈព្រះអង្គ صلوات الله عليه والسلام) ដូចតទៅគឺ៖

១. អាមីរុល-មុមីនីន صلوات الله عليه والسلام (ព្រះអគ្គប្រមុខរបស់បណ្ដាអ្នកមានសទ្ធាជ្រះថ្លា)

២. សៃយីដុ អាល់-វ៉ាស្ស៊ីយីន (سَيِّدُ الْوَصِيِّينَ ម្ចាស់របស់បណ្ដាអ្នកស្នងព្រះសាស្ដាទាំងឡាយ)

៣. ក៏ស៊ីម អាន់-ណារ វ៉ាល់ យ៉ាន់ណាស់ (قَسيمُ النّارِ و الجَنَة អ្នកចែកឋាននរកនិងឋានសួគ៌)

៤. សាគ្គី អាល់-កៅស្ស៊ារ (ساقي الكوثر ព្រះអនុរក្សស្រះអាល់-កៅស្ស៊ារ)

៥. ហៃដារ អាល់-ការ៉ារ (حيدر الكرار អស្សប្ញទ្ធិ (យុទ្ធជន) វាយសម្រុក)

៦. អ៊ីម៉ាំ អាល់-មុតតាគីន (إمام المتقين អគ្គប្រមុខរបស់បណ្ដាអ្នកជឿសប់ចិត្ត)

៧. អាស្ស៍-ស៊ីដ្ឌិក្ក អាល់-អាក់បារ (الصِدّيق الاكبر មហាសាក្សី)

៨. អាល់-ហ្វារុក្ក អាល់-អាក់ស្ហាំ (الْفَارُوقُ الأَعْظَمُ អ្នកញែកវែកញែករកខុសត្រូវ)

៩. យ៉ាក់ស៊ូប អាល់-មុស្លីមីន (يعسوب المسلمين មុស្លីមប្រសើរជាង់គេ)

១០ ខ៊ុលីហ្វាទូ រ៉ស៊ូលុលឡោះហ៍ (خَلِيفَةُ رَسُولِ اللَّهِ ព្រះឧត្តរាធិការីរបស់ព្រះសាសនៈទូត)

១១. វ៉ាស៊ី អារ-រ៉ស៊ូលុលឡោះហ៍ (وَصِيَّ رَسُولِ اللَّهِ អនុប្រធានរបស់ព្រះសាសនៈទូត)

១២. វ៉ាលីយុលឡោះហ៍ (وَلِيَّ اللَّهِ មិត្តរបស់អល់ឡោះហ៍ﷻ)

១៣. យ៉ាឌុលឡោះហ៍ (يَدُ اللَّهِ ដៃអល់ឡោះហ៍ﷻ)

១៤. អាស្វ-ស្វហ្វី (الصافي អ្នកបរិសុទ្ធ)

១៥. អាសាឌុលឡោះហ៍ អាល់-ក៊លីប (أسد الله الغالب វិជ័យរាជសីរបស់អល់ឡោះហ៍ﷻ)

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហាឌីស្ហព្រះសាស្តាមូហាំម៉ាដ់ﷺមួយនេះ មានន័យថាអ្វី គឺៈ "អាណា ម៉ាឌីណាទុល-អ៊ីលមូ វ៉ា អាលីយុន បាប៊ូហា"[6] ?

២. កាលព្រះសាស្តាមូហាំម៉ាដ់ﷺប្រកាសថា ព្រះអង្គﷺជាព្រះសាស្តារបស់អល់ឡោះហ្ជ័عزّ وجلّនោះ ព្រះអង្គﷺមានអាយុប៉ុន្មាន ?

៣. សៃយីដាស់ ហ្វាទីម៉ាស់ ប៊ិនទី អាសាដ់ បានចូលទៅក្នុងកាក់បាស់ដូចម្តេច ?

៤. ព្រះនាងចេញពីក្នុងកាក់បាស់វិញដូចម្តេច ?

៥. ឋានន្តរមួយណារបស់អ៊ីម៉ាំអាលីصلوات الله عليه والسلام បញ្ជាក់ថាព្រះអង្គصلوات الله عليه والسلامជា "ព្រះអគ្គប្រមុខរបស់បណ្តាអ្នកមានសទ្ធាជ្រះថ្លា" ?

6

قَالَ رَسُولُ اللّهِ صَلَّى اللّهُ عَلَيْهِ وَسَلَّمَ : "أَنَا مَدِينَةُ الْعِلْمِ وَعَلَيٌّ بَابُهَا، فَمَنْ أَرَادَ الْمَدِينَةَ فَلْيَأْتِ مِنْ بَابُهَا."

## មេរៀនទី ១៤

# អ៊ីមាំអាលី صلوات الله عليه والسلام - ភាគ ២

## អាចារសម្បត្តិនិងគុណសម្បត្តិ

ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ជាបុរសដែលមាន និងសម្តែងឲ្យឃើញនូវចរិមារយាទល្អប្រពៃបំផុតដែលមនុស្សអាចបានសម្រេច ។ ព្រះអង្គ صلوات الله عليه والسلام ជាគំរូគ្រប់វិស័យសម្រាប់បណ្តាអ្នកតាមព្រះអង្គ صلوات الله عليه والسلام ។ ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ صلى الله عليه وآله وسلم បានប្រាប់ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ថា៖ "អាលី صلوات الله عليه والسلام អើយ អ្នក صلوات الله عليه والسلام នឹងជាប់ពាក់ព័ន្ធក្នុងវិវាទ តែអ្នក صلوات الله عليه والسلام នឹងឈ្នះពួកគេអាស្រ័យគុណសម្បត្តិ ៧ ប្រការដែលអ្នក صلوات الله عليه والسلام មួយគត់មានគឺ៖ អ្នក صلوات الله عليه والسلام ជាបុគ្គលដំបូងបង្អស់ដែលជឿខ្ញុំ صلى الله عليه وآله وسلم អ្នក صلوات الله عليه والسلام ខ្លាំងពូកែបំផុតក្នុងសង្គ្រាម អ្នក صلوات الله عليه والسلام ចេះដឹងជាងគេនូវព្រះសញ្ញារបស់អល់ឡោះហ៊ូ عز وجل អ្នក صلوات الله عليه والسلام ស្មោះត្រង់ជាងគេចំពោះកិច្ចសន្យាស្មោះស្ម័គ្រ (عَهْد) ចំពោះអល់ឡោះហ៊ូ عز وجل អ្នក صلوات الله عليه والسلام អាណិតអាសូរមនុស្សជាងគេ អ្នក صلوات الله عليه والسلام មានសមត្ថភាពជាងគេក្នុងការប្រព្រឹត្តចំពោះខ្លួនឯងស្មើអ្នកដទៃ អ្នក صلوات الله عليه والسلام វិសេសវិសាលជាងគេសម្រាប់អល់ឡោះហ៊ូ عز وجل ។" យើងនឹងអធិប្បាយលំអិតអំពីគុណសម្បត្តិខ្លះរបស់ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ។

### ១. ជំនឿរបស់ព្រះអង្គ صلوات الله عليه والسلام ចំពោះអល់ឡោះហ៊ូ عز وجل និងចំពោះព្រះសាស្តា صلى الله عليه وآله وسلم

ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ជាបុរសដំបូងបង្អស់ដែលទៅជាមុស្លីម ។ ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "អស់ទេវតាប្រសិទ្ធិពរខ្ញុំ صلى الله عليه وآله وسلم និងអាលី صلوات الله عليه والسلام ៧០ ឆ្នាំព្រោះពេលមួយមានតែអាលី صلوات الله عليه والسلام និងខ្ញុំ صلى الله عليه وآله وسلم ទេដែលសូត្រកាលីម៉ាស្ទ ។" ព្រះអង្គ صلى الله عليه وآله وسلم មានព្រះវចនៈដែរថា៖ "អាលី صلوات الله عليه والسلام ជាបុគ្គលដំបូងបង្អស់ដែលជឿខ្ញុំ صلى الله عليه وآله وسلم និងជាបុគ្គលដំបូងបង្អស់ដែលចាប់ដៃគំនាប់ខ្ញុំ صلى الله عليه وآله وسلم ក្នុងថ្ងៃជំនុំជម្រះ ។ គេ صلوات الله عليه والسلام ជាមហាសាក្សីបញ្ជាក់ការពិត (ស្ទីដ្ឋឌិក្ក) ។ គេ صلوات الله عليه والسلام ជាព្រះអគ្គមហាប្រមុខរបស់បណ្តាអ្នកមានសទ្ធា ។"

## ២. ចំណេះរបស់ព្រះអង្គ صلوات الله عليه والسلام

ព្រះសាស្តាមូហាំម៉ាដ្ឋ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "អាលី صلوات الله عليه والسلام ជាអ្នកចេះដឹងជាងគេរបស់សហាគមន៍ខ្ញុំ صلى الله عليه وآله وسلم និងជាអ្នកមានសមត្ថភាពជាងគេក្នុងការវិនិច្ឆ័យស្របតាមច្បាប់បន្ទាប់ខ្ញុំ صلى الله عليه وآله وسلم ។" ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បានសម្តែងឲ្យឃើញថាព្រះអង្គ صلوات الله عليه والسلام ប្រសើរជាច់គេគ្រប់វិស័យចំណេះមួយជីវិតព្រះអង្គ صلوات الله عليه والسلام ។ ក្រោយពីព្រះសាស្តា صلى الله عليه وآله وسلم សោយទិវង្គត សូម្បីតែពួកស្តេចខ្ចិលិហ្វដែលបានដណ្តើមយកអំណាចដោយខុសច្បាប់នោះក៏បានរកព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ដែរ ដើម្បីសូមឲ្យជួយដោះស្រាយបញ្ហាពួកគេ ។ ពេលឡើងកាន់អំណាច ព្រះអង្គ صلوات الله عليه والسلام បានពាក់អាវធំនិងឈ្នួតក្បាលរបស់ព្រះសាស្តាមូហាំម៉ាដ្ឋ صلى الله عليه وآله وسلم ទៅម៉ាស់យ៉ីដ្ឋ អង្គុយលើវេទិកា ។ បន្ទាប់ពីបានធ្វើសក្ការៈអល់ឡោះហ៊្ វ عزوجل និងណែនាំប្រជារាស្ត្រ ព្រះអង្គ صلوات الله عليه والسلام អង្គុយវិញដោយទំនុកចិត្ត ស្រែះម្រាមដៃដាក់លើពោះ ហើយមានវចនៈថា៖ "ចូរអស់លោកសួរខ្ញុំ صلوات الله عليه والسلام មក មុនអស់លោកនឹងបាត់បង់ខ្ញុំ صلوات الله عليه والسلام ។ ចូរអស់លោកសួរខ្ញុំ صلوات الله عليه والسلام មកព្រោះខ្ញុំ صلوات الله عليه والسلام មានចំណេះរបស់បណ្តាអ្នកមុនៗខ្ញុំ صلوات الله عليه والسلام និងចំណេះរបស់បណ្តាអ្នកក្រោយៗខ្ញុំ صلوات الله عليه والسلام ។ ខ្ញុំ صلوات الله عليه والسلام អាចវិនិច្ឆ័យឲ្យបណ្តាអ្នកកាន់ព្រះគម្ពីរតៅរ៉ត្តបាន អាស្រ័យព្រះគម្ពីរតៅរ៉ត្តរបស់ពួកគេ ។ ខ្ញុំ صلوات الله عليه والسلام អាចវិនិច្ឆ័យឲ្យបណ្តាអ្នកកាន់ព្រះគម្ពីរអ៊ីនយ៉ីលបាន អាស្រ័យព្រះគម្ពីរអ៊ីនយ៉ីលរបស់ពួកគេ ។ ខ្ញុំ صلوات الله عليه والسلام អាចវិនិច្ឆ័យឲ្យបណ្តាអ្នកកាន់ព្រះគម្ពីរស្សាប៊ូរបាន អាស្រ័យព្រះគម្ពីរស្សាប៊ូររបស់ពួកគេ ។ ខ្ញុំ صلوات الله عليه والسلام អាចវិនិច្ឆ័យឲ្យបណ្តាអ្នកកាន់ព្រះគម្ពីរហ្វ៊ូរក្ខន (ព្រះគម្ពីរគួរអាន) បានអាស្រ័យព្រះគម្ពីរហ្វ៊ូរក្ខនរបស់ពួកគេ ។ សូមស្បថចំពោះអល់ឡោះហ៊្វ عزوجل ខ្ញុំ صلوات الله عليه والسلام ចេះដឹងព្រះគម្ពីរគួរអាននិងសេចក្តីអធិប្បាយព្រះគម្ពីរគួរអានប្រសើរជាងបុគ្គលដែលថាខ្លួនចេះដឹងព្រះគម្ពីរគួរអាននោះ ។"

## ៣. សេចក្តីក្លាហានរបស់ព្រះអង្គ صلوات الله عليه والسلام

ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام នៅមុខគេជានិច្ចក្នុងសមរភូមិអ៊ីស្លាម ព្រះអង្គ صلوات الله عليه والسلام បានធ្វើឲ្យបក្សមុស្លីមបានទទួលជ័យជំនះច្រើនសមរភូមិ ។ ព្រះអង្គ صلوات الله عليه والسلام ជាយុទ្ធជននិងជាមេទ័ពពូកែ ។ ព្រះអង្គ صلوات الله عليه والسلام ជាវិជយបុរសនៃសមរភូមិបាដ្ឋារ សមរភូមិអ៊ូហ៊្វុដ្ឋ សមរភូមិខុន់ដ្ឋាក់ សមរភូមិខុយ់បារនិងសមរភូមិហ៊ូណៃន៍ ។

គេទប់ព្រះអង្គ صلوات الله عليه والسلام មិនឈ្នះទេក្នុងសមរភូមិ លើសពីនេះ ព្រះអង្គ صلوات الله عليه والسلام បង្ហាត់

បង្រៀនមិត្តនិងសត្រូវព្រះអង្គ صلوات الله عليه والسلام ឲ្យចេះប្រព្រឹត្តត្រឹមត្រូវក្នុងសង្គ្រាម ។ សេចក្ដីក្លាហានរបស់ព្រះអង្គ صلوات الله عليه والسلام លាតសន្ធឹងទៅលើការបញ្ជាមនុស្សជាទូទៅ ព្រះអង្គ صلوات الله عليه والسلام មិនញញើតថាឬធ្វើអ្វីឡើយដើម្បីការពារអ៊ីស្លាម ទោះបីមានអ្នកប្រឆាំងបែបណាក៏ដោយ ។

## ៤. វោហារកោសល្យរបស់ព្រះអង្គ صلوات الله عليه والسلام

ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ស្ទាត់ជំនាញភាសាអារ៉ាប់ណាស់ ។ ក្នុងពេលដែលបុគ្គលឯទៀតរវល់តែដណ្ដើមអំណាចខ៊ិលីហ្វាស់ដោយខុសច្បាប់ ព្រះអង្គ صلوات الله عليه والسلام រវល់តែសរសេរតម្រាផ្សេងៗ ។ ព្រះអង្គ صلوات الله عليه والسلام បានចងក្រងព្រះគម្ពីរគួរអាន រៀបចំច្បាប់វាក្យសម្ព័ន្ធនិងច្បាប់វេយ្យាករណ៍របស់ភាសាអារ៉ាប់ ។ អត្ថបទនិងពាក្យពេជន៍មួយចំនួនរបស់ព្រះអង្គ صلوات الله عليه والسلام មាននៅក្នុងសាត្រា ណាស្ហ៍យ៉ូល-បាឡាកោ៎ះត៍ ដែលមាននូវគំរូសិល្បៈអក្សរសាស្ត្រអារ៉ាប់ប្រសើរបំផុត ។

## ៥. ស្រឡាញ់ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام និងជាស៊ីអ៊ាស់

ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام មានវចនៈថា៖ "ព្រះសាស្ដាមូហុាំម៉ាដ់ صلى الله عليه وآله وسلم បានប្រាប់ខ្ញុំ صلوات الله عليه والسلام ថាមានតែបណ្ដាអ្នកមានសទ្ធាជ្រះថ្លាទេដែលនឹងស្រឡាញ់ខ្ញុំ صلوات الله عليه والسلام មានតែមនុស្សមានកលល្បិចនិងពុតត្បុតទេដែលនឹងស្អប់ខ្ញុំ صلوات الله عليه والسلام ។" ហេតុដូច្នេះ មធ្យោបាយមួយសម្រាប់ស្គាល់ជំនឿរបស់មុស្លីមគឺពិនិត្យមើលអារម្មណ៍របស់មុស្លីមនោះ ដែលមានចំពោះព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ។

កាលគេសួរព្រះនាង អ៊ូម សាឡាម៉ាស់ ព្រះមហេសីម្នាក់របស់ព្រះសាស្ដាមូហុាំម៉ាដ់ صلى الله عليه وآله وسلم អំពីព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ព្រះនាងបានឆ្លើយថា៖ "ខ្ញុំបានឮព្រះសាស្ដារបស់អល់ឡោះហ៍ عز وجل មានព្រះវចនៈថា អាលី صلوات الله عليه والسلام និងស៊ីអ៊ាស់របស់ព្រះអង្គ صلوات الله عليه والسلام ជាអ្នកមានជោគជ័យ ។" ថ្ងៃមួយព្រះសាស្ដាមូហុាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "អ្នកសហាគមន៍ខ្ញុំ صلى الله عليه وآله وسلم ចំនួន ៧០ ០០០០ និងបានចូលឋានសួគ៌ដោយគ្មានការទូទាត់ឬដោយគ្មានទោស ។" បន្ទាប់មក ព្រះអង្គ صلى الله عليه وآله وسلم បែរទៅរកព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام មានព្រះវចនៈថា៖ "ពួកគេទាំងនោះជាស៊ីអ៊ាស់របស់អ្នក صلوات الله عليه والسلام អ្នក صلوات الله عليه والسلام ជាអ៊ីមុាំរបស់ពួកគេ ។"

មួយលើកទៀត ព្រះសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلمបានប្រាប់ព្រះសន្ដអ៊ីម៉ាំصلوات الله عليه والسلامថា៖ "ខ្ញុំصلى الله عليه وآله وسلمនិងអ្នកصلوات الله عليه والسلامត្រូវបង្កើតមកពីដុំដីតែមួយ ។ នៅសល់ដីនោះបន្ដិច អល់ឡោះហ្ទ៍عز وجلបានបង្កើតស្ទុីអ៊ុស្ទុំយើងعليهم السلامពីដីសំណល់នេះ ។ ថ្ងៃរស់ពីស្លាប់វិញ ប្រជារាស្ត្រទាំងអស់នឹងត្រូវហៅតាមឈ្មោះម្ដាយខ្លួន លើកលែងតែស្ទុីអ៊ុស្ទុំយើងعليهم السلام ។ ពួកគេនឹងត្រូវហៅតាមឈ្មោះឪពុកខ្លួនព្រោះពួកគេមានកំណើតប្រពៃ ។" គ្រាមួយ កាលព្រះសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلمបាននៅជុំជាមួយមុស្លីមមួយក្រុម ព្រះអង្គصلى الله عليه وآله وسلمបានប្រាប់ពួកគេថា៖ "បណ្ដាអាន់ស្វារអើយ ចូរអស់លោកបង្ហាត់កូនៗអស់លោកឲ្យចេះស្រឡាញ់ អាលីصلوات الله عليه والسلام ប៊ិន អាប៊ូ តាំលិបرضي الله عنه ។ អ្នកណាស្រឡាញ់គេصلوات الله عليه والسلام ចូរអ្នកនោះដឹងថាខ្លួនបានទទួលការដឹកនាំល្អ ។ អ្នកណាស្អប់គេصلوات الله عليه والسلام ចូរអ្នកនោះដឹងថាខ្លួនខុស ។"

សូមអល់ឡោះហ្ទ៍عز وجلឲ្យយើងងើបឡើងវិញនៅខាងអ៊ីម៉ាំអាលីصلوات الله عليه والسلام ថ្ងៃជំនុំជម្រះ ។

# លំហាត់

ចូរលើកឧទាហរណ៍ ប្រាប់នូវគុណសម្បត្តិខាងក្រោមនេះរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ។

១. សេចក្ដីក្លាហានរបស់ព្រះអង្គ صلوات الله عليه والسلام ។
២. វោហារកោសល្យរបស់ព្រះអង្គ صلوات الله عليه والسلام
៣. ជំនឿរបស់ព្រះអង្គ صلوات الله عليه والسلام លើអល់ឡោះហ្វ៍ عز وجل ។
៤. សេចក្ដីស្មោះត្រង់របស់ព្រះអង្គ صلوات الله عليه والسلام ចំពោះព្រះសាស្ដាមូហ្ហាំម៉ាដ់ صلى الله عليه وآله وسلم ។
៥. ចំណេះរបស់ព្រះអង្គ صلوات الله عليه والسلام ។

## មេរៀនទី ១៥

# អ៊ីម៉ាំអាលី صلوات الله عليه والسلام - ភាគ ៣

ជីវិតរបស់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ពេញដោយព្រឹត្តិការណ៍ ដែលឆ្លុះបញ្ចាំងឲ្យឃើញគុណសម្បត្តិនិងឋានៈព្រះអង្គ صلوات الله عليه والسلام ជាបុគ្គលមុខគេ បន្ទាប់ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ក្នុងចំណោមបណ្តាមុស្លីម ។ ពុំមានបុគ្គលណាមួយទេ ក្រៅពីព្រះអង្គ صلوات الله عليه والسلام ដែលមានគុណបំណាច់ (គឺបានធ្វើប្រការល្អសម្រាប់សហាគមន៍និងមនុស្សជាតិ) និងមានគុណសម្បត្តិច្រើនប្រការ ។ យើងសូមលើកឡើងនូវទង្វើសំខាន់ៗខ្លះក្នុងជីវិតព្រះអង្គ صلوات الله عليه والسلام ។

### ១. ចរិយារបស់ព្រះអង្គ صلوات الله عليه والسلام ក្នុងថ្ងៃ ស៊ុល អាស្ហ៊ីរ៉ោះត៍ (دعوة ذي العشيرة)

កាលព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានទទួលព្រះរាជបញ្ជាពីអល់ឡោះហ្ទ៍ عز وجل ឲ្យប្រកាសអ៊ីស្លាមប្រាប់សាច់ញាតិជិតស្និទ្ធិរបស់ព្រះអង្គ صلى الله عليه وآله وسلم ព្រះអង្គ صلى الله عليه وآله وسلم បានអញ្ជើញសាច់ញាតិទាំងអស់មកពិសាល្ងៀង រួចហើយព្រះអង្គ صلى الله عليه وآله وسلم ណែនាំឲ្យទាំងអស់គ្នាស្គាល់អ៊ីស្លាម ហើយបានសួរថាអ្នកណានឹងជួយព្រះអង្គ صلى الله عليه وآله وسلم ក្នុងបេសកកម្មព្រះអង្គ صلى الله عليه وآله وسلم ។ ពុំមានអ្នកណាចូលមកជិតទេ ក្រៅពីព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ថ្វីដ្បិតព្រះអង្គ صلوات الله عليه والسلام នៅកុមារភាពកាលនោះ ។ កាលនោះព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានប្រាប់ព្រះអង្គ صلوات الله عليه والسلام ថា៖ "អាលី صلوات الله عليه والسلام អើយ អ្នក صلوات الله عليه والسلام ជាបងប្អូនខ្ញុំ صلى الله عليه وآله وسلم ជាអ្នកតំណាងខ្ញុំ صلى الله عليه وآله وسلم ជាអ្នកគាំទ្រខ្ញុំ صلى الله عليه وآله وسلم ជាទាយាទខ្ញុំ صلى الله عليه وآله وسلم និងជាអ្នកស្នងខ្ញុំ صلى الله عليه وآله وسلم ។" ពេលដែលគ្រួសារព្រះអង្គ صلى الله عليه وآله وسلم មិនព្រមជឿព្រះអង្គ صلى الله عليه وآله وسلم ទេនោះ ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានទទួលការធានាគាំទ្រជីវិតព្រះអង្គ صلى الله عليه وآله وسلم ពីព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ។

### ២. ការបូជាជីវិតព្រះអង្គ صلوات الله عليه والسلام ក្នុងយប់ភៀសខ្លួន

ក្រោយពីបានបញ្ជាឲ្យពួកមុស្លីមចាកចេញពីម៉ាក់កាស់ ទៅកាន់ម៉ាឌីណាស់ ដើម្បីសន្តិសុខ ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានទទួលព្រះរាជបញ្ជាឲ្យភៀសខ្លួនដែរ ។ ធ្វើតាមព្រះរាជបញ្ជារបស់អល់ឡោះហ្ទ៍ عز وجل ព្រះអង្គ صلى الله عليه وآله وسلم បានសូមឲ្យព្រះសន្ត

អ៊ីម៉ាំ صلوات الله عليه والسلام សម្រាកនៅលើគ្រែព្រះអង្គ ﷺ ខណៈដែលព្រះអង្គ ﷺ ចាកចេញពីផ្ទះដោយមិនឲ្យគេដឹង ។ ទោះបីដឹងថាអាចមានគ្រោះថ្នាក់ដល់អាយុជីវិតជួសព្រះសាស្ដា ﷺ ក៏ដោយ ព្រះអង្គ صلوات الله عليه والسلام មិនរារែកធ្វើតាមបញ្ជាទេ ។ ផែនការក្បត់របស់ពួកគូរ៉យស្ហ៍ដែលគ្រោងសហការសម្លាប់ព្រះសាស្ដាមូហាំម៉ាដ់ ﷺ នោះ ត្រូវបរាជ័យដូច្នេះឯង ។ ដើម្បីទទួលស្គាល់គុណបំណាច់បូជាជីវិតរបស់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام អល់ឡោះហ្ទ៍ عزّ وجلّ បានដាក់អាយ៉ាស់មកថា៖

وَمِنَ ٱلنَّاسِ مَن يَشۡرِي نَفۡسَهُ ٱبۡتِغَآءَ مَرۡضَاتِ ٱللَّهِۚ وَٱللَّهُ رَءُوفُۢ بِٱلۡعِبَادِ ٢٠٧

*207. មនុស្សខ្លះប្ដូរជីវិតដើម្បីផ្គាប់ព្រះហឫទ័យអល់ឡោះហ្ទ៍ ។ អល់ឡោះហ្ទ៍អាណិតស្រឡាញ់បាវទាំងឡាយ[បែបនេះ]របស់ព្រះអង្គ ។* (អាល់-បាក៏វ៉ោះត៏ អាយ៉ាស់ 207 (2:207))

## ៣. បំពេញកាតព្វកិច្ចរបស់ព្រះសាស្ដាមូហាំម៉ាដ់ ﷺ នៅម៉ាក់កាស់

មានមនុស្សច្រើននៅម៉ាក់កាស់ បានផ្ញើទ្រព្យទុកឯព្រះសាស្ដាមូហាំម៉ាដ់ ﷺ ព្រោះព្រះអង្គ ﷺ ល្បីឈ្មោះជាមនុស្សត្រង់ ។ សត្រូវព្រះអង្គ ﷺ ក៏ទុកចិត្តព្រះអង្គ ﷺ ដែរ ។ ក្រោយពីបានទៅម៉ាឌីណាស់ ព្រះអង្គ ﷺ ផ្ដាំឲ្យព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បុគ្គលម្នាក់គត់ដែលព្រះអង្គ ﷺ ទុកចិត្ត ប្រគល់បញ្ញើទាំងអស់ទៅម្ចាស់វាវិញ ។ ព្រះអង្គ ﷺ បានផ្ដាំឲ្យព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام នាំគ្រួសារព្រះអង្គ ﷺ ទៅម៉ាឌីណាស់ដែរ ។

## ៤. តែងតាំងព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ជាព្រះអគ្គប្រតិភូទៅកាន់ប្រទេសយេមែន

ព្រះសាស្ដាមូហាំម៉ាដ់ ﷺ បានចាត់បញ្ជូន ខ៉ូលីដ្ឌ ប៊ិន វ៉ាលីដ្ឌ ទៅជួបប្រជាជាតិ បានី យ៉ាហ្ស៊ីម៉ាស់ (بنو جذيمة) នៅយេមែនដើម្បីហៅពួកគេមកចូលអ៊ីស្លាម ។ តែខ៉ូលីដ្ឌបានប្រព្រឹត្តរំលងព្រះបញ្ជាព្រះអង្គ ﷺ គាត់បានច្បាំងពួកគេទោះបីពួកគេព្រមទទួលអ៊ីស្លាមជាសាសនាខ្លួនហើយក៏ដោយ ។ ដើម្បីសងការខូចខាតដោយសារខ៉ូលីដ្ឌ ព្រះសាស្ដាមូហាំម៉ាដ់ ﷺ បានចាត់បញ្ជូនព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ទៅយេមែន ។

ព្រះអង្គ صلوات الله عليه والسلام បានទាក់ទងប្រជាជាតិនេះដោយថ្នម ហើយបានសងអ្វីដែលពួកគេបានខូចខាតនោះដោយបង់ឲ្យគេលើសពីគេទារ ។ ពាក្យពេជន៍ព្រះអង្គ صلوات الله عليه والسلام បាន

ធ្វើឲ្យយេមេនទាំងមូលប្តូរសាសនាមកកាន់សាសនាអ៊ីស្លាម លុះប្រជារាស្ត្រមានជំនឿមាំទើបព្រះអង្គ صلوات الله عليه والسلام ត្រឡប់មកម៉ាឌីណាស្ទុំវិញ ។

## ៥. កម្ទាត់រូបព្រះពីព្រះបូជនីយគ្រឹះកាក់បាស្ទុំ

ក្រោយពីវាយយកម៉ាក់កាស្ទុំបាន ព្រះសាស្តាមូហ៊ាំម៉ាដ្ទុំ صلى الله عليه وآله وسلم បានកម្ទាត់ចោលរូបព្រះទាំងអស់ដែលពួកអ្នកស្រុកម៉ាក់កាស្ទុំ បានដាក់នៅក្នុងបរិវេណព្រះបូជណីយគ្រឹះកាក់បាស្ទុំនោះ ។ ព្រះអង្គ صلى الله عليه وآله وسلم ឈោងមិនដល់រូបព្រះខ្លះ ដូច្នេះព្រះអង្គ صلى الله عليه وآله وسلم ជ្រើសរើសព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ឲ្យឡើងលើស្មាព្រះអង្គ صلى الله عليه وآله وسلم វាយទម្លាក់រូបព្រះដែលនៅសេសសល់ ។

## ៦. ខ្ទាន់ទង់នៅខុយ៉បារ

ក្នុងសមរភូមិខុយ៉បារ ទ័ពមុស្លីមមិនអាចវាយយកបានបន្ទាយមួយរបស់ពួកយ៉ាហ៊្វូឌី ថ្វីដ្បិតខិតខំច្រើនលើកក្រោមបញ្ជាមេបញ្ជាការច្រើននាក់ ។ ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام មានវត្តមាននៅទីនោះដែរតែមិនអាចចូលរួមប្រយុទ្ធបានទេ ព្រោះព្រះអង្គ صلوات الله عليه والسلام ឈឺភ្នែកខ្លាំងពេក ។ ទីបំផុត ព្រះសាស្តាមូហ៊ាំម៉ាដ្ទុំ صلى الله عليه وآله وسلم បានប្រកាសថា៖ "ស្អែកខ្ញុំ صلى الله عليه وآله وسلم នឹងប្រគល់ទង់ឲ្យទៅបុគ្គលម្នាក់ ដែលអល់ឡោះហ៊្វ عز وجل និងព្រះសាស្តាព្រះអង្គ عز وجل ស្រឡាញ់ ។ បុគ្គលនោះនឹងមិនគេចវេះសមរភូមិទេ លុះត្រាតែអល់ឡោះហ៊្វ عز وجل ប្រទានឲ្យនូវជ័យជំនះទើបបុគ្គលនោះប្រឡប់មកវិញ ។" ពួកមុស្លីមរង់ចាំថ្ងៃស្អែកដោយអន្ទះសា ម្នាក់ៗចង់ឲ្យគេជ្រើសរើសខ្លួន ។ តែព្រះសាស្តាមូហ៊ាំម៉ាដ្ទុំ صلى الله عليه وآله وسلم បានហៅព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام បានធ្វើឲ្យភ្នែកព្រះអង្គ صلوات الله عليه والسلام ជាសះស្បើយវិញដោយឈ្លីភ្នែកព្រះអង្គ صلوات الله عليه والسلام ជាមួយទឹកមាត់ព្រះអង្គ صلى الله عليه وآله وسلم ។ បន្ទាប់ពីនោះ ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ទៅប្រយុទ្ធក្នុងសមរភូមិយ៉ាងខ្លាំងក្លា ពុំមានអ្នកណាមួយទប់ព្រះអង្គ صلوات الله عليه والسلام ឈ្នះទេ ។ ព្រះអង្គ صلوات الله عليه والسلام ត្រឡប់មកវិញលុះត្រាតែវាយយកបានបន្ទាយទាំងអស់ បាននាំជ័យជំនះមកឲ្យបក្សមុស្លីម ។

## ៧. ការប្រគល់ (ប្រកាស) អាយ៉ាស្ទុំព្រះគម្ពីរគួរអាន

ព្រះសាស្តាមូហ៊ាំម៉ាដ្ទុំ صلى الله عليه وآله وسلم បានផ្ញើឯកសារមួយដែលមាននូវ ៤០ អាយ៉ាស្ទុំ

ដំបូងនៃសូរ៉ោះត៍ អាត់-តៅបាស់ (អាល់-បារ៉អាស់) ជាមួយ អាប៊ូ បាការ ទៅម៉ាក់កាស់ ដើម្បីនឹងឲ្យគាត់សូត្រក្នុងពិធីហាជ្ជ់ ។ តែទេវតាយ៉ីបរ៉អ៊ីល عليه السلام បានមកប្រាប់ព្រះសាស្តាមូហាំម៉ាដ់ صلی الله علیه وآله وسلم ថា៖ "អល់ឡោះហ្វ៍ عزّ وجلّ ផ្ញើសាទ្បាមមកព្រះអង្គ صلی الله علیه وآله وسلم អល់ឡោះហ្វ៍ عزّ وجلّ ចង់ឲ្យព្រះអង្គ صلی الله علیه وآله وسلم ឬកនម្នាក់របស់ព្រះអង្គ صلی الله علیه وآله وسلم ជាអ្នកប្រគល់ (ប្រកាស) អាយ៉ាស់ ។" ព្រះសាស្តា صلی الله علیه وآله وسلم ក៏បានបញ្ជូនព្រះសន្តអ៊ីម៉ាំ صلوات الله علیه والسلام ភ្លាម ជិះអូដ្ឋលឿនទៅឲ្យទាន់ អាប៊ូ បាការ ទទួលយកអាយ៉ាស់ជូសគាត់ ។ ដូច្នេះ ព្រះសន្តអ៊ីម៉ាំ صلوات الله علیه والسلام ជាអ្នកទទួលភារកិច្ចសូត្រអាយ៉ាស់គួរអាន ដែលមាននូវខ្លឹមសារសំខាន់ប្រាប់ប្រជារាស្រ្តម៉ាក់កាស់ថាបក្សមុស្លីមមិនអត់ឱនឲ្យធ្វើសក្ការៈរូបព្រះទៀតទេ ។

## ៨. ការតែងតាំងព្រះអង្គ صلوات الله علیه والسلام នៅ ក៏ដៀរ ឃុម

ក្រោយពីបានបំពេញពិធីហាជ្ជ់ចុងក្រោយ ព្រះសាស្តាមូហាំម៉ាដ់ صلی الله علیه وآله وسلم បានទទួលព្រះរាជបញ្ជាពីអល់ឡោះហ្វ៍ عزّ وجلّ ឲ្យប្រកាសប្រាប់ប្រជារាស្រ្តឲ្យដឹងថា ព្រះសន្តអ៊ីម៉ាំ صلوات الله علیه والسلام ជាអ្នកស្នងព្រះអង្គ صلی الله علیه وآله وسلم ។ នៅឯកន្លែងមួយដែលហៅថា ក៏ដៀរ ឃុម ព្រះសាស្តាមូហាំម៉ាដ់ صلی الله علیه وآله وسلم បានប្រកាស ដោយបរិយាយសង្ខេបព្រះបេសកកម្មព្រះអង្គ صلی الله علیه وآله وسلم ពីដើមដល់ចប់ ។ ទីបញ្ចប់ ព្រះអង្គ صلی الله علیه وآله وسلم មានព្រះវចនៈថា៖ "ប្រជារាស្រ្តអើយ ខ្ញុំ صلی الله علیه وآله وسلم ជាម្ចាស់របស់អ្នកណា អាលី صلوات الله علیه والسلام ក៏ជាម្ចាស់របស់អ្នកនោះដែរ ។" ពុំមានអ្វីគួរឲ្យសង្ស័យទេថាគ្រប់ៗគ្នាដែលមានវត្តមាននៅទីនោះ យល់ច្បាស់ខ្លឹមសាររបស់ព្រះរាជសារ ថ្វីដ្បិតបុគ្គលខ្លះមិនអើពើព្រះរាជសារនេះព្រោះតែលោភលន់អំណាចនិងច្រណែនឈ្នានីសព្រះសន្តអ៊ីម៉ាំ صلوات الله علیه والسلام ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីអ៊ីម៉ាំអាលី ﷺ មិនបានប្រយុទ្ធក្នុងសមរភូមិខុយបារ ពីដំបូង ?

២. មានន័យថាអ្វី "មាន់ គុនទូ ម៉ៅឡាហ៊ូ ហ្វា ហ្វាសា អាលីយុន ម៉ៅឡាហ៊ូ" ?

៣. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ ﷺ បានបញ្ជូនអ៊ីម៉ាំអាលី ﷺ ទៅសូត្រ អាយ៉ាស់ព្រះគម្ពីរគួរអានឲ្យពួកអ្នកស្រុកម៉ាក់កាស់ស្តាប់ ?

៤. ការអញ្ជើញ ស៊ុល អាស្ស៊ីរ៉ោះត៍ មានលទ្ធអ្វី ?

៥. ព្រះសាស្តាមូហាំម៉ាដ់ ﷺ បានធ្វើឲ្យអ៊ីម៉ាំអាលី ﷺ មានសុខភាពល្អវិញ ដូចម្តេចនៅខុយបារ ?

# មេរៀនទី ១៦

## អ៊ីមាំអាលី صلوات الله عليه والسلام - ភាគ ៤

### ទុក្ករកម្មរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام

បន្ទាប់ពីអ៊ីម៉ាំអាលី صلوات الله عليه والسلام បានទៅជាខ៊ិលិហ្វរបស់មុស្លីម ព្រះអង្គ صلوات الله عليه والسلام បានប្រឈមនឹងសមរភូមិច្រើន ។ សមរភូមិណាស្ហ៍រវ៉ាន (معركة النهروان) ជាសមរភូមិចុងក្រោយ ក្នុងចំណោមសមរភូមិទាំងនេះ ច្បាំងតទល់ពួក ខ៊ិវ៉ារិជ្ជ (الخوارج) ។ ប្រជាជាតិនេះបានបោះបង់ចោលព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ដោយចោទថាព្រះអង្គ صلوات الله عليه والسلام អត់ឱនឲ្យមូអាវីយ៉ាស្ហ៍ពេកនៅក្នុងសមរភូមិស៊្ហិហ្វហ្វ៊ីន (وَقْعَة صِفِّيْن) ។ ក្រោយពីបានចាញ់សមរភូមិ ប្រជាជាតិនេះបានទៅកាន់ម៉ាក់កាស្ហ៍ បានរៀបចំផែនការនៅទីនោះដើម្បីសម្លាប់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام, មូអាវីយ៉ាស្ហ៍, អុំរ៉ូ អាល់-អាស្ហ៍ (عمر بن العاص) ។ អុំរ៉ូជាទីប្រឹក្សាជំនិតរបស់មូអាវីយ៉ាស្ហ៍និងជាទេសាភិបាលប្រទេសអេស៊ីបត៍ ពួកគេខ្លាចគាត់ទាមទារអំណាចខ៊ិលីហ្វាស្ហ៍បន្ទាប់ពីមូអាវីយ៉ាស្ហ៍ស្លាប់ ។ ដែលពួកខ៊ិវ៉ារីជ្ជចង់សម្លាប់បុគ្គលទាំងអស់នេះ ព្រោះពួកគេគិតថានឹងអាចធ្វើឲ្យចក្រភពមុស្លីមមានសណ្តាប់ធ្នាប់ឡើងវិញបាន ។ អាស្រ័យហេតុនេះ អាប់ឌូរ៉ោះហ្ម៉ាន អ៊ីបនូ មុលយ៉ាំ (عَبْدُ الرَّحْمَنِ اِبْنُ مُلْجَمٍ) ព្រមសម្លាប់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام, អាល់-ប៊ូរ៉ក់ ប៊ិន អាប់ឌុលឡោះហ្ហ៍ អាល់-តាមីមី (البرك بن عبد الله التميمي) ព្រមសម្លាប់មូអាវីយ៉ាស្ហ៍, អុំរ៉ូ ប៊ិន បាការ អាល់-តាមីមី (عمرو بن بكر التميمي) ព្រមសម្លាប់អុំរ៉ូ អាល់-អាស្ហ៍ ។

ព្រឹកថ្ងៃសុក្រ ទី ១៩ ខែរ៉ម៉ាដូន ត្រូវបានជ្រើសរើសជាថ្ងៃធ្វើឃាត ។ ឃាតករទាំងបីបានលាបផ្លែដាវដោយថ្នាំបំពុលហើយបានទៅកាន់ស្រុកគូហ្វាស្ហ៍ ដាម៉ាស់ និងអេស៊ីបត៍ ។ ឃាតករទៅកាន់អេស៊ីបត៍ត្រូវសម្លាប់តាំងពីមុនបានចូលទៅជិតអុំរ៉ូ អាល់-អាស្ហ៍ ម្ល៉េះ ។ ឃាតករទីពីរ អាល់-ប៊ូរ៉ក់ បានទៅដល់ដាម៉ាស់ បានវាយសម្លាប់មូអាវីយ៉ាស្ហ៍តែវាយខុស ។ គាត់ត្រូវសម្លាប់មុនបានប៉ះខ្លួនមូអាវីយ៉ាស្ហ៍ ។ តែឃាតករទីបីបញ្ជូនទៅសម្លាប់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام នោះ បានទៅដល់គូហ្វាស្ហ៍ដោយសវត្ថិភាព បានទៅឈប់នៅមុខម៉ាស់យ៉ិដគូហ្វាស្ហ៍យប់នៃថ្ងៃទី ១៩ ខែរ៉ម៉ាដូន ។

## ជំហានចុងក្រោយ

ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បានដឹងជាមុន នូវពេលព្រះអង្គ صلوات الله عليه والسلام ចាកចោលលោកនេះ ច្រើនថ្ងៃមកម្ល៉េះ ។ ពេលព្រះអង្គ صلوات الله عليه والسلام ចេញពីផ្ទះ ទាព្រះអង្គ صلوات الله عليه والسلام យំខ្លាំងៗ ពេលបម្រើព្រះអង្គ صلوات الله عليه والسلام ដេញវាឲ្យឈប់ស្រែក ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام មានវចនៈថា៖ "លែងវាទៅ ! វាស្រែកព្រោះតែវាកើតទុក្ខដោយសារខ្ញុំ صلوات الله عليه والسلام ជិតដល់ពេលស្លាប់ ។"

ព្រឹកថ្ងៃទី ១៩ ខែរ៉ាម៉ាដ្ហន ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ទៅម៉ាស់ឃ្ជិដ្ទគូហ្វាស់ ដាស់មនុស្សដែលដេកនៅឯម៉ាស់ឃ្ជិដ្ទនោះ ។ អ៊ីបនូ មុលយ៉ាំ ដេកផ្កាប់មុខដើម្បីលាក់ដាវ ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បានដាស់គាត់ដែរដោយប្រាប់គាត់កុំឲ្យដេកផ្កាប់មុខដូចស្ហៃតនូន لعن الله ។ រួចអាស្ហាន់ ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បាននាំស្វ៉ឡាត់ អ៊ីបនូ មុលយ៉ាំ ធ្វើជាស្វ៉ឡាត់ពីក្រោយព្រះអង្គ صلوات الله عليه والسلام ។ ពេលព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ឱនស៊ូឃ្ជូដ អ៊ីបនូ មុលយ៉ាំ កាប់ព្រះអង្គ صلوات الله عليه والسلام មួយដាវពេញទំហឹងចំក្បាល ។ ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានប្រាប់ឲ្យដឹងមុនអំពីឃាតកម្មព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام និងអំពីឃាតកម្មព្រះរាជបុត្រ عليهم السلام ព្រះអង្គ صلوات الله عليه والسلام ថា៖ "អាលី صلوات الله عليه والسلام អើយ ខ្ញុំ صلى الله عليه وآله وسلم ឃើញផ្ទាល់ភ្នែកពុកចង្កាអ្នក صلوات الله عليه والسلام ប្រឡាក់ឈាមថ្ងាសអ្នក صلوات الله عليه والسلام ។"

## សេចក្តីប្រោសប្រណីចំពោះឃាតករ

គេចាប់ខ្លួនឃាតករបាន ហើយនាំទៅជួបព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ។ ពេលឃើញខ្សែចំណងមុតសាច់គាត់ ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ភ្លេចការឈឺចាប់របស់ខ្លួនឯង ឲ្យគេប្រព្រឹត្តដោយមនុស្សធម៌ជាងនេះចំពោះ អ៊ីបនូ មុលយ៉ាំ ។ ពាក្យពេជន៍ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បានធ្វើឲ្យឃាតករយំព្រោះរំភើបចិត្តខ្លាំង ។ ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ញញឹមស្ងួត ហើយមានវចនៈខ្សោយៗថា៖ "ពេលនេះលោកហួសពេលសោកស្តាយកំហុសដែលបានប្រព្រឹត្តហើយ ។ លោកបានធ្វើហួសហើយ ។ ខ្ញុំ صلوات الله عليه والسلام ជាអ៊ីម៉ាំអាក្រក់ឬជាអ្នកដឹកកំណាចមែនទេ ?" នេះជាការប្រព្រឹត្តតាមប្រក្រតីរបស់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ប្រតិបត្តិយុត្តិធម៌ដោយផ្អែកទៅលើធម៌មេត្តា ចំពោះសត្រូវអប្រិយបំផុតរបស់ព្រះអង្គ صلوات الله عليه والسلام ក៏ព្រះអង្គ صلوات الله عليه والسلام ធ្វើបែបនេះដែរ ។

## ពាក្យពេជន៍ចុងក្រោយប្រកបដោយសុភនិច្ឆ័យ

គេបានលើកព្រះសន្តអ៊ីមុាំصلوات الله عليه والسلامពីម៉ាស់យ៉ីដទៅលំនៅព្រះអង្គصلوات الله عليه والسلام ។ ជិតសោយទិវង្គត សាវកម្នាក់របស់ព្រះអង្គصلوات الله عليه والسلامឈ្មោះ អាស្វ៉ាក់ ប៊ិន ណាបាតាស់ (أَصْبَغ بْنِ نُبَاتَةَ المُجاشعي التَميمي الحَنظلي) បានមកមើលព្រះអង្គصلوات الله عليه والسلام សូមធម៌ព្រះអង្គصلوات الله عليه والسلام ។ ព្រះសន្តអ៊ីមុាំصلوات الله عليه والسلامបានតបថា៖ "អាស្វ៉ាក់អើយ មានឱវាទណាប្រសើរជាងព្រឹត្តិការណ៍ដែលកាលពីម្សិលមិញខ្ញុំصلوات الله عليه والسلامជាកនម្នាក់របស់លោក ថ្ងៃនេះលោកជាភ្ញៀវខ្ញុំصلوات الله عليه والسلام ថ្ងៃស្អែកខ្ញុំصلوات الله عليه والسلامគ្រាន់តែជាអនុស្សាវរីយមួយប៉ុណ្ណោះ ។"

ពាក្យពេជន៍ចុងក្រោយ ដែលព្រះអង្គصلوات الله عليه والسلامមានវចនៈប្រាប់ព្រះរាជបុត្រعليهم السلام ព្រះអង្គصلوات الله عليه والسلامគឺ៖ "ចូរកូនខ្លាចក្រែងព្រះជានិច្ចកុំល្មៀង ចូរកូនទុកកាយថ្វាយចិត្តលើព្រះឆន្ទៈអល់ឡោះហ៏عزّ وجلّ ។ ចូរកូនកុំប្រាថ្នាអ្វីដែលឈោងមិនដល់ ។ ចូរកូនត្រង់និងអាណិតប្រណីកូនកំព្រា ។ ចូរកូនជួយជនក្រីក្រនិងជនតោកយ៉ាក ចូរកូនរស់នៅក្នុងលោកនេះដោយធ្វើឲ្យលោកនេះកាន់តែប្រសើរឡើង ។

## កិច្ចបញ្ចុះព្រះរាជសពដ៏អស្ចារ្យ

ព្រះអង្គصلوات الله عليه والسلامបានប្រាប់ព្រះរាជបុត្រعليهم السلامព្រះអង្គصلوات الله عليه والسلام ឲ្យសែងមឈូសព្រះអង្គصلوات الله عليه والسلامខាងក្រោយព្រោះមានដៃដែលមើលមិនឃើញសែងមឈូសខាងមុខ ។ ព្រះអង្គصلوات الله عليه والسلامបានប្រាប់ព្រះរាជបុត្រعليهم السلامឲ្យដើរតាមមឈូសផ្ទាល់ ។ មឈូសឈប់កន្លែងណា ព្រះរាជបុត្រعليهم السلامនឹងឃើញមានផ្នូរជីកស្រាប់ទុកសម្រាប់ព្រះអង្គصلوات الله عليه والسلام ។ ព្រះអង្គصلوات الله عليه والسلامបានប្រាប់ព្រះរាជបុត្រعليهم السلامឲ្យបញ្ចុះព្រះរាជសពព្រះអង្គصلوات الله عليه والسلام ដោយកុំឲ្យគេដឹងក្រែងសត្រូវប្រមាថផ្នូរព្រះអង្គصلوات الله عليه والسلام ។

ថ្ងៃទី ២១ ខែរ៉ម៉ាដ្ធន ឆ្នាំទី ៤០ សករាជហ៊ិជ្រ៉ោះត៏ ព្រះសន្តអ៊ីមុាំصلوات الله عليه والسلامបានចាកចោលលោកនេះ ។ ព្រះអង្គصلوات الله عليه والسلامមានព្រះជន្មាយុ ៦៣ ព្រះវស្សា ។ បន្ទាប់ពីបានផ្ងូតទឹកម៉ាយិតនិងគ្រងសំពត់កាហ្វាន់ ព្រះរាជបុត្រទាំងពីរعليهم السلامរបស់ព្រះអង្គصلوات الله عليه والسلام អ៊ីមុាំហ្ហាសាន់صلوات الله عليه والسلامនិងអ៊ីមុាំហ៊្សែន៍صلوات الله عليه والسلامបានសែងមឈូស ។ មឈូសបានឈប់នៅឯណាយ៉ាហ្វ៍ ឆ្ងាយពីគូហ្វាស់ប្រមាណ ៦,៥ គីឡូម៉ែត្រ ។ ព្រះរាជបុត្រعليهم السلامបានឃើញផ្នូរមួយជីករួចស្រេចជាមួយសារមួយឃ្លាថា៖ "ផ្នូរនេះត្រូវបានជីកដោយព្រះសាស្តានុះហ៊្វ៍عليه السلامសម្រាប់អាលីصلوات الله عليه والسلام ព្រះអគ្គប្រមុខរបស់បណ្តាអ្នកមានសទ្ធាជ្រះថ្លា ។"



ព្រះរាជសពព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ត្រូវបានបញ្ចុះក្នុងផ្នូរនេះ ។ រហូតមកដល់សព្វថ្ងៃនេះ ព្រះចេតិយរបស់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ត្រូវបានសាងសង់ខ្ពស់ឡើងអស្ចារ្យបំផុត ។ មនុស្សច្រើនរាប់ពុំអស់មួយពិភពលោក ទៅស៊ីរ៉ាស់ និងសម្តែងសេចក្តីគោរព ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ទាំងហ្វូងៗរៀងរាល់ថ្ងៃ ។ គេបួងសួងអល់ឡោះហ៍ عز وجل នៅទីនេះសូមការគាំទ្រពីព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ។

បុគ្គលបិសាចឈ្មោះ សាដ្ដាំ ហ៊ូសែន បានបំផ្លិចបំផ្លាញផ្នូរព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام និងព្រះចេតិយនៅឯណាយ៉ាហ្វ៍និងការបាឡាអ៍ និងប្រព្រឹត្តបទឧក្រិដ្ឋសន្ធឹកសន្ធាប់ទៅលើមនុស្សស្លូតត្រង់ ជាពិសេស ទៅលើស៊ីអ៊ាស់ ។ សូមអល់ឡោះហ៍ عز وجل ដាក់ទណ្ឌកម្មវាក្នុងផ្នូរវារហូតដល់ថ្ងៃជំនុំជម្រះ បញ្ជូនទៅក្នុងនរករហូតឥតអវសាន ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. បុគ្គលបីនាក់ដែលពួកខ៊័រ៉ារីជ្ជបានសម្រេចសម្លាប់នោះមានអ្នកណាខ្លះ ?

២. ហេតុអ្វីពួកគេបានសម្រេចធ្វើបែបនេះ ?

៣. ឃាតករមួយណាដែលបានធ្វើឃាតកម្មបានសម្រេច ?

៤. ចូរប្រាប់ថ្ងៃដែលព្រះសន្តអ៊ីម៉ាំអា្លី صلوات الله عليه والسلام សោយព្រះទិវង្គត ?

៥. ព្រះរាជសពព្រះអង្គ صلوات الله عليه والسلام ត្រូវបញ្ចុះនៅឯណា ?

## មេរៀនទី ១៧

# អ៊ីមាំហាសាន់ صلوات الله عليه والسلام - ភាគ ១

| | |
|---|---|
| ឈ្មោះ | : ហាសាន់ |
| ឋានៈ | : អាល់-មុជតាបា (اَلْمُجْتَبَى បុគ្គលដែលអល់ឡោះហ៊្ជ عزوجل ជ្រើសរើស) |
| ឈ្មោះក្រៅ | : អាប៊ូ មូហាំម៉ាដ្ឌ |
| បិតា | : អ៊ីមុាំអាលី صلوات الله عليه والسلام |
| មាតា | : សៃយីដ្ហាស់ ហ្វាទីម៉ាស់ ស្ហាស់រ៉ាអ៊ី سلام الله عليها |
| កំណើត | : ថ្ងៃទី ១៥ ខែរ៉ម៉ាដូន ឆ្នាំទី ៣ សកករាជហ៊ីជ្រ៉េះត៍ នៅម៉ាឌីណាស់ |
| អ៊ីម៉ាម៉ាស់ | : ពីឆ្នាំទី ៤០ សកករាជហ៊ីជ្រ៉េះត៍ ដល់ឆ្នាំទី ៥០ សកករាជហ៊ីជ្រ៉េះត៍ |
| ទុក្ករកម្ម | : ថ្ងៃទី ២៨ ខែស៊្វហ្វារ ឆ្នាំទី ៥០ សកករាជហ៊ីជ្រ៉េះត៍ |
| ទីបញ្ចុះសព | : ម៉ាឌីណាស់ ប្រទេស អារ៉ាប៊ី សាអ៊ូឌី |

ព្រះសន្តអ៊ីមុាំហាសាន់ صلوات الله عليه والسلام ជាព្រះរាជបុត្របងគេរបស់អ៊ីមុាំអាលី صلوات الله عليه والسلام និង សៃយីដ្ហាស់ ហ្វាទីម៉ាស់ ស្ហាស់រ៉ាអ៊ី سلام الله عليها ។ ពេលព្រះសាស្តាមូហាំម៉ាដ្ឌ صلى الله عليه وآله وسلم បានទទួលដំណឹងល្អកំណើតព្រះរាជនត្តារបស់ព្រះអង្គ صلى الله عليه وآله وسلم ព្រះអង្គ صلى الله عليه وآله وسلم បានទៅកាន់ដំណាក់ព្រះរាជបុត្រីជាទីស្រឡាញ់របស់ព្រះអង្គ صلى الله عليه وآله وسلم ភ្លាម ។ ព្រះអង្គ صلى الله عليه وآله وسلم បានបីព្រះរាជទារកបានសូត្រអាស្ហានដាក់ត្រចៀកស្តាំព្រះរាជទារក សូត្រអ៊ីក៏ម៉ាស់ដាក់ត្រចៀកឆ្វេង ។ បន្ទាប់មកព្រះអង្គ صلى الله عليه وآله وسلم បានដាក់ព្រះនាមឲ្យព្រះរាជទារកថា អាល់-ហាសាន់ តាមព្រះរាជបញ្ជារបស់អល់ឡោះហ៊្ជ عزوجل ។

ប្រាំពីរឆ្នាំដំបូងក្នុងជីវិតរបស់ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام នៅក្រោមអាណាព្យាបាលនិងការណែនាំរបស់ព្រះសាស្តាមូហាំម៉ាដ្ឌ صلى الله عليه وآله وسلم ព្រះអយ្យកោ صلى الله عليه وآله وسلم ព្រះអង្គ صلوات الله عليه والسلام ។ ការអប់រំមុនពេលនេះបានធ្វើឲ្យព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ប្រសើរដាច់គេក្នុងការចេះដឹង ក្នុងជំនឿ ក្នុងការអត់ឱន ក្នុងវិស័យប្រាជ្ញានិងក្នុងវិស័យអង់អាចក្លាហាន ។

ព្រះសន្តអ៊ីម៉ាំ(صلوات الله عليه والسلام)និងប្អូនប្រុសព្រះអង្គ(صلوات الله عليه والسلام) អ៊ីម៉ាំហ៊្វូសៃន៍(صلوات الله عليه والسلام) ជាបុគ្គលជាទីស្រឡាញ់បំផុតសម្រាប់ព្រះសាស្តាមូហ្ហាំម៉ាដ់(صلى الله عليه وآله وسلم) ។ ព្រះអង្គ(صلى الله عليه وآله وسلم)បានលីព្រះអង្គទាំងពីរ(عليهم السلام)លើស្មា ដោយមានព្រះវចនៈថា៖ "ហ្ហាសាន់(صلوات الله عليه والسلام)និងហ៊្វូសៃន៍(صلوات الله عليه والسلام)ជាព្រះអគ្គប្រមុខរបស់យុវជនឋានសួគ៌ ។"[7]

ថ្ងៃមួយសៃយីដ្វាស់ហ្វាទីម៉ាស់(سلام الله عليها)បាននាំព្រះរាជបុត្រទាំងពីរ មកលេងព្រះសាស្តាមូហ្ហាំម៉ាដ់(صلى الله عليه وآله وسلم) ទូលព្រះអង្គ(صلى الله عليه وآله وسلم)ថា៖ "ព្រះសាស្តា(صلى الله عليه وآله وسلم)អល់ឡោះហ៍(عز وجل)អើយ នេះគឺព្រះរាជនត្តាទាំងពីរ(عليهم السلام)របស់ព្រះអង្គ(صلى الله عليه وآله وسلم) ។ សូមព្រះអង្គ(صلى الله عليه وآله وسلم)ប្រទានអ្វីមួយជាកេរមរតកឲ្យគេទាំងពីរនេះ(عليهم السلام) ។" ព្រះសាស្តាមូហ្ហាំម៉ាដ់(صلى الله عليه وآله وسلم)បានតបថា៖ "ហ្ហាសាន់(صلوات الله عليه والسلام)នឹងទទួលរាងនិងសេចក្តីថ្លៃថ្នូររបស់បិតា(صلى الله عليه وآله وسلم)ជាកេរមរតក[8] ចំណែកឯហ៊្វូសៃន៍(صلوات الله عليه والسلام)នឹងទទួលចិត្តទូលំទូលាយនិងសេចក្តីអង់អាចក្លាហានរបស់បិតា(صلى الله عليه وآله وسلم) ជាកេរមរតក ។"

កាលពីនៅកុមារភាព ព្រះសន្តអ៊ីម៉ាំ(صلوات الله عليه والسلام)តែងតែស្តាប់ដោយយកចិត្តទុកដាក់

[7]-ដកស្រង់ពី *ស៊ូណាន់ អ៊ីបនូ ម៉ាយ៉ាស្ញ់ (سنن ابن ماجه)* https://sunnah.com/ibnmajah:118 ថា៖ អាប៊ូអ៊ុម៉ារមានប្រសាសន៍ថាព្រះសាស្តា(صلى الله عليه وآله وسلم)មាន ព្រះវចនៈថា៖ "អាល់-ហ្ហាសាន់(صلوات الله عليه والسلام)និងអាល់-ហ៊្វូសៃន៍(صلوات الله عليه والسلام)នឹងទៅជាមេដឹកនាំរបស់បណ្តាយុវជនឋានសួគ៌ បិតា(صلوات الله عليه والسلام)របស់ពួកគេ(عليهم السلام)ប្រសើរជាងពួកគេ(عليهم السلام) ។"

حَدَّثَنَا مُحَمَّدُ بْنُ مُوسَى الْوَاسِطِيُّ، حَدَّثَنَا الْمُعَلَّى بْنُ عَبْدِ الرَّحْمَنِ، حَدَّثَنَا ابْنُ أَبِي ذِئْبٍ، عَنْ نَافِعٍ، عَنِ ابْنِ عُمَرَ، قَالَ قَالَ رَسُولُ اللَّهِ ـ صلى الله عليه وسلم ـ " **الْحَسَنُ وَالْحُسَيْنُ سَيِّدَا شَبَابِ أَهْلِ الْجَنَّةِ وَأَبُوهُمَا خَيْرٌ مِنْهُمَا** " .

-ដកស្រង់ពី យ៉ាមិអ៊ អាត់តៀរមីស៊ី (جامع الترمذي) https://sunnah.com/tirmidhi/49/180

حَدَّثَنَا عَبْدُ اللَّهِ بْنُ عَبْدِ الرَّحْمَنِ، وَإِسْحَاقُ بْنُ مَنْصُورٍ، قَالاَ أَخْبَرَنَا مُحَمَّدُ بْنُ يُوسُفَ، عَنْ إِسْرَائِيلَ، عَنْ مَيْسَرَةَ بْنِ حَبِيبٍ، عَنِ الْمِنْهَالِ بْنِ عَمْرٍو، عَنْ زِرِّ بْنِ حُبَيْشٍ، عَنْ حُذَيْفَةَ، قَالَ سَأَلَتْنِي أُمِّي مَتَى عَهْدُكَ - تَعْنِي - بِالنَّبِيِّ صلى الله عليه وسلم . فَقُلْتُ مَا لِي بِهِ عَهْدٌ مُنْذُ كَذَا وَكَذَا . فَنَالَتْ مِنِّي فَقُلْتُ لَهَا دَعِينِي آتِي النَّبِيَّ صلى الله عليه وسلم فَأُصَلِّيَ مَعَهُ الْمَغْرِبَ وَأَسْأَلُهُ أَنْ يَسْتَغْفِرَ لِي وَلَكِ . فَأَتَيْتُ النَّبِيَّ صلى الله عليه وسلم فَصَلَّيْتُ مَعَهُ الْمَغْرِبَ فَصَلَّى حَتَّى صَلَّى الْعِشَاءَ ثُمَّ انْفَتَلَ فَتَبِعْتُهُ فَسَمِعَ صَوْتِي فَقَالَ " مَنْ هَذَا حُذَيْفَةُ " . قُلْتُ نَعَمْ . قَالَ " مَا حَاجَتُكَ غَفَرَ اللَّهُ لَكَ وَلأُمِّكَ " . قَالَ " إِنَّ هَذَا مَلَكٌ لَمْ يَنْزِلِ الأَرْضَ قَطُّ قَبْلَ هَذِهِ اللَّيْلَةِ اسْتَأْذَنَ رَبَّهُ أَنْ يُسَلِّمَ عَلَىَّ وَيُبَشِّرَنِي بِأَنَّ فَاطِمَةَ سَيِّدَةُ نِسَاءِ أَهْلِ الْجَنَّةِ وَأَنَّ **الْحَسَنَ وَالْحُسَيْنَ سَيِّدَا شَبَابِ أَهْلِ الْجَنَّةِ** " . هَذَا حَدِيثٌ حَسَنٌ غَرِيبٌ مِنْ هَذَا الْوَجْهِ لاَ نَعْرِفُهُ إِلاَّ مِنْ حَدِيثِ إِسْرَائِيلَ .

[8] ដកស្រង់ពី *ស៊ូហ៊្ហិះហ្ហ៍ អាល់-ប៊ូខ៊ូរី (صحيح البخاري)* ពីប្រភពព័ត៌មាន https://sunnah.com/bukhari:3543

حَدَّثَنَا أَحْمَدُ بْنُ يُونُسَ، حَدَّثَنَا زُهَيْرٌ، حَدَّثَنَا إِسْمَاعِيلُ، عَنْ أَبِي جُحَيْفَةَ ـ رضى الله عنه ـ قَالَ رَأَيْتُ النَّبِيَّ صلى الله عليه وسلم وَكَانَ الْحَسَنُ يُشْبِهُهُ.

អាប៊ូ យ៉ូហៃហ្វាស្ញ់ បានរាយការណ៍ថាខ្ញុំបានឃើញព្រះសាស្តា(صلى الله عليه وآله وسلم) អាល់-ហ្ហាសាន់ដូចព្រះអង្គ(صلى الله عليه وآله وسلم) ។

អាយ៉ាស់ព្រះគម្ពីរគួរអានពេលអល់ឡោះﷻបើកឲ្យដឹង ។ ព្រះសាស្តាមូហាំម៉ាដ់ﷺឆ្ងល់ណាស់ ព្រះរាជបុត្រីព្រះអង្គﷺ ព្រះនាងហ្វាទីម៉ាស់سلام الله عليها ចេះសូត្រពាក្យពេជន៍អាយ៉ាស់ដែលទើបនឹងបានបើកឲ្យដឹងនោះ ត្រឹមត្រូវឥតខុសមួយតួអក្សរឡើយថ្វីដ្បិតព្រះអង្គﷺពុំទាន់បានប្រាប់ព្រះនាងسلام الله عليهاឲ្យដឹងទេនោះ ។ ពេលព្រះអង្គﷺសួរព្រះនាងسلام الله عليهاថាចេះសូត្រអាយ៉ាស់នោះដូចម្តេច ព្រះនាងسلام الله عليهاបានទូលថាព្រះសន្តអ៊ីម៉ាំហ្វាសាន់صلوات الله عليه والسلامបានប្រាប់ព្រះនាងسلام الله عليهاឲ្យចេះសូត្រអាយ៉ាស់នោះ កាលព្រះអង្គصلوات الله عليه والسلامបានឮព្រះសាស្តាមូហាំម៉ាដ់ﷺសូត្រអាយ៉ាស់នេះ នៅឯម៉ាស់យ៊ីដ្ឋឲ្យគេស្តាប់ ។

ព្រះអង្គصلوات الله عليه والسلامមានទ្រព្យសម្បត្តិគ្រាន់បើ អាចរស់នៅក្នុងភាពសម្បូរ ក្នុងសេចក្តីស្រណុក តែព្រះអង្គصلوات الله عليه والسلامសុខចិត្តលះបង់ទ្រព្យដើម្បីជួយជនក្រីក្រ ជនតោកយ៉ាក ។ ពីរលើកក្នុងជីវិតព្រះអង្គصلوات الله عليه والسلام ព្រះអង្គصلوات الله عليه والسلامបានបរិច្ចាគទ្រព្យទាំងអស់ជាទាន ហើយបានកជីវិតថ្មីពីទទេ ។

គ្រាមួយ បុរសម្នាក់មកដល់គូហ្វាស់ សួរផ្លូវបុរសម្នាក់ដែលកំពុងប្រកបកិច្ចការក្នុងចម្ការ ។ បុរសនេះបានប្រាប់ផ្លូវគាត់ ហើយបានអញ្ជើញគាត់ទទួលទានអាហារ ។ បុរសរំភើបចិត្តដែលគេបានអញ្ជើញខ្លួន ក៏យល់ព្រម ។ តែពេលគេដាក់នំបុ័ងចាស់ឲ្យគាត់ពិសា នំបុ័ងនោះរឹងណាស់ ទោះបីកាច់បំបាក់វាដោយយកជង្គង់ទ្រាប់ក៏កាច់មិនបាក់ ខាំក៏មិនបែក ។ គាត់សាកដាក់វាត្រាំក្នុងទឹកក៏ពុំបានការ ។ បុរសអ្នកចម្ការឃើញគាត់មិនសូវស្រួលចិត្តក៏បង្ហាញគាត់ផ្ទះសំណាក់មួយដែលចែកអាហារឲ្យសាធារណជនដោយមិនគិតថ្លៃ ។

ផ្ទះសំណាក់ជារបស់អ៊ីម៉ាំហ្វាសាន់صلوات الله عليه والسلام ព្រះអង្គصلوات الله عليه والسلامទទួលបុរសប្លែកមុខដោយផ្ទាល់ បានដាក់អាហារក្តៅៗឲ្យគាត់ទទួលទាន ។ ក្រោយមកបន្តិច ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلامឃើញបុរសប្លែកមុខបរិភោគចំណីបន្តិច ហើយយកចំណីបន្តិចដាក់ទុកក្នុងថង់ ។ ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلامបានប្រាប់គាត់ឲ្យបរិភោគតាមសម្រួលចុះ គេនឹងឲ្យអាហារគាត់ថែមទៀតមុនគាត់ទៅវិញ បើគាត់ចង់យកទៅឲ្យគ្រួសារគាត់ ។ បុរសប្លែកមុខបានប្រាប់ព្រះអង្គصلوات الله عليه والسلامថាគាត់មិនមានគ្រួសារទេ តែគាត់ទុកអាហារបន្តិចសម្រាប់បុរសចិត្តល្អអ្នកចម្ការនៅឯក្បាលផ្លូវ ព្រោះគាត់មានតែនំបុ័ងរឹងសម្រាប់បរិភោគ ។ ពេលបានឮដូច្នេះ ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلامញញឹម ប្រាប់គាត់ថា៖ "បុរសនោះ

គឺព្រះបិតាខ្ញុំ صلوات الله عليه والسلام  អាលី صلوات الله عليه والسلام  ព្រះចៅខ៏លិហ្វរបស់មុស្លីម ។ ព្រះអង្គ صلوات الله عليه والسلام សោយតែអាហារសាមញ្ញដើម្បីនឹងកុំឲ្យជនគោកយ៉ាកណាមួយអៀនខ្មាសព្រះអង្គ صلوات الله عليه والسلام ។"

ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បានជួយជ្រោមជ្រែងព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام  មួយជីវិតលុះត្រាព្រះសន្តអ៊ីម៉ាំអាលី صلوات الله عليه والسلام សោយព្រះទិវង្គត   កាលព្រះអង្គ صلوات الله عليه والسلام មានព្រះជន្ម ៣៧  ព្រះវស្សា ។  ព្រះអង្គ صلوات الله عليه والسلام ស្នងព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلى الله عليه وآله وسلم ចាប់តាំងពីមានព្រះជន្មាយុ ៣៧ ព្រះវស្សានេះមក បានក្លាយទៅជាអាណាព្យាបាលរបស់អាស្ហ៍លុល-បៃត៍ عليهم السلام និងស្ហ៊ីអាស្ហ៍ ។ នៅក្នុងមរតកសាសន៍ដែលគេស្គាល់ច្បាស់នោះ អ៊ីម៉ាំអាលី صلوات الله عليه والسلام បានជ្រើសរើសព្រះអង្គ صلوات الله عليه والسلام ជាអ៊ីម៉ាំបន្ទាប់ព្រះអង្គ صلوات الله عليه والسلام ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. មរតកដែលព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ បានទុកឲ្យអ៊ីមុាំហាសាន់ صلوات الله عليه والسلام គឺអ្វី ?

២. កាលព្រះអង្គ صلوات الله عليه والسلام បានទៅជាអ៊ីមុាំ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام មានព្រះជន្មាយុប៉ុន្មានព្រះវស្សា ?

៣. ចូរលើកឡើងនូវទ្រព្យរបស់ព្រះអង្គ صلوات الله عليه والسلام ជាឧទាហរណ៍ ?

៤. ឋាន: (គឺឈ្មោះចំតើត) របស់ព្រះអង្គ صلوات الله عليه والسلام មានន័យថាអ្វី ?

៥. មានន័យថាអ្វី "អាល់-ហាសានូ វ៉ាល់-ហ៊ូសៃនូ សៃយីដ្ឋា ស្ហាបាប៊ី អាស្ស៉លិល-យ៉ាន់ណាស្ហ៊" ?

## មេរៀនទី ១៨

# អ៊ីមាំហាសាន់صلوات الله عليه والسلام - ភាគ ២

ទុក្ករកម្មរបស់អ៊ីម៉ាំអាលីصلوات الله عليه والسلامថ្ងៃទី ២១ ខែរ៉ម៉ាដន ឆ្នាំទី ៤០ សករាជហ៊ីជ្រ៉ោះគឺជាដើមអ៊ីម៉ាម៉ាស់របស់អ៊ីម៉ាំហាសាន់صلوات الله عليه والسلام ។ ប្រជារាស្ត្រមុស្លីមបានប្តេជ្ញាភ័ក្តីភាពចំពោះព្រះអង្គصلوات الله عليه والسلامនិងបានបង្គ្រប់កិច្ចសន្យាបៃអាស់ (بَيْعَةَ) ។ ឡើងកាន់តំណែងដឹកនាំភ្លាម ព្រះអង្គصلوات الله عليه والسلامត្រូវប្រឆាំង មូអាវីយ៉ាស់ ប៊ិន អាប៊ូ ស៊ុហ្វយ៉ានទេសាភិបាលរបស់ប្រទេសស៊ីរី ដែលចាប់ផ្តើមជាន់ឈ្លីព្រះអាជ្ញាធរព្រះអង្គصلوات الله عليه والسلام ។ ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلامបានសម្រេចទម្លាក់មូអាវីយ៉ាស់ពីតំណែងដោយកម្លាំង និងបានត្រៀមខ្លួនប្រយុទ្ធ ។ ព្រះអង្គصلوات الله عليه والسلامបានតែងតាំងអ្នកតំណាងព្រះអង្គصلوات الله عليه والسلامនៅគូហ្វាស់ ហើយបានទៅកាន់ នូខុយឡាស់ (النُخَيلَة) ព្រះអង្គصلوات الله عليه والسلامបានឲ្យប្រមូលទ័ពនៅទីនេះ ។ ១០ ថ្ងៃក្រោយមក ប្រមូលទ័ពបានតែ ៤០០០ នាក់ ។ ដូច្នេះ ព្រះអង្គصلوات الله عليه والسلامបានត្រឡប់ទៅគូហ្វាស់វិញ បានប្រកាសឲ្យប្រជារាស្ត្រចូលរួមក្នុងសមរភូមិម្តងទៀត ហើយបានចាត់បញ្ជូន ហ៊ុជ្រ៍ ប៊ិន អាឌី (حُجْر ٱبْن عَدِيّ) ទៅបំពេញបេសកកម្មតែមួយ ។

បន្តិចម្តងៗ ប្រជារាស្ត្របានឆ្លើយតបការអំពាវនាវឃ្យីហាដ់ ។ មនុស្សផ្សេងៗបានរួបរួមគ្នាជាកងទ័ពមួយ ។ ខ្លះជាស៊ីអាស់ស្មោះត្រង់ ខ្លះជាប្រជាជាតិខ៍វ៉ារីជ្ជដែលសង្ឃឹមផ្តួលមូអាវីយ៉ាស់ដោយប្រើគ្រប់មធ្យោបាយ ខ្លះទៀតជាមនុស្សដែលស្រឡាញ់ការប្រយុទ្ធនិងប៉ងប្រាថ្នាប្រមូលទ្រព្យសង្គ្រាម អ្នកខ្លះមិនជឿជាក់ទេថាព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلامមានសិទ្ធិពេញទីក្នុងការកាន់អំណាចខ៍លីហ្វាស់ អ្នកឯទៀតធ្វើតាមបង្គាប់មេដឹកនាំប្រជាជាតិខ្លួនទាំងងឹតងងល់មិនគិតដល់សាសនាទេ ។

ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلامបានថ្លែងទៅកាន់កងទ័ព ។ ព្រះអង្គصلوات الله عليه والسلامចាប់ផ្តើមដោយសម្តែងសេចក្តីគោរពអល់ឡោះហ៍عز وجلនិងព្រះសាស្តាصلى الله عليه وآله وسلم បន្ទាប់មកព្រះអង្គصلوات الله عليه والسلامថ្លែងប្រាប់ប្រជាពលរាស្ត្រថាព្រះអង្គصلوات الله عليه والسلامជាអ្នកណែនាំពិតប្រាកដរបស់ពួកគេ ហើយបានជំរុញពួកគេឲ្យរួបរួមគ្នាជាជាងបែកបាក់គ្នាជាពួក ។ អ្នកខ្លះយល់ខុសអំពីព្រះរាជសារនេះ ដោយគិតថាព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلامមានគម្រោងវាយយកអំណាចពី

កណ្តាប់ដៃមូអាវីយ៉ាស់ ។ កើតមានកុបកម្មរវាងប្រជាពលរាស្ត្រ ក្រុមមួយបានវាយប្រហារព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام នៅក្នុងជំរំព្រះអង្គ صلوات الله عليه والسلام ។ ពួកស្ហ៊ីអាស់បានប្រមូលគ្នាជុំវិញព្រះអង្គ صلوات الله عليه والسلام ការពារព្រះអង្គ صلوات الله عليه والسلام ។

ក្រោយមក ពេលលើកទ័ពទៅកាន់ប្រទេសស៊ីរី បុរសប្រជាជាតិ បានី អាសាដ្ម់ម្នាក់បានវាយប្រហារព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ដោយពូថៅចំចង្កេះ ។ រងរបួស ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ចាំបាច់ត្រូវឈប់នៅឯ ម៉ាដ្ហាអ៊ីន (المدائن) ព្រះអង្គ صلوات الله عليه والسلام បានចាត់បញ្ជូនពីទីនេះ អ៊ូបៃឌុលឡោះហ៍ ប៊ិន អាប់បាស់ ជាមួយរេហ៍ពល ១២០០០ នាក់ទៅទប់ស្កាត់មូអាវីយ៉ាស់ដែលកំពុងលើកទ័ពទៅកាន់អ៊ីរ៉ាក់ ។

មូអាវីយ៉ាស់សូកប៉ាន់បានសម្រេច បក្សពួកច្រើននាក់របស់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ឲ្យរលាស់ចោលព្រះអង្គ صلوات الله عليه والسلام រាប់បញ្ចូល អ៊ូបៃឌុលឡោះហ៍ ផ្ទាល់តែម្តងដែលត្រូវគេសូកប្រាក់មួយលានដៀរហ៊ាំឲ្យក្បត់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ។

ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ដឹងថា មិនអាចទុកចិត្តលើបក្សពួកភាគច្រើនរបស់ព្រះអង្គ صلوات الله عليه والسلام បានទេ មានតែស្ហ៊ីអាស់របស់ព្រះអង្គ صلوات الله عليه والسلام ទេដែលព្រះអង្គ صلوات الله عليه والسلام អាចទុកចិត្តបានដែលមានចំនួនតិចដើម្បីតស៊ូទល់នឹងយុទ្ធជនស៊ីរីនោះ ។ ព្រមនឹងពេលនោះ មូអាវីយ៉ាស់បានផ្ញើសំបុត្រមកព្រះអង្គ صلوات الله عليه والسلام ស្នើសូមធ្វើកិច្ចព្រមព្រៀងសន្តិភាពតាមលក្ខខណ្ឌរបស់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ។

ប្រតិបត្តិតាមព្រះឆន្ទៈរបស់អល់ឡោះហ៍ عز وجل និងមានបំណងចៀសវាងការបង្ហូរឈាមមុស្លីមស្មោះត្រង់ ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ព្រមចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងសន្តិភាពជាមួយមូអាវីយ៉ាស់ ដោយដាក់លក្ខខណ្ឌដើម្បីការពារអ៊ីស្លាមនិងដើម្បីបញ្ឈប់សង្គ្រាមស៊ីវិល (ច្បាំងគ្នាឯង) ។ លក្ខខណ្ឌកិច្ចព្រមព្រៀងសន្តិភាពមានដូចតទៅគឺ៖

១. មូអាវីយ៉ាស់នឹងប្រព្រឹត្តចំពោះមនុស្សទូទៅតាមព្រះគម្ពីរគួរអាន និងតាមស៊ុនណាស់ព្រះសាស្តា صلى الله عليه وآله وسلم ។

២. មូអាវីយ៉ាស់នឹងមិនតែងតាំងអ្នកណាមួយជាអ្នកស្នងខ្លួនទេ ។

៣. គ្រួសាររបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام និងស្ហ៊ីអាស់របស់គ្រួសារអ៊ីម៉ាំអាលី صلوات الله عليه والسلام នៅក្រោមការការពារ (មិនត្រូវប៉ះពាល់ទេ) ។

៤. មូអាវីយ៉ាស់ត្រូវបង់ប្រាក់ ៥០០០០ ដៀរហ៊ាំរៀងរាល់ឆ្នាំពីប្រាក់ចំណូលរដ្ឋឲ្យទៅព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ។

៥. មិនត្រូវធ្វើការជេរប្រមាថ ទៅលើអ៊ីម៉ាំអាលី صلوات الله عليه والسلام និងបណ្ដាអ្នកតាមព្រះអង្គ صلوات الله عليه والسلام ទេក្រោយស៊ូឡាត់ថ្ងៃសុក្រ ។

មូអាវីយ៉ាស់ព្រមទទួលលក្ខខណ្ឌទាំងអស់ លើកលែងតែខចុងក្រោយ តែយល់ព្រមមិនជេរប្រមាថអ៊ីម៉ាំអាលី صلوات الله عليه والسلام ចំពោះមុខព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ទេ ។ យូរទៅៗ មូអាវីយ៉ាស់ល្មើសលក្ខខណ្ឌគ្រប់ខរបស់កិច្ចព្រមព្រៀង ។

ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ឆ្លៀតយកឱកាសនេះដើម្បីពង្រឹងជំនឿពួកមុស្លីម និងបង្កើនការចេះដឹងរបស់ពួកគេអំពីអ៊ីស្លាម ។ ព្រះអង្គ صلوات الله عليه والسلام បានត្រឡប់ទៅម៉ាឌីណាស់វិញ នៅទីនោះព្រះអង្គ صلوات الله عليه والسلام ឆ្លើយតបសំណួររបស់ប្រជារាស្ត្ររឿងសាសនានិងបានលះបង់ជីវិតដើម្បីផ្សាយសាសនាអ៊ីស្លាម ។

មូអាវីយ៉ាស់មិនស្ដាប់ស្ដល់ទេ ។ គាត់ដឹងថាកិច្ចព្រមព្រៀងសន្តិភាពមិនមានន័យថាព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام លាលែងពីតំណែងនោះទេ ព្រោះព្រះអង្គ صلوات الله عليه والسلام ត្រូវអល់ឡោះហ៊ូ عز وجل តែងតាំងជាអ៊ីម៉ាំ ។

នេះគ្រាន់តែជាការផ្ទេរតំណែងគ្រប់គ្រងរដ្ឋអ៊ីស្លាម បណ្ដោះអាសន្នប៉ុណ្ណោះ ប្រសិនបើតំណែងនេះបានទៅព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បន្ទាប់ពីមូអាវីយ៉ាស់ស្លាប់ បន្ទាប់មកតំណែងនឹងត្រូវផ្ទេរឲ្យទៅអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ។ តែមូអាវិយ៉ាស់បានគ្រោងទុកមុនជាស្រេចថានឹងតែងតាំងកូនប្រុសខ្លួនឈ្មោះ យ៉ាស៊ីដ្ឋ ជាអ្នកស្នងខ្លួន ។ ដូច្នេះ គាត់សម្រេចកម្ចាត់ចោលព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام មុនគេ ។

ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام មានមហេសីម្នាក់ឈ្មោះ យ៉ាក់ដ្ហាស់ ប៊ិនទី អាល់-អាស្អ៊ាស្ហ៍ ប៊ិន ក្វយ់ស៍ (جَعْدَةُ بِنْتُ اَلْأَشْعَثِ بْنِ قَيْسٍ اَلْكِنْدِيِّ) ។ មូអាវីយ៉ាស់បានរួមគំនិតក្បត់ជាមួយព្រះនាងយ៉ាក់ដ្ហាស់ដើម្បីដាក់ថ្នាំបំពុលព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ។ ត្រឡប់វិញព្រះនាងយ៉ាក់ដ្ហាស់នឹងបានទទួលប្រាក់ ១០០ ០០០ ដៀរហ្ហាំ ហើយនឹងបានរៀបការជាមួយកូនប្រុសរបស់មូអាវីយ៉ាស់ឈ្មោះយ៉ាស៊ីដ្ឋ ។ នារីបិសាចរូបនេះបានដាក់ថ្នាំបំពុលក្នុងកែវទឹកព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ក៏បានធ្លាក់ព្រះកាយឈឺធ្ងន់ ។ ក្រោយពីបានឈឺចាប់ខ្លាំង ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បានចាកចោលលោកនេះ ។ មុនសោយព្រះទិវង្គត ព្រះអង្គ صلوات الله عليه والسلام បានផ្ទេរមុខតំណែងអ៊ីម៉ាម៉ាស់ឲ្យទៅប្អូនប្រុសព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام បានឲ្យព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ទៅជាអាណាព្យាបាលរបស់គ្រួសារព្រះអង្គ صلوات الله عليه والسلام ។

ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام បានឲ្យគេនាំព្រះរាជសពព្រះអង្គ صلوات الله عليه والسلام ទៅឯផ្នូរព្រះសាស្តា មូហ៊ាំម៉ាដ្ធ صلى الله عليه وآله وسلم ដើម្បីស៊ុំរ៉ាស្ទ់ជាលើកចុងក្រោយបង្អស់ មុនបញ្ចុះព្រះរាជសពព្រះអង្គ صلوات الله عليه والسلام នៅឯ យ៉ាណាទុល-បាគ្វីអ៍ (جنت البقيع) ។ ពេលពួក បានី ហាស៊ីម ធ្វើតាមបណ្តាំចុងក្រោយរបស់ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام អ៊ែស្វាស្ទ់និងសមាជិក បានី អ៊ូម៉ៃយ៉ាស្ទ់ ច្រើននាក់បានហាមឃាត់ ដោយគិតថាគេនឹងបញ្ចុះព្រះរាជសពរបស់ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ក្បែរព្រះអយ្យកោ صلى الله عليه وآله وسلم ព្រះអង្គ صلوات الله عليه والسلام ។ អ៊ីមុាំហ៊ូសៃន៍ صلوات الله عليه والسلام មិនចង់ឲ្យមានការបង្ហូរឈាមទេ ដូច្នេះព្រះអង្គ صلوات الله عليه والسلام បានឲ្យនាំព្រះរាជសពរបស់ព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ទៅកាន់យ៉ាណាទុល-បាគ្វីអ៍ តែម្តង ។ ព្រះរាជសពព្រះអង្គ صلوات الله عليه والسلام ត្រូវបញ្ចុះនៅទីនេះក្បែរយាយព្រះអង្គ صلوات الله عليه والسلام ព្រះនាង ហ្វាទីម៉ាស្ទ់ ប៊ិនទី អាសាដ្ធ ។ ព្រះអង្គ صلوات الله عليه والسلام មានព្រះជន្មាយុ ៤៨ ព្រះវស្សាកាលព្រះអង្គ صلوات الله عليه والسلام បានធ្វើទុក្ករកម្មដោយលះបង់ព្រះជន្ម ។

ពេលព្រះនាង យ៉ាក្ទ៌ដាស្ទ់ ទៅទាររង្វាន់ មូអាវីយ៉ាស្ទ់បានប្រគល់ប្រាក់ឲ្យព្រះនាងតែមិនព្រមរៀបការព្រះនាងជាមួយយ៉ាស៊ីដ្ធទេ ដោយអះអាងថាស្ត្រីដែលហ៊ានដាក់ថ្នាំបំពុលស្វាមីខ្លួនឯងនោះ ច្បាស់ជាមិនញញើតដាក់ថ្នាំបំពុលស្វាមីម្នាក់ទៀតជាដាច់ខាត ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ព្រមចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងសន្តិភាពជាមួយមូអាវីយ៉ាស់ ?

២. មូអាវីយ៉ាស់បានធ្វើដូចម្ដេច ដើម្បីញុះញង់បក្សពួករបស់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ឲ្យចោលព្រះអង្គ صلوات الله عليه والسلام ?

៣. អ៊ីម៉ាម៉ាស់របស់អ៊ីម៉ាំហាសាន់ صلوات الله عليه والسلام មានរយៈពេលប៉ុន្មានឆ្នាំ ?

៤. អ្នកណាដាក់ថ្នាំបំពុលព្រះអង្គ صلوات الله عليه والسلام ?

៥. ហេតុអ្វីអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام មិនតវ៉ា ដើម្បីនាំព្រះរាជសពបងព្រះអង្គ صلوات الله عليه والسلام ទៅឯផ្នូរព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ?

## មេរៀនទី ១៩

# អ៊ីមាំហ៊្វូសែន៍ صلوات الله عليه والسلام - ភាគ ១

| | |
|---|---|
| ឈ្មោះ | : ហ៊្វូសែន៍ |
| ឋានៈ | : សៃយីឌុស្ស-ស៊្ហូហាដា (سَيِّدُ الشُّهَدَاءِ អគ្គប្រមុខរបស់បណ្ដាទុក្ករបុគ្គល) |
| ឈ្មោះក្រៅ | : អាប៊ូ អ៊ុាប់ឌុលឡោះហ្ន៍ (أبو عبد الله) |
| បិតា | : អ៊ីមុាំអ៊ុាលី صلوات الله عليه والسلام |
| មាតា | : សៃយីដ្ហាស្ទ ហ្វាទីម៉ាស្ទ ស្ហាស្ទររ៉អ៍ سلام الله عليها |
| កំណើត | : ថ្ងៃទី ៣ ខែ ស្ហាក់បាន ឆ្នាំ ៤ សករាជហ៊ីជ្រ៉ោះត៍ នៅម៉ាឌីណាស្ទ |
| អ៊ីម៉ាម៉ាស្ទ | : ពីឆ្នាំទី ៥០ សករាជហ៊ីជ្រ៉ោះត៍ ដល់ឆ្នាំទី ៦១ សករាជហ៊ីជ្រ៉ោះត៍ |
| ទុក្ករកម្ម | : ថ្ងៃទី ១០ ខែមូហារ៉ម ឆ្នាំ ៦១ សករាជហ៊ីជ្រ៉ោះត៍ |
| ទីបញ្ចុះសព | : ការបាឡាអ៍ ប្រទេស អ៊ីរ៉ាក់ |

ព្រះសន្តអ៊ីមុាំហ៊្វូសែន៍ صلوات الله عليه والسلام ជាព្រះរាជបុត្រទីពីររបស់អ៊ីមុាំអ៊ុាលី صلوات الله عليه والسلام និង សៃយីដ្ហាស្ទ ហ្វាទីម៉ាស្ទ ស្ហាស្ទររ៉អ៍ سلام الله عليها ។ ព្រះអង្គ صلوات الله عليه والسلام ជាអ៊ីមុាំទីបីរបស់យើង ។ កំណើតព្រះអង្គ صلوات الله عليه والسلام ជាឱកាសរីករាយដ៏ឱឡារិកសម្រាប់អាស្ហ៍លុល-បៃត៍ عليهم السلام គេធ្វើពិធីបុណ្យកំណើតនេះទាំងនៅលើផែនដីទាំងនៅលើមេឃ ។ ពេលបាន ទទួលដំណឹង ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ صلى الله عليه وآله وسلم បានមកសូត្រអាស្ហាននិងអ៊ីក៏ម៉ាស្ទដាក់ត្រចៀកស្ដាំនិងត្រចៀកឆ្វេងរបស់ព្រះរាជទារកទើបនឹងកើត ។ ក្រោយពីប្រសូតបាន ៧ ថ្ងៃ គេបានធ្វើពិធីបុណ្យ អ៊ុាគ្គីក្វោះត៍ (عقيقة) បានដាក់ព្រះនាមឲ្យព្រះរាជទារកថា អាល់-ហ៊្វូសែន៍ (الْحُسَيْن) ។

ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ صلى الله عليه وآله وسلم បានដាក់ឈ្មោះឲ្យព្រះរាជនត្តាព្រះអង្គ صلى الله عليه وآله وسلم តាមព្រះបង្គាប់របស់អល់ឡោះហ្ន៍ عز وجل ។ បងប្រុសរបស់ព្រះសាស្ដាមូសា عليه السلام ព្រះសាស្ដាហ្ហារូន عليه السلام មានព្រះរាជបុត្រពីរនាក់ដែរឈ្មោះ ស្ហាប់បារ (شَبَّر) និង ស្ហាប់បៀរ (شَبِير) ។ ឈ្មោះរបស់កូនប្រុសទាំងពីររបស់អ៊ីមុាំអ៊ុាលី صلوات الله عليه والسلام ជាភាសាអារ៉ាប់ស្មើនឹងឈ្មោះពីរជាភាសាអ៊ីសរ៉អ៊ីលស្ហាប់បារនិងស្ហាប់បៀរ ។ គោលបំណងគឺចង់បង្ហាញ

នូវទំនាក់ទំនងរវាងអ៊ីម៉ាំអាលី صلوات الله عليه والسلام និងព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ដែលមានព្រះវចនៈថា៖ "អាលី صلوات الله عليه والسلام អឺយ ទំនាក់ទំនងរវាងអ្នក صلوات الله عليه والسلام និងខ្ញុំ صلى الله عليه وآله وسلم ដូចទំនាក់ទំនងរវាងហារូន عليه السلام និងមូសា عليه السلام លើកលែងតែពុំមានសាស្ដាទេអត់ពីខ្ញុំ صلى الله عليه وآله وسلم ទៅ ។" ពាក្យពេជន៍ទាំងនេះសឲ្យឃើញថា អ៊ីម៉ាំអាលី صلوات الله عليه والسلام មានសារៈសំខាន់ដូចព្រះសាស្ដាហារូន عليه السلام បងប្រុសនិងអ្នកស្នងរបស់ព្រះសាស្ដាមូសា عليه السلام ដែរ ។

ថ្ងៃដែលព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ប្រសូត អល់ឡោះហ៊្ វ عز وجل បានឲ្យទេវតាយ៉ីបរ៉អ៊ីល عليه السلام ចុះមកថ្លែងសេចក្ដីអបអរសាទរសរសើរព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ក្នុងព្រះនាមព្រះអង្គ عز وجل ។

ពេលចុះមក យ៉ីបរ៉អ៊ីល عليه السلام បានកាត់តាមកោះមួយដែលអល់ឡោះហ៊្វ عز وجل បានបោះបង់ទេវតាឈ្មោះ ហ្វិត្ទុរុស (فُطْرُس) ព្រោះហ្វិត្ទុរុសយឺតយាវប្រតិបត្តិព្រះបញ្ជាអល់ឡោះហ៊្វ عز وجل ។ ចាប់ពីពេលនោះមកហ្វិត្ទុរុសគ្មានស្លាប ហើយត្រូវដាក់ឲ្យនៅលើកោះនេះ ។ ហ្វិត្ទុរុសបានបួងសួងអល់ឡោះហ៊្វ عز وجل អស់ច្រើនឆ្នាំ អង្វរព្រះអង្គ عز وجل សូមខមាទោស ។

ពេលឃើញយ៉ីបរ៉អ៊ីល عليه السلام ហ្វិត្ទុរុសបានសួរព្រះអង្គ عليه السلام ថាទៅណា ។ យ៉ីបរ៉អ៊ីល عليه السلام បានប្រាប់ហ្វិត្ទុរុសថា ព្រះអង្គ عليه السلام ទៅឯលំនៅរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ដើម្បីថ្លែងសេចក្ដីអបអរសាទរ សរសើរព្រះអង្គ صلوات الله عليه والسلام ថ្ងៃប្រសូតព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ។ ពេលបានឮដូច្នេះ ហ្វិត្ទុរុសបានសូមថា៖ "ព្រះអង្គ عليه السلام អាចជួយយកទូលបង្គំទៅជាមួយព្រះអង្គ عليه السلام បានទេ ? ប្រហែលជាមូហាំម៉ាដ់ صلى الله عليه وآله وسلم អាចជួយនិយាយរឿងទូលបង្គំប្រាប់អល់ឡោះហ៊្វ عز وجل បាន ។"

ទេវតាទាំងពីរអង្គមកដល់លំនៅរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام យ៉ីបរ៉អ៊ីល عليه السلام បានប្រាប់ឲ្យជ្រាបព្រះរាជសាររបស់អល់ឡោះហ៊្វ عز وجل បន្ទាប់មកបានថ្លែងរឿងហ្វិត្ទុរុស ។ ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ចូរឲ្យទេវតាប៉ះខ្លួនទារក ហើយត្រឡប់ទៅកាន់កន្លែងខ្លួនវិញនៅលើមេឃ ។"

ធ្វើតាមព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ប្រាប់ ហ្វិត្ទុរុសក៏មានស្លាបវិញភ្លាម ហើយបានឡើងទៅលើមេឃដោយសន្យាព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ថា៖ "ហ៊ូសែន៍ صلوات الله عليه والسلام អឺយ ចាប់ពីថ្ងៃនេះតរៀងទៅ អ្នកណាផ្ញើសាឡាមមកព្រះអង្គ صلوات الله عليه والسلام ទូលបង្គំនឹងនាំសាឡាមនោះមកឲ្យព្រះអង្គ صلوات الله عليه والسلام ដោយខ្លួនឯង ។"

ប្រាំពីរឆ្នាំដំបូងនៃជីវិតព្រះអង្គ صلوات الله عليه والسلام ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام បានធាត់ធំនៅក្រោមការណែនាំរបស់ព្រះអយ្យកោ صلى الله عليه وآله وسلم ព្រះអង្គ صلوات الله عليه والسلام ដែលស្រឡាញ់ព្រះអង្គ صلوات الله عليه والسلام ណាស់ ។ ព្រះអង្គ صلى الله عليه وآله وسلم មានព្រះវចនៈជាញឹកញយថា៖ "ហ៊ូសែន៍ صلوات الله عليه والسلام ចេញពីខ្ញុំ صلى الله عليه وآله وسلم ខ្ញុំ صلى الله عليه وآله وسلم ចេញពីហ៊ូសែន៍ صلوات الله عليه والسلام (ពោលគឺ សាច់តែមួយ)[9] ។" គ្រាមួយ ព្រះអង្គ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ហ៊ាសាន់ صلوات الله عليه والسلام និងហ៊ូសែន៍ صلوات الله عليه والسلام ជាព្រះអគ្គប្រមុខរបស់យុវជនឋានសួគ៌ ។ សម័យមូបាហាឡាស្ហ៍ ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم បាននាំព្រះសន្តអ៊ីម៉ាំហ៊ាសាន់ صلوات الله عليه والسلام និងព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ទៅជាមួយព្រះអង្គ صلى الله عليه وآله وسلم ក្នុងឋានៈជាកូនៗរបស់ព្រះអង្គ صلى الله عليه وآله وسلم ។

ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈដែរថា៖ "ហ៊ាសាន់ صلوات الله عليه والسلام និងហ៊ូសែន៍ صلوات الله عليه والسلام ជាអ៊ីម៉ាំ ទោះបីពួកគេ عليهم السلام ឈរឬអង្គុយក៏ដោយ ។" ពាក្យពេជន៍នេះមានសេចក្ដីថាគេត្រូវស្ដាប់បង្គាប់ព្រះរាជនត្ដាទាំងពីរ عليهم السلام របស់ព្រះអង្គ صلى الله عليه وآله وسلم ទោះបីព្រះអង្គទាំងពីរ عليهم السلام អង្គុយស្ងៀមក្នុងសន្តិភាពក៏ដោយ ទោះបីព្រះអង្គទាំងពីរ عليهم السلام ចេញទៅច្បាំងក៏ដោយ ។

ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام មានគុណសម្បត្តិ ដូចព្រះបិតាមាតា عليهم السلام ព្រះអង្គ صلوات الله عليه والسلام ដែរ ។ ព្រះអង្គ صلوات الله عليه والسلام មានចិត្តទូលំទូលាយ តែមិនអត់ឱនឲ្យគេរំលោភគោលសាសនាអ៊ីស្លាមទេ ។

អ្នកណាក៏ដឹងដែរថាព្រះអង្គ صلوات الله عليه والسلام មានចិត្តបុណ្យទូលំទូលាយ ។ ព្រះអង្គ صلوات الله عليه والسلام

---

[9] ដកស្រង់ពី *យ៉ាមិអ៍ អាល់-តៀរមីស៊ី (جامع الترمذي)* https://sunnah.com/tirmidhi/49/174 ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈដូចតទៅគឺ៖

حَدَّثَنَا الْحَسَنُ بْنُ عَرَفَةَ، قَالَ حَدَّثَنَا إِسْمَاعِيلُ بْنُ عَيَّاشٍ، عَنْ عَبْدِ اللَّهِ بْنِ عُثْمَانَ بْنِ خُثَيْمٍ، عَنْ سَعِيدِ بْنِ رَاشِدٍ، عَنْ يَعْلَى بْنِ مُرَّةَ، قَالَ قَالَ رَسُولُ اللَّهِ صلى الله عليه وسلم " **حُسَيْنٌ مِنِّي وَأَنَا مِنْ حُسَيْنٍ أَحَبَّ اللَّهُ مَنْ أَحَبَّ حُسَيْنًا حُسَيْنٌ سِبْطٌ مِنَ الأَسْبَاطِ** " . قَالَ أَبُو عِيسَى هَذَا حَدِيثٌ حَسَنٌ وَإِنَّمَا نَعْرِفُهُ مِنْ حَدِيثِ عَبْدِ اللَّهِ بْنِ عُثْمَانَ ابْنِ خُثَيْمٍ وَقَدْ رَوَاهُ غَيْرُ وَاحِدٍ عَنْ عَبْدِ اللَّهِ بْنِ عُثْمَانَ بْنِ خُثَيْمٍ .

យ៉ាក់ឡា ប៊ិន មូរ៉ោះត៍បានរាយការណ៍ថាព្រះសាស្ដា صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ហ៊ូសែន៍ចេញពីខ្ញុំ صلى الله عليه وآله وسلم ខ្ញុំ صلى الله عليه وآله وسلم ចេញពីហ៊ូសែន៍ صلوات الله عليه والسلام ។ អល់ឡោះហ៍ عز وجل ស្រឡាញ់អ្នកណាដែលស្រឡាញ់ហ៊ូសែន៍ صلوات الله عليه والسلام ។ ហ៊ូសែន៍ صلوات الله عليه والسلام ជាស៊ីបត្ធ៍មួយក្នុងចំណោមស៊ីបត្ធ៍ទាំងឡាយ ។" [អាស់បាត្ធ៍ ជាពហុវចនៈរបស់ ស៊ីបត្ធ៍ មានន័យថា ប្រជាជាតិធំ ។ បានសេចក្ដីថា អាល់-ហ៊ូសែន៍ صلوات الله عليه والسلام នឹងមានបណ្ដាកូនចៅច្រើន ទៅជាប្រជាជាតិដ៏ធំមួយ ។ ក្រោយមក រឿងនេះក៏បានទៅជាពិតមែន ។ សូមមើលសៀវភៅ *ទូហ្វាស្ហ៍ អាល់-អាស្ហ៍វ៉ាស៊ី (تحفة الأحوذي)* (4/341)]

ចូលចិត្តបំពេញសេចក្តីត្រូវការរបស់បុគ្គលដែលមកសូមប្រាក់ព្រះអង្គ صلوات الله عليه والسلام ដោយស្ងាត់ៗ (បាំងខ្លួនពីក្រោយរាំងនន) ជានិច្ច ព្រោះព្រះអង្គ صلوات الله عليه والسلام មិនចង់ឲ្យគេអៀនខ្មាសទេដោយនៅទល់មុខបុគ្គលអ្នកបរិច្ចាគទានឲ្យមកខ្លួន ។

ព្រះសន្តអ៊ីម៉ាំហ៊្ជូសែន៍ صلوات الله عليه والسلام មើលថែរក្សាស្ត្រីមេម៉ាយ និងកូនកំព្រាច្រើនដោយខ្លួនឯង ។ ពេលយប់ ព្រះអង្គ صلوات الله عليه والسلام លីថង់ស្បៀងទៅចែកឲ្យជនតោកយ៉ាក ។ ក្រោយពីព្រះអង្គ صلوات الله عليه والسلام សោយព្រះទិវង្គត គេឃើញមានស្លាកស្នាមនៅលើស្មាព្រះអង្គ صلوات الله عليه والسلام ដោយសារទម្ងន់ថង់ស្បៀងទាំងនេះ ។

ព្រះសន្តអ៊ីម៉ាំហ៊្ជូសែន៍ صلوات الله عليه والسلام មានព្រះបិតា صلوات الله عليه والسلام នៅក្បែរ និងបានទទួលការណែនាំពីព្រះអង្គ صلوات الله عليه والسلام រហូតដល់ព្រះអង្គ صلوات الله عليه والسلام មានព្រះជន្ម ៣៦ ព្រះវស្សា ។ ១០ ឆ្នាំកន្លងមក ព្រះអង្គ صلوات الله عليه والسلام បានបម្រើអ៊ីម៉ាំហាសាន់ صلوات الله عليه والسلام បងប្រុសព្រះអង្គ صلوات الله عليه والسلام ។ ពេលសោយព្រះទិវង្គត ព្រះសន្តអ៊ីម៉ាំហាសាន់ صلوات الله عليه والسلام បានតែងតាំងព្រះសន្តអ៊ីម៉ាំហ៊្ជូសែន៍ صلوات الله عليه والسلام ជាអ្នកស្នងព្រះអង្គ صلوات الله عليه والسلام ហើយបានផ្ទេរភារកិច្ចអ៊ីម៉ាម៉ាស់ឲ្យទៅព្រះអង្គ صلوات الله عليه والسلام ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីទេវតា ហ្វិត្រុស បាត់បង់ស្លាប ?

២. ពេលមានស្លាបវិញ ហ្វិត្រុស បានសន្យាអ្វីឲ្យអ៊ីមុាំហ៊្វូសែន៍صلوات الله عليه والسلام ?

៣. អ៊ីមុាំហ៊្វូសែន៍صلوات الله عليه والسلامអាយុប៉ុន្មានកាលព្រះអង្គصلوات الله عليه والسلامទៅជាអ៊ីមុាំ ?

៤. ហេតុអ្វីព្រះអង្គصلوات الله عليه والسلامជួយមនុស្សពីខាងក្រោយរាំងនន ?

៥. សម្តីរបស់ព្រះសាស្តាមូហុាំម៉ាដ់صلى الله عليه وآله وسلم "ហ៊្វាសាន់صلوات الله عليه والسلامនិងហ៊្វូសែន៍صلوات الله عليه والسلامជាអ៊ីមុាំ ទោះបីពួកគេعليهم السلامឈរឬអង្គុយក៏ដោយ" មានន័យថាអ្វី ?

## មេរៀនទី ២០

# អ៊ីមាំហ៊្សៃសែន៍ صلوات الله عليه والسلام - ភាគ ២

ឆ្នាំ ៥០ សករាជហ៊ីជ្រ៉ោះត៏ កាលព្រះរៀម صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ព្រះសន្តអ៊ីមុាំហ្ហាសាន់ صلوات الله عليه والسلام សោយព្រះទិវង្គត ព្រះសន្តអ៊ីមុាំហ៊្សៃសែន៍ صلوات الله عليه والسلام បានទទួលភារកិច្ចអ៊ីម៉ាម៉ាស់ ។ បណ្តាំចុងក្រោយរបស់ព្រះសន្តអ៊ីមុាំហ្ហាសាន់ صلوات الله عليه والسلام គឺឲ្យបញ្ចុះព្រះរាជសពព្រះអង្គ صلوات الله عليه والسلام នៅឯយ៉ាណាទុល-បាគ្គីអ៉ បន្ទាប់ពីបានទៅស៊ុរ៉ាស់ព្រះរាជកោដ្ឋព្រះសាស្តាមូហ៊ាំម៉ាដ្ឋ صلى الله عليه وآله وسلم រួច ។ ពេលព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ចង់ធ្វើតាមបណ្តាំចុងក្រោយនេះ ពួកបានី អ៊្វម៉ៃយ៉ាស់បានហាមឃាត់ព្រះអង្គ صلوات الله عليه والسلام ។ បក្សពួកពួកគេម្នាក់ឈ្មោះម៉ារវ៉ាន ដែលជាអតីតលេខារបស់អ៊ុស្មម៉ាននោះ បានថា៖ "ហេតុអ្វីអ៊ុស្មម៉ានត្រូវកប់នៅក្រៅម៉ាឌីណាស់ ហ្ហាសាន់ صلوات الله عليه والسلام ត្រូវកប់ក្បែរព្រះសាស្តា صلى الله عليه وآله وسلم អល់ឡោះហ៊្វ عز وجل ?" អៃស្សាស់ មហេសីមេម៉ាយរបស់ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ صلى الله عليه وآله وسلم បានជិះសេះទេសមកកាន់ទីនោះ ទាមទារឲ្យយកព្រះរាជសពព្រះសន្តអ៊ីមុាំហ្ហាសាន់ صلوات الله عليه والسلام ចេញឆ្ងាយពីទីនោះ ។ អ៊ាប់ឌុលឡោះហ្វ៍ ប៊ិន អ៊ាប់បាស់ បានតបអៃស្សាស់វិញថា៖ "ព្រះនាងហៃបង្កអន្តរាយមែន! ថ្ងៃមួយលើសេះទេស ថ្ងៃមួយលើអូដ្ឋ!" ព្រះសន្តអ៊ីមុាំហ្ហាសាន់ صلوات الله عليه والسلام មានវចនៈដាក់ពួកបានី អ៊្វម៉ៃយ៉ាស់ថា៖ "សូមស្បថចំពោះអល់ឡោះហ៊្វ عز وجل ! បើព្រះរៀម صلوات الله عليه والسلام ខ្ញុំ صلوات الله عليه والسلام មិនបានប្រាប់ខ្ញុំ صلوات الله عليه والسلام ឲ្យចៀសវាងការបង្ហូរឈាមទេ ពួកអ្នកប្រាកដជានឹងបានដឹងថា ដាវយើងនឹងដកសិទ្ធិដើរកាត់ដីគេពីពួកអ្នកដូចម្តេច ។" បន្ទាប់មក ព្រះអង្គ صلوات الله عليه والسلام បាននាំព្រះរាជសពព្រះសន្តអ៊ីមុាំហ្ហាសាន់ صلوات الله عليه والسلام ទៅឯយ៉ាណាទុល-បាគ្គីអ៉ ។

ព្រះសន្តអ៊ីមុាំហ៊្សៃសែន៍ صلوات الله عليه والسلام បានឡើងកាន់តំណែងអ៊ីម៉ាម៉ាស់ ក្នុងសម័យលំបាកខ្លាំងសម្រាប់មុស្លីម ជាពិសេសសម្រាប់ស្ហ៊ីអាស់ ។ មូអាវីយ៉ាស់ស្វះស្វែងបង្កជម្លោះ ។ ស្ហ៊ីអាស់ប្រទេសអ៊ីរ៉ាក់បានទៅជួបព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ចង់សូមសច្ចាស្មោះស្ម័គ្រចំពោះព្រះអង្គ صلوات الله عليه والسلام តែព្រះអង្គ صلوات الله عليه والسلام បានរំលឹកពួកគេថាពួកគេជាប់ពាក់ព័ន្ធក្នុងកិច្ចព្រមព្រៀង រវាងព្រះសន្តអ៊ីមុាំហ្ហាសាន់ صلوات الله عليه والسلام និងមូអាវីយ៉ាស់នៅឡើយ

ក្រោយពីមូអាវីយ៉ាស្លាប់ទើបអាចគិតគូរសាឡើងវិញបាន ។ ចំណែកឯមូអាវីយ៉ាស្ស៍វិញបានរំលោភខសន្យាទាំងអស់របស់កិច្ចព្រមព្រៀង នៅសល់តែប្រការចុងក្រោយមួយគត់ដែលមូអាវីយ៉ាស្ស៍ត្រូវធ្វើ គឺតែងតាំងកូនប្រុសខ្លួនឈ្មោះយ៉ាស៊ីដ្ធជាអ្នកស្នង ។ បញ្ហាគឺយ៉ាស៊ីដ្ធមិនស័ក្តិសមកាន់អំណាចទេ មូអាវីយ៉ាស្ស៍និងបក្សពួកខ្លួនក៏ដឹងបញ្ហានេះច្បាស់ដែរ ។ ដូច្នេះ មូអាវីយ៉ាស្ស៍បានលះបង់មួយជីវិតខ្លួនដើម្បីផ្តល់អំណាចខ៉លីហ្វាស្ស៍ឲ្យកូនប្រុសមិនស័ក្តសមរបស់ខ្លួន ។ បន្តិចម្តងៗដោយសូក ដោយគំរាមកំហែងនិងដោយសម្លាប់អ្នកប្រឆាំង មូអាវីយ៉ាស្ស៍ជិតទៅដល់គោលដៅ ។ ព្រមនឹងពេលនោះ ព្រះសន្តអ៊ីម៉ាំហ៊្សសៃន៍صلوات الله عليه والسلامរស់នៅលើមាគ៌ាសន្តិភាពដោយលះបង់ខ្លួនដឹកនាំមនុស្សវិស័យសាសនា ។

គេដឹងច្បាស់ថាព្រះសន្តអ៊ីម៉ាំហ៊្សសៃន៍صلوات الله عليه والسلامមានចិត្តទូលំទូលាយ ។ គ្រាមួយបុរសអាក្រ័របសាសន៍អារ៉ាប់ម្នាក់មករកព្រះអង្គصلوات الله عليه والسلام ថាគាត់បានឮព្រះសាស្តាមូហ៊ាំម៉ាដ្ឋ៍صلى الله عليه وآله وسلمមានព្រះវចនៈថា ពេលទ័លខ្លាំងចូរសូមជំនួយពីបុរសចិត្តទូលាយនិងថ្លៃថ្នូរម្នាក់ ។ គាត់ក៏បានមករកព្រះសន្តអ៊ីម៉ាំហ៊្សសៃន៍صلوات الله عليه والسلام ព្រោះព្រះអង្គصلوات الله عليه والسلامប្រកបដោយគុណសម្បត្តិទាំងនេះ ។ ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلامបានប្រាប់គាត់ថាព្រះអង្គصلوات الله عليه والسلامនឹងសួរគាត់បីសំណួរ ។ ព្រះអង្គصلوات الله عليه والسلامនឹងឲ្យប្រាក់ដែលព្រះអង្គصلوات الله عليه والسلامមាននៅក្នុងថង់ទៅបុរសនោះមួយភាគបីចំណែកបើបុរសនោះឆ្លើយត្រូវសំណួរមួយ ។ កិច្ចសន្ទនាមានដូចតទៅគឺៈ

ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلام - ប្រការល្អបំផុតដែលត្រូវធ្វើគឺប្រការអ្វី ?

បុរសអាក្រ័រប - ជឿអល់ឡោះហ៍عز وجل ។

ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلام - មធ្យោបាយល្អបំផុតសម្រាប់បុគ្គល ដើម្បីការពារខ្លួនពីវិនាសអន្តរាយ (ក្នុងលោកមុខ) គឺអ្វី ?

បុរសអាក្រ័រប - គឺជឿអល់ឡោះហ៍عز وجل ។

ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلام - គុណសម្បត្តិប្រសើរបំផុតដែលបុគ្គលអាចមានគឺអ្វី ?

បុរសអាក្រ័រប - ចំណោះចេះដឹងបូករួមជាមួយប្រាជ្ញា ។

ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلام - បើមិនអាចរកបានប្រការនេះទេ មានប្រការអ្វីផ្សេង ?

បុរសអាក្រ័រប - ទ្រព្យសម្បត្តិជាប់ជាមួយចិត្តទូលាយ ។

ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلام - បើគ្មានសមត្ថភាពឈោងដល់ទៀត ?

បុរសអាក់រ៉ប - សេចក្ដីក្រខ្សត់ជាប់ជាមួយអំណត់ ។
ព្រះសន្ដអ៊ីម៉ាំ صلوات الله عليه والسلام - បើមិនអាចធ្វើបានទេ ?
បុរសអាក់រ៉ប - បើដូច្នេះ សូមឲ្យផ្លេកបន្ទោរកម្ទេចបុគ្គលឲ្យទៅជាផេះចុះ ។
ព្រះសន្ដអ៊ីម៉ាំ صلوات الله عليه والسلام ញញឹម ហើយបានប្រគល់ថង់ថវិកាទាំងអស់ឲ្យទៅបុរសអាក់រ៉ប ។

ថ្ងៃមួយ បុរសម្នាក់បានមករកព្រះសន្ដអ៊ីម៉ាំហ៊្សសៃន៍ صلوات الله عليه والسلام សូមយោបល់ព្រះអង្គ صلوات الله عليه والسلام ព្រោះគាត់មិនអាចទប់ខ្លួនកុំឲ្យធ្វើប្រការអាក្រក់បានទេ ។ ព្រះសន្ដអ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់គាត់ឲ្យធ្វើប្រការមួយក្នុងចំណោមប្រការទាំងប្រាំ រួចហើយគាត់អាចបន្តធ្វើប្រការអាក្រក់បាន គឺ៖

១. ចូរលោកកុំបរិភោគចំណីអាហារ (គឺរីស្ស៊ីគ្វី) របស់អល់ឡោះហ្ (عزّ وجلّ) និងបន្តការសាងអំពើអាក្រក់តាមតែចិត្តលោកចុះ ។

២. ចូរលោកចេញពីអាណាចក្ររបស់អល់ឡោះហ្ (عزّ وجلّ) និងបន្តការសាងអំពើអាក្រក់តាមតែចិត្តលោកចុះ ។

៣. ចូរលោករកកន្លែងណាដែលអល់ឡោះហ្ (عزّ وجلّ) មើលមិនឃើញលោកទេ និងបន្តការសាងអំពើអាក្រក់តាមតែចិត្តលោកចុះ ។

៤. ពេលទេវតាយកព្រលឹងមកដកព្រលឹងលោក ចូរលោករារាំងកុំឲ្យយកព្រលឹងលោកបាន ។

៥. ពេលគេអូសទាញលោកទៅទម្លាក់ក្នុងភ្លើងនរក តាមព្រះរាជបញ្ជារបស់អល់ឡោះហ្ (عزّ وجلّ) ចូរលោកបដិសេធ មិនព្រមចូលក្នុងភ្លើងនរកនោះ ។

មូអាវីយ៉ាស្ស៍ស្លាប់ក្នុងឆ្នាំ ៦០ សករាជហ៊ីជ្រ៉េះត៍ ដោយបានរៀបចំសព្វគ្រប់ដើម្បីនឹងឲ្យយ៉ាស៊ីដ្ឋនឹងបានទៅជាសេច្ចខ៍លិហ្វថ្មី ។ មូអាវីយ៉ាស្ស៍បានប្រព្រឹត្តបទឧក្រិដ្ឋអាក្រក់បំផុតច្រើនណាស់ដើម្បីនឹងបានសម្រេចគោលដៅនេះ ដោយបានសម្លាប់មនុស្សត្រឹមត្រូវច្រើននាក់ ដូចជា ហ៊ុជ្រ៍ ប៊ិន អ៊ាឌី (حُجْر اَبْن عَدِيّ) ជាដើម ។ មុនស្លាប់ មូអាវីយ៉ាស្ស៍បានផ្ដែផ្ដាំកូនប្រុសខ្លួន កុំឲ្យចូលឡូកឡំជាមួយព្រះសន្ដអ៊ីម៉ាំហ៊្សសៃន៍ صلوات الله عليه والسلام ជាដាច់ខាត ព្រោះព្រះអង្គ صلوات الله عليه والسلام ជាបុគ្គលមួយគត់ដែលអាចជះឥទ្ធិពលទៅលើអំណាចរបស់ឪពុកកូនគូនេះបាន ។ តែយ៉ាស៊ីដ្ឋប្រកាន់ខ្លួនពេក មិន

ស្តាប់ឱវាទបែបនេះទេ ។ ប្រការដំបូងបង្អស់ដែលយ៉ាស៊ីដធ្វើគឺផ្ញើសំបុត្រទៅទេសាភិបាលនគរម៉ាឌីណាស់ដែលនៅក្រោមបង្គាប់ខ្លួននោះ ប្រាប់ថាឲ្យព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام សច្ចាទទួលស្គាល់ខ្លួនជាស្តេចខ៍លិហ្វ ។

ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام បដិសេធដាច់អហង្ការ តែព្រះអង្គ صلوات الله عليه والسلام ត្រូវចាកចេញពីម៉ាឌីណាស់ជាចាំបាច់ ព្រោះវត្តមានព្រះអង្គ صلوات الله عليه والسلام អាចធ្វើឲ្យមុស្លីមក្នុងនគររងគ្រោះថ្នាក់ ។ ព្រឹត្តិការណ៍បន្តបន្ទាប់បណ្តាលឲ្យកើតមាននូវសោកនាដកម្មការបាឡាអ៊ំបានចាប់ផ្តើមដូច្នេះឯង ។ ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام បានប្រាប់ប្អូនប្រុសព្រះអង្គ صلوات الله عليه والسلام ឈ្មោះ មូហ៊ាំម៉ាដ់ អាល់-ហាណាហ្វីយ៉ាស់ (محمد ابن الحنفية) ថាព្រះអង្គ صلوات الله عليه والسلام ចាកចេញពីម៉ាដីណាស់ ដើម្បីស្តារសាសនារបស់ព្រះអយ្យកោ صلى الله عليه وآله وسلم ព្រះអង្គ صلوات الله عليه والسلام ព្រះសាស្តាមូហ៊ាំម៉ាដ់ صلى الله عليه وآله وسلم ឡើងវិញតែម្យ៉ាងទេ ។

ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام បានចាកចេញជាមួយគ្រួសារព្រះអង្គ صلوات الله عليه والسلام ទៅកាន់ម៉ាក់កាស់ បន្ទាប់ពីនោះបានទៅកាន់គូហ្វាស់ ។ អ្នកស្រុកគូហ្វាស់ច្រើនបានផ្ញើសំបុត្រមកសូមឲ្យព្រះអង្គ صلوات الله عليه والسلام ទៅស្រុកពួកគេ ដើម្បីបំពេញសេចក្តីត្រូវការរបស់ពួកគេ ។ តាមផ្លូវ កងពលមួយកងរបស់យ៉ាស៊ីដ ដឹកនាំដោយបុគ្គលឈ្មោះ ហ៊ូរ (اَلْحُرّ بْنَ يَزِيدَ الرِّيَاحِيّ) បានបំបែរផ្លូវព្រះអង្គ صلوات الله عليه والسلام ឲ្យទៅឯការបាឡាអ៊ំ ។

បន្ទាប់ពីបានរងការអត់បាយនិងអត់ទឹក ៣ ថ្ងៃ ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام និងបក្សពួកភក្តីមួយក្រុមតូចរបស់ព្រះអង្គ صلوات الله عليه والسلام បានធ្វើទុក្ករកម្មដោយបូជាជីវិតនៅឯការបាឡាអ៊ំ ។ ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام បានក្ស័យព្រះជន្មថ្ងៃទី ១០ ខែមូហារ៉ម ឆ្នាំ ៦១ សករាជហ៊ីជ្រ៉ោះត៍ កាលព្រះអង្គ صلوات الله عليه والسلام មានព្រះជន្មាយុ ៥៧ ព្រះវស្សា ។

# លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ព្រះសន្តអ៊ីម៉ាំហ្សាសាន់صلوات الله عليه والسلامក្សៀយព្រះជន្មឆ្នាំ

ក) ២៥ សករាជហ្ស៊ីច្ជ៉ោះត្ហ៍

ខ) ៥០ សករាជហ្ស៊ីច្ជ៉ោះត្ហ៍

គ) ១៩ សករាជហ្ស៊ីច្ជ៉ោះត្ហ៍

ឃ) ៤៥ សករាជហ្ស៊ីច្ជ៉ោះត្ហ៍

២. កាលព្រះសន្តអ៊ីម៉ាំហ្សូសៃន៍صلوات الله عليه والسلام ចង់ធ្វើតាមបណ្តាំចុងក្រោយរបស់ព្រះសន្តអ៊ីម៉ាំហ្សាសាន់صلوات الله عليه والسلام ព្រះអង្គصلوات الله عليه والسلامត្រូវហាមឃាត់ដោយ

ក) ពួកបានី អ៊ូម៉ៃយ៉ាស្ហ់

ខ) អល់ឡោះហ្វ៍عز وجل

គ) ពួកបានី អ៊ីសរ៉ាអ៊ីល

ឃ) មូអាវីយ៉ាស្ហ់

៣. យ៉ាស៊ីដជា

ក) អ្នកស្នងមូអាវីយ៉ាស្ហ់

ខ) លេខារបស់អ៊ុស្មម៉ាន

គ) បងប្រុសរបស់ អាប់ឌុលឡោះហ្វ៍ ប៊ិន អាប់បាស់

ឃ) លេខារបស់មូអាវីយ៉ាស្ហ់

៤. ព្រះសន្តអ៊ីម៉ាំហ្សូសៃន៍صلوات الله عليه والسلامល្បីល្បាញជា

ក) អ្នកមានចរិយាមារយាទល្អប្រពៃ

ខ) អ្នកមានចិត្តទូលំទូលាយ

គ) អ្នកមានសម្រស់ស្អាតដាច់គេ

ឃ) អ្នកមានសេចក្តីអង់អាចក្លាហាន

៥. "រីស្សាគ្ន៏" មានន័យថា
ក) ចំណីអាហារ
ខ) គុំនូរ
គ) អំណាច
ឃ) សីលត្រណម

៦. មូអាវីយ៉ាស្ទ់បានចាកចោលលោកនេះឆ្នាំ
ក) ៣៥ សករាជហ្ស៊ីច្រ៉េះត្ទ័
ខ) ៦០ សករាជហ្ស៊ីច្រ៉េះត្ទ័
គ) ៥៥ សករាជហ្ស៊ីច្រ៉េះត្ទ័
ឃ) ៥៦ សករាជហ្ស៊ីច្រ៉េះត្ទ័

៧. យ៉ាស៊ីដ្ទមិនស្តាប់បណ្តាំឪពុកខ្លួនទេ ព្រោះគាត់
ក) កាចពេក
ខ) សាហាវពេក
គ) ចចេសរឹងរូសពេក
ឃ) ប្រកាន់ខ្លួនពេក

៨. ប្អូនប្រុសរបស់ព្រះសន្តអ៊ីម៉ាំហ៊្សសៃន៍ صلوات الله عليه والسلام ឈ្មោះ
ក) ក៊្ទស៊ីម
ខ) មូហ៊ាំម៉ាដ្ទ អាល់-ហ៊ាណាហ្វីយ៉ាស្ទ់
គ) អាប៊្ទ បាការ
ឃ) មុស្លីម អ៊ីបន្ទ អាគ្ទីល

៩. ព្រះសន្តអ៊ីម៉ាំហ៊្សសៃន៍ صلوات الله عليه والسلام បានចាកចេញពីម៉ាឌីណាស្ទ់ ជាមួយគ្រួសារព្រះអង្គ صلوات الله عليه والسلام ទៅកាន់
ក) ម៉ាក់កាស្ទ់

ខ) ដូម៉ាស់

គ) ការបាឡាអ៊ុំ

ឃ) ណាយ៉ាហ៊ូ

១០. កាលព្រះអង្គصلوات الله عليه والسلامសោយព្រះទិវង្គត ព្រះសន្តអ៊ីមុាំហ្វ៊ូសៃន៍صلوات الله عليه والسلامមានព្រះជន្មាយុ

ក) ៧៥ ព្រះវស្សា

ខ) ៦៧ ព្រះវស្សា

គ) ៧២ ព្រះវស្សា

ឃ) ៥៧ ព្រះវស្សា

*sources:*
www.saba-igc.org
shia974.fr
www.madressa.net

អ៊ីម៉ាំមេម៉ាស្ហ៊ូប់ហ្វាប់ទាំង ៤ ។

| ឈ្មោះអ៊ីម៉ាំមេម៉ាស្ហ៊ូប់ហ្វាប់ | ម៉ាស្ហ៊ូប់ហ្វាប់ | ថ្ងៃកំណើត/ថ្ងៃស្លាប់<br>សករាជហ៊ិជ្រ៉ោះត៏ | ថ្ងៃកំណើត/ថ្ងៃស្លាប់<br>គ្រិស្តសករាជ |
|---|---|---|---|
| អាប៊ូ ហ៊ានីហ្វាស្ហ៊ូ | ហ៊ាណាហ្វី | 80-150 ស.ហ. | 699-767 គ.ស. |
| ម៉ាលិក | ម៉ាលីគី | 93-179 ស.ហ | 711-795 គ.ស. |
| អាស្ហ៊-ស្ហាហ្វីអ៊ី | ស្ហាហ្វីអ៊ី | 150-204 ស.ហ | 767-820 គ.ស. |
| អាស៊ុំម៉ាដ្ហ៊ូ ហ៊ាន់បាល់ | ហ៊ាន់បាលី | 164-241 ស.ហ. | 780-855 គ.ស. |

ព្រះសាសា មូហ៊ាំម៉ាដ្ហ៊ូ ប្រសូត/ចូលព្រះទិវង្គត ឆ្នាំ 570-632 គ.ស.

អ៊ីម៉ាំអ្នកស្នងព្រះសាស្តាមូហ៊ាំម៉ាដ្ហ៊ូﷺទាំង ១២ ។

| លំដាប់ | ឈ្មោះ | ឈ្មោះក្រៅ | ឋានន្តរស័ក្តិ | ថ្ងៃកំណើត/ថ្ងៃស្លាប់<br>គ.ស./ស.ហ. |
|---|---|---|---|---|
| 1 | អ៊ុលី | អាប៊ូ អាល់-ហ៊ាសាន់ | អាមីរុល-មុមីនីន | 600-661/23 មុន ស.ហ.-40 |
| 2 | ហ៊ាសាន់ | អាប៊ូ មូហ៊ាំម៉ាដ្ហ៊ូ | អាល់-មុច្ចតាបា | 625-670/3-50 |
| 3 | ហ៊ូសៃន៍ | អាប៊ូ អ៊ុប់ឌុលឡោះហ្វ៍ | សៃយីដ្ហ អាស្ហ៊-ស្ហ៊ូហ្វាដ្ហាអ៊ុំ | 626-680/4-61 |
| 4 | អ៊ុលី ប៊ិន ហ៊ូសៃន៍ | អាប៊ូ មូហ៊ាំម៉ាដ្ហ៊ូ | អាស់-សាច់យ៉ាដ្ហ៊ូ<br>ស្សៃនុល-អាប៊ីឌីន | 659-713/38-95 |
| 5 | មូហ៊ាំម៉ាដ្ហ៊ូ អាល់-បាក្វៀរ | អាប៊ូ យ៉ាក្ហ៊ុំហ្វារ | បាក្វៀរ អាល់-អ៊ូលូម | 676-733/57-114 |
| 6 | យ៉ាក្ហ៊ុំហ្វារ | អាប៊ូ អ៊ុប់ឌុលឡោះហ្វ៍ | អាស្ហ៊-ស្ហ៊ឌិក្វ | 702-765/83-148 |
| 7 | មូសា ប៊ិន យ៉ាក្ហ៊ុំហ្វារ | អាប៊ូ អាល់-ហ៊ាសាន់ | អាល់-កាស្ហ៊ីម | 745-799/128-183 |
| 8 | អ៊ុលី ប៊ិន មូសា | អាប៊ូ អាល់-ហ៊ាសាន់ | អារ-រីដ្ហ៊ | 765-819/148-203 |
| 9 | មូហ៊ាំម៉ាដ្ហ៊ូ ប៊ិន អ៊ុលី | អាប៊ូ យ៉ាក្ហ៊ុំហ្វារ | អាត់-តាគ្វី<br>អាល់-យ៉ាវ៉ាដ្ហ៊ូ | 811-835/195-220 |
| 10 | អ៊ុលី ប៊ិន មូហ៊ាំម៉ាដ្ហ៊ូ | អាប៊ូ អាល់-ហ៊ាសាន់ | អាល់-ហ្វាឌី<br>អាន់-ណាគ្វី | 828-868/212-254 |
| 11 | ហ៊ាសាន់ ប៊ិន អ៊ុលី | អាប៊ូ មូហ៊ាំម៉ាដ្ហ៊ូ | អាល់-អ៊ុស់ការី | 846-874/232-260 |
| 12 | មូហ៊ាំម៉ាដ្ហ៊ូ ប៊ិន ហ៊ាសាន់ | អាប៊ូ ក្វ៉ាស៊ីម | អាល់-ម៉ាស្ហ៊ូឌី<br>អាល់-ហ៊ុជ្ជយ៉ាស្ហ៊ូ<br>ស្ហ៊ហ្វ៊ីប អាល់-ស្សាម៉ាន<br>អាល់-ក្វ៉ាអ៊ីម | 869/255 |